សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economies

Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. សុត សច្ចា**

**ខ. ហឿន ចិត្រា**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត ទូរ សុខុម៉ា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៥

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំបញ្ចប់សិក្សា ២០២២

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economies

Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. សុត សច្ចា**

**ខ. ហឿន ចិត្រា**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត ទូរ សុខុម៉ា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៥

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំបញ្ចប់សិក្សា ២០២២

# សេចក្តីថ្លែងអំណរគុណ


នាងខ្ញុំឈ្មោះ **សុត សច្ចា** និងខ្ញុំបាទឈ្មោះ **ហឿន ចិត្រា** ជានិស្សិតបរិញ្ញាបត្រឆ្នាំទី៤ ជំនាន់ទី១៥ ផ្នែករដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានសិក្សាចាប់ពីឆ្នាំ ២០១៨ ដល់ ២០២២។

**សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖**

- **លោកឪពុក** និង **អ្នកម្តាយ** ដែលលោកទាំងពីរពិតជាមានគុណដ៏ធំធេង ដែលលោកមិនត្រឹមតែផ្តល់កំណើតដល់រូបយើងខ្ញុំប៉ុណ្ណោះទេ លោកបានខិតខំថែរក្សាចិញ្ចឹមបីបាច់ផ្តល់ដំបូន្មានល្អៗព្រមទាំងខំប្រឹងប្រែងអស់ពីកំលាំងកាយចិត្ត លះបង់គ្រប់បែបយ៉ាងដើម្បីឱ្យកូនៗក្លាយជាអ្នកមានចំណេះដឹងមួយរូបនៅក្នុងសង្គម។ លោកពិតជាបានជួបនូវឧបសគ្គការលំបាកជាច្រើនប៉ុន្តែលោកមិនដែលត្អូញត្អែរ និងរុញរាឡើយ។ ដោយសារតែទទួលបានការលើកទឹកចិត្តនិងភាពកក់ក្តៅរបស់លោកទាំងពីរដែលជាកំលាំងចលករមួយដ៏មហិមាទើបយើងខ្ញុំក្លាយជានិស្សិតមួយរូបដែលបាបញ្ចប់ថ្នាក់បរិញ្ញាបត្រព្រមទាំងមានលទ្ធភាពក្នុងការសរសេរសារណាមួយនេះបាន។
- **រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា** និង **ក្រសួងអប់រំយុវជន និងកីឡា** ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការលើកកម្ពស់ទៅលើវិស័យអប់រំ ហើយបានបង្កើតនៅគ្រឹះស្ថានឧត្តមសិក្សា សម្រាប់បណ្តុះបណ្តាលចំណេះដឹងជាច្រើនដែលធ្វើឱ្យយុវជនជំនាន់ក្រោយអាចបន្តការសិក្សា និងក្រេបជញ្ជក់យកចំណេះវិជ្ជាសម្រាប់ជួយខ្លួនពួកគេនៅពេលបច្ចុប្បន្ននិងអនាគត។ ជាពិសេសគឺដើម្បីកសាងជាតិមាតុភូមិឱ្យមានការរីកចម្រើនជានិរន្តរ៍។
- **ឯកឧត្តម បណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រីសាស្ត្រាចារ្យ ដែលបានខិតខំអស់ពីកំលាំងកាយចិត្តពីសមត្ថភាពក្នុងការដឹកនាំគ្រប់គ្រង និងបង្ហាត់បង្រៀនរូបយើងខ្ញុំឱ្យទទួលបានចំណេះដឹងដើម្បីសរសេរសារណានេះឡើង ។
- **សាស្ត្រាចារ្យ បណ្ឌិត ទូរ សុខុម៉ា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំណែនាំបង្ហាត់បង្ហាញពន្យល់កែតម្រូវ និងបានបង្កលក្ខណៈងាយស្រួលដល់ការសរសេរសារណានេះឡើង។

ជាចុងក្រោយយើងខ្ញុំសូមបួងសួងដល់វត្ថុស័ក្តសិទ្ធិទាំងពួងលើលោកនេះ ឱ្យជួយតាមថែរក្សាអស់លោកអ្នកមានគុណ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ បងប្អូន រាមច្បង និងមិត្តភក្តិទាំងឡាយឱ្យជួបតែសេចក្តីសុខសេចក្តីចម្រើនគ្រប់វេលាកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំទាំងពីរជានិស្សិត ក្រុម **P4A3** ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈជំនាន់ទី១៥ នៃឆ្នាំសិក្សា ២០១៨-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានសម្រេចយកនូវការស្រាវជ្រាវ និងចងក្រងជា សារណាបញ្ចប់ឆ្នាំសិក្សាមួយស្ដីពី « **ការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ** » សម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ។

ការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ គឺពិតជាមានសារៈសំខាន់ណាស់នៅក្នុងការចូលរួមចំណែកអភិវឌ្ឍសង្គមជាតិទាំងមូលឱ្យមានការជឿនលឿនរីកចម្រើនទៅមុខ។ ជាងនេះទៅទៀតការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិគឺបានលើកកម្ពស់គុណភាពនៃការផ្ដល់សេវាសាធារណៈ បង្កើនសុខុមាលភាព និងធ្វើការតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានទាំងអស់ដែលធ្វើឱ្យរដ្ឋាភិបាល និងប្រជាពលរដ្ឋកាន់តែមានភាពជិតស្និទ្ធនិងគ្នាមិនតែប៉ុណ្ណោះមានការយល់កាន់តែច្បាស់អំពីតម្រូវការរបស់ប្រជាពលរដ្ឋថា ពួកគាត់មានតម្រូវការចង់បានអ្វី និងមិនចង់បានអ្វី ដើម្បីងាយស្រួលក្នុងការដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋបានទាន់ពេលវេលា។

អាស្រ័យដូចបានរៀបរាប់ខាងលើរួចមកហើយ ដែលកត្តាធ្វើឱ្យយើងខ្ញុំទាំងពីរសម្រេចចិត្តជ្រើសរើសយកប្រធានបទ « **ការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ** » យកមកសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ព្រោះថាប្រធាននេះបានបង្ហាញឱ្យយើងមើលឃើញនូវ ការរៀបចំចាត់ចែងតួនាទីភារកិច្ចរបស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តដោយគោរពទៅតាមបទដ្ឋានគតិយុត្តនានា។

ជាការពិត សារណាដែលកំពុងស្ថិតនៅក្នុងដៃរបស់មិត្តអ្នកអាននេះ ទោះបីជាបានចេញជារូបរាងពិតមែនតែកំហុសដែលកើតឡើងដោយអចេតនាតែងតែមានដូចជា៖ ការប្រើពាក្យពេចន៍ ការប្រើភាសា អក្ខរាវិរុទ្ធ ការប្រើប្រាស់វេយ្យាករណ៍ជាដើម ដែលមិនអាចជៀសផុតឡើយ។ លើសពីនេះទៅទៀត កម្រិតនៃការយល់ដឹងពេលវេលា ឯកសារ កិច្ចសហការពីមន្ត្រីមូលដ្ឋានញ៉ាំងឱ្យកិច្ចការនេះមិនទាន់មានលក្ខណៈទូលំទូលាយនៅឡើយ។

ជាចុងបញ្ចប់យើងខ្ញុំទាំងពីរសង្ឃឹមថាសារណានេះនឹងផ្ដល់ជាជំនួយ និងគន្លឹះខ្លះៗសម្រាប់មិត្តអ្នកអានណាដែលចង់ចេះដឹង ស្រាវជ្រាវ ស្វែងយល់ពីគ្រប់មជ្ឈដ្ឋានទាំងអស់។ម្យ៉ាងវិញទៀត យើងខ្ញុំទាំងពីរនាក់ពិតជាមានសេចក្ដីរីករាយ និងរងចាំទទួលយកគ្រប់យ៉ាងនូវការរិះគន់ ក្នុងន័យស្ថាបនាពីសំណាក់មិត្តអ្នកអានទាំងអស់ យើងខ្ញុំទាំងពីរនាក់ព្យាយាមខិតខំបន្តពង្រឹងស្ថាបនាឯកសារស្រាវជ្រាវឱ្យកាន់តែមានគុណភាព និងក្លាយទៅជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់យើងខ្ញុំទាំងពីរ

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............................................................ ១

**ជំពូកទី១**

**រំលឹកទ្រឹស្តី**

**១.១. កំណត់អត្ថន័យ** ............................................................ ៥

**១.២. បទពិសោធន៍នៃការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ** ............................................................ ៥

១.២.១. សម័យមុនអាណានិគមនិយមបារាំង ............................................................ ៥

១.២.២. សម័យអាណានិគមបារាំង ............................................................ ៧

១.២.៣. សម័យក្រោយអាណានិគមបារាំង ............................................................ ៨

**១.៣. សញ្ញាណរដ្ឋបាលថ្នាក់ក្រោមជាតិ** ............................................................ ១០

១.៣.១. និយមន័យ ............................................................ ១០

១.៣.២. ចរិតលក្ខណៈ ............................................................ ១០

១.៣.៣. វិមជ្ឈការ និង វិសហមជ្ឈការនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ............................................................ ១១

**១.៤. ការរៀបចំរដ្ឋបាលនៅថ្នាក់ក្រោមជាតិ** ............................................................ ១១

១.៤.១. អំពីរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ............................................................ ១៣

១.៤.២. រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ............................................................ ១៣

១.៤.៣. អំពីឃុំ សង្កាត់ ............................................................ ១៥

១.៤.៤. រដ្ឋបាល ឃុំ សង្កាត់ ............................................................ ១៦

**ជំពូកទី២**

**ដំណើរការនៃការប្រព្រឹត្តទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

**២.១. ទិដ្ឋភាពទូទៅនៃរដ្ឋបាលថ្នាក់ក្រោមជាតិ** ............................................................ ១៨

**២.២. រចនាសម្ព័ន្ធការងារ** ............................................................ ២១

២.២.១. រចនាសម្ព័ន្ធការងារ របស់រដ្ឋបាលរាជធានី ខេត្ត ............................................................ ២១

២.២.២. រចនាសម្ព័ន្ធការងារ របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ............................................................ ២២

២.២.៣. រចនាសម្ព័ន្ធការងារ របស់រដ្ឋបាលឃុំ សង្កាត់ ............................................................ ២៤

**២.៣. ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ** ............ ២៥
២.៣.១. ការគ្រប់គ្រងបែបវិសហមជ្ឈការ ............ ២៥
២.៣.២. ការគ្រប់គ្រងបែបវិមជ្ឈការ ............ ២៦
២.៣.២.១. ការគ្រប់គ្រងរដ្ឋបាល ............ ២៧
២.៣.២.២. ការគ្រប់គ្រងហិរញ្ញវត្ថុ ............ ២៨
**២.៤. មុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** ............ ៣០
២.៤.១. ប្រភេទនៃមុខងារ ............ ៣០
២.៤.២. គោលការណ៍នៃការផ្ទេរមុខងារ ............ ៣១

## ជំពូកទី៣

## ពិភាក្សា

**៣.១. ពិភាក្សាអំពីអំណាច រដ្ឋបាលថ្នាក់ក្រោមជាតិ** ............ ៣៣
៣.១.១. ពិភាក្សាអំពីអំណាច រដ្ឋបាលរាជធានី ខេត្ត ............ ៣៣
៣.១.២. ពិភាក្សាអំពីអំណាច រដ្ឋបាលក្រុង ស្រុក ខណ្ឌ ............ ៣៣
៣.១.៣. ពិភាក្សាអំពីអំណាច រដ្ឋបាលឃុំ សង្កាត់ ............ ៣៤
**៣.២. ចំណុចខ្លាំង ចំណុចខ្សោយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** ............ ៣៥
៣.២.១. ចំណុចខ្លាំងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ............ ៣៥
៣.២.២. ចំណុចខ្សោយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ............ ៣៦
**សេចក្តីសន្និដ្ឋាន** ............ ៣៧
**អនុសាសន៍** ............ ៣៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមជាច្រើនលើក ច្រើនសារ មិនត្រឹមតែបានបន្ទុចបង្អាក់ការអភិវឌ្ឍន៍នៅកម្ពុជាលើគ្រប់វិស័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរនូវរចនាសម្ព័ន្ធ សង្គម សេដ្ឋកិច្ចវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ ប្រព័ន្ធនយោបាយ និងផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងរដ្ឋបាលជាបន្តបន្ទាប់ដោយគិតពីឆ្នាំ១៩៤៧ រហូតមកដល់ឆ្នាំ១៩៩៣។ ទោះយ៉ាងនេះក្តី រដ្ឋាភិបាលកម្ពុជា នាពេលនោះបានខិតខំរិះរកគ្រប់មធ្យោបាយដើម្បីស្តារ និងអភិវឌ្ឍប្រទេសជាតិឡើងវិញលើគ្រប់វិស័យ ក្នុងនោះរួមទាំងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យមានសមត្ថភាពក្នុងការថែរក្សាសន្តិសុខសុវត្ថិភាពតាមមូលដ្ឋាន។

ក្រោយមកនៅឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានបង្កើត រដ្ឋធម្មនុញ្ញថ្មីនៃព្រះរាជាណាចក្រកម្ពុជា ដែលជាការបើកទំព័រថ្មីនៃប្រព័ន្ធគ្រប់គ្រងរដ្ឋ ទាំងរបបនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាលផងដែរ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានធ្វើវិសោធនកម្មដើម្បីរៀបចំឡើងវិញនូវដែនដីរដ្ឋបាលនៅព្រះរាជាណាចក្រកម្ពុជាដូចខាងក្រោម៖

- ដែនដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានីភ្នំពេញ និងខេត្ត។
- រាជធានីភ្នំពេញចែកជា ខណ្ឌ។ ខណ្ឌចែកជា សង្កាត់។
- ខេត្តចែកជា ក្រុង និងស្រុក។ ក្រុងចែកជា សង្កាត់។ ស្រុកចែកជា ឃុំ និងជា សង្កាត់។ ការរៀបចំដែនដីតាមការបែងចែកនេះ គឺសំដៅរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងឱ្យបានជាក់លាក់រវាងតំបន់ទីក្រុង ទីប្រជុំជន និងតំបន់ជនបទ ដែលបានអនុវត្តរហូតមកទល់សព្វថ្ងៃ។

កម្ពុជាបានធ្វើការរៀបចំរដ្ឋបាលឱ្យមានភាពប្រសើរឡើងដោយបង្កើតឱ្យមានការបែងចែកអំណាច និង ការផ្ទេរនូវសិទ្ធិអំណាច មួយចំនួនចាប់ពីររដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីធ្វើការគ្រប់គ្រង និងផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋនៅមូលដ្ឋាននីមួយៗដែលរដ្ឋមិនអាចផ្តល់ជូនបានទាន់ពេលវេលា និងមានប្រសិទ្ធភាពនោះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

មូលហេតុដែលជំរុញឱ្យយើងខ្ញុំស្រាវជ្រាវអំពី ការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិនៃព្រះរាជាណាចក្រកម្ពុជា ដោយយើងខ្ញុំបានសង្កេតឃើញថាការរៀបចំឱ្យមានរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ជាការបង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានក្នុងការចូលរួម នឹងប្រាស័យទាក់ទងការងារផ្សេងៗ។

ដើម្បីដឹងច្បាស់ពីការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានបញ្ហាចោទសួរ និងលើកឡើងជាច្រើនដូចជា៖

១. តើការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈបែបណា? តើអ្នកណាខ្លះជាអ្នកចូលរួមក្នុងការរៀបចំ?
២. តើរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបាននូវសិទ្ធអំណាចអ្វីខ្លះ នៅក្នុងការអនុវត្តការងារនៅមូលដ្ឋាន?
៣. តើការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិបានផ្តល់នូវផលប្រយោជន៍អ្វីខ្លះដល់ប្រជាជនកម្ពុជាក្នុងពេលបច្ចុប្បន្ន?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ គឺមានគោលបំណងក្នុងការចូលរួមចំណែកបង្កើនចំណេះដឹងដល់ក្រុមរបស់យើងខ្ញុំ ដែលបានធ្វើការខិតខំស្រាវជ្រាវឡើង ព្រមទាំងបានយល់កាន់តែច្បាស់អំពីការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ និងការអនុវត្តការងាររបស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិយើង។ ខ្ញុំសង្ឃឹមថាការស្រាវជ្រាវឯកសារមួយនេះអាចជាជំនួយដល់មិត្តនិស្សិតជំនាន់ក្រោយអាចយកទៅសិក្សាបានបន្ថែមទៀត។ គោលបំណងក្នុងការសិក្សស្រាវជ្រាវលើប្រធានបទមួយនេះនេះគឺយើងខ្ញុំផ្តោតទៅលើការស្វែងយល់ចំណុចមួយចំនួនដូចជា៖

- ដើម្បីសិក្សាស្វែងយល់ពីដំណើរការនៃការប្រព្រឹត្តទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- ស្វែងយល់ពីការគ្រប់គ្រងសេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- សិក្សាស្វែងយល់អំពីការយល់ដឹង និងការទទួលបានរបស់ប្រជាជនក្នុងការប្រើប្រាស់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ទំហំ និងដែនកំណត់នៃការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ គឺផ្តោតសំខាន់ទៅលើ **ការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ** ដែលផ្តោតសំខាន់ទៅលើការរៀបចំស្ថាប័នរដ្ឋបាលនៅពេលបច្ចុប្បន្នដែលរួមមានរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ពីប្រព័ន្ធគ្រប់គ្រង និងដំណើរការប្រព្រឹត្តទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ដែលការសិក្សាស្រាវនេះបានផ្អែកទៅលើមូលដ្ឋានច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការលើកយកនូវប្រធានបទនៃការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ នៃព្រះរាជាណាចក្រកម្ពុជាមកធ្វើការសិក្សាស្រាវជ្រាវនេះពិតជាមានសារៈសំខាន់ណាស់សម្រាប់អ្នកសិក្សាផ្នែករដ្ឋបាលសាធារណៈ ព្រោះថាការសិក្សាស្រាវជ្រាវមួយនេះបានផ្តល់សារៈសំខាន់ជាច្រើនដូចជា៖

- **សារៈសំខាន់សំខាន់សម្រាប់សង្គម៖** សម្រាប់ទុកជាឯកសារដល់អ្នកសិក្សាជំនាន់ក្រោយៗ ដើម្បីជាឯកសារជំនួយនៃការសិក្សាស្រាវជ្រាវ បង្កើនចំណេះដឹងដល់អ្នកអានបានយល់ពីប្រព័ន្ធគ្រប់គ្រងពីការរៀបចំក៏ដូចជាតួនាទីភារកិច្ចរបស់ រួមទាំងការប្រព្រឹត្តទៅរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ។
- **សារៈសំខាន់សម្រាប់រាជរដ្ឋាភិបាល៖** ងាយស្រួលក្នុងការកែលម្អ កំណែរទម្រង់បន្ថែមលើការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ។
- **សារៈសំខាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** យល់ច្បាស់អំពីនីតិវិធីនៃការប្រើប្រាស់ដែលកន្លងមកអាចមានការចន្លោះប្រហោងក្នុងការបំពេញតួនាទីរបស់ខ្លួន និងអាចផ្តល់ជូនសេវាសាធារណៈជូនប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួនបានកាន់តែប្រសើរជាងមុន។
- **សារៈសំខាន់សម្រាប់ប្រជាពលរដ្ឋ៖** ធ្វើឱ្យប្រជាពលរដ្ឋមានការយល់ដឹងកាន់តែច្រើនអំពីការផ្តល់សេវាសាធារណៈ និងអាចប្រើប្រាស់សេវាសាធារណៈកាន់តែល្អប្រសើរ។
- **សារៈសំខាន់សម្រាប់អ្នកសិក្សាស្រាវជ្រាវផ្ទាល់៖** បានពង្រឹង និងពង្រីកចំណេះដឹងតាមរយៈការស្រាវជ្រាវប្រមូលផ្តុំនូវឯកសារជាច្រើនដែលទាក់ទងនឹងការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ និងបានស្វែងយល់អំពីរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែច្បាស់លាស់។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

កិច្ចការស្រាវជ្រាវមួយនេះ ត្រូវបានរៀបចំឡើងដោយមានការសិក្សាប្រមូលទិន្នន័យបានច្បាស់លាស់ និងត្រឹមត្រូវដែលផ្តោតសំខាន់ទៅលើការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិនៃព្រះរាជាណាចក្រកម្ពុជា ដោយប្រើវិធីសាស្ត្របែបអត្ថាធិប្បាយ និងរៀបចំឡើងតាមប្រភពទិន្នន័យចម្បងៗដូចជា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឯកសារនៅបណ្ណាល័យមួយចំនួនដែលទាក់ទងទៅនឹងប្រធានបទ ឯកសារពីសាស្ត្រាចារ្យដឹកនាំ ឯកសារដែលយើងខ្ញុំធ្លាប់បានសិក្សាពីមុនៗមក និងឯកសារខ្លះទៀតក្រុមយើងខ្ញុំបានធ្វើការស្រាវជ្រាវតាមប្រព័ន្ធគេហៈទំព័រណាមួយ ដើម្បីបានឯកសារបន្ថែមសម្រាប់ធ្វើឱ្យប្រធានបទកាន់តែមានន័យនឹងទូលំទូលាយបន្ថែមទៀត។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះរចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវនេះ ត្រូវបានចែកចេញជា១កថាខណ្ឌ និង៣ជំពូកគឺ៖

**សេចក្តីផ្តើម៖** និយាយអំពី សេចក្តីផ្តើមដែលបរិយាយអំពី លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី១៖** រំលឹកទ្រឹស្តី ដែលបរិយាយអំពី ការកំណត់អត្ថន័យ បទពិសោធនៃការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ សញ្ញាណនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**ជំពូកទី២៖** ដំណើរការនៃការប្រព្រឹត្តទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ បរិយាយអំពី ទិដ្ឋភាពទូទៅនៃរដ្ឋបាលថ្នាក់ក្រោមជាតិ រចនាសម្ព័ន្ធការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ជំពូកទី៣៖** ពិភាក្សាអំពីអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងបរិយាយអំពីចំណុចខ្លាំង និងចំណុចខ្សោយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

# ជំពូកទី១

# រំលឹកត្រីស្តី

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. កំណត់អត្ថន័យ

ជាដំបូងយើងត្រូវស្គាល់និយមន័យនៃពាក្យ "**រដ្ឋបាល**" ជាមុនសិនៈ

ពាក្យ "**រដ្ឋបាល**" ត្រូវបានគេឱ្យនិយមន័យផ្សេងៗគ្នាទៅតាមការប្រើប្រាស់ និងទស្សនៈផ្សេងៗដែលយើងអាចស្វែងយល់បាន។ ក្នុងនោះយើងឃើញរួមមានដូចជាៈ

តាមន័យអក្សរសាស្ត្រ ពាក្យរដ្ឋបាលបានមកពីពាក្យ **រដ្ឋ** + **បាល**។

ពាក្យ "**រដ្ឋ**" មានន័យថាជា ប្រទេស ដែន បុរី នគរ។

ពាក្យ "**បាល**" គឺជាការគ្រប់គ្រង ថែរក្សា។

ដូចនេះ រដ្ឋបាលគឺការគ្រប់គ្រង ថែរក្សាក្នុងប្រទេស ក្នុងបុរី។[1]

តាមន័យវិទ្យាសាស្ត្ររដ្ឋបាលត្រូវបានគេឱ្យនិយមន័យថា គឺជាអង្គការមួយខុសប្លែកពីអង្គការដទៃទៀតពីព្រោះវាមានគោលដៅបម្រើដល់ប្រយោជន៍សាធារណៈជាធំនិងដើម្បីឱ្យគោលដៅនេះមានប្រសិទ្ធិភាព។ រដ្ឋបាលទទួលបានបុព្វសិទ្ធនៃអំណាចសាធារណៈ និងអំណាចធម្មានុរូបដែលតម្រូវឱ្យប្រជាពលរដ្ឋគោរពតាមសេចក្តីសម្រេចរដ្ឋបាល។[2]

ចំណែកឯរដ្ឋបាលថ្នាក់ក្រោមជាតិ គឺសំដៅទៅលើរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។[3]

## ១.២. បទពិសោធន៍នៃការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ

### ១.២.១. សម័យមុនអាណានិគមនិយមបារាំង

សម័យមុនអាណានិគមនិយមបារាំង គឺជារបបរាជានិយមដែលព្រះមហាក្សត្រក្តោបអំណាចទាំងអស់ដោយផ្ទាល់តែមួយអង្គឯង ជាពិសេសអំណាចនយោបាយនិងអំណាចរដ្ឋបាល។ ព្រះមហាក្សត្រមិនធ្វើច្បាប់ដោយផ្ទាល់ទេ គឺទ្រង់យកច្បាប់ដែលចេញពី គម្ពីរវេទ និងទំនៀមទំលាប់មកប្រតិបត្តិតែម្តង។ ព្រះមហាក្សត្រចេញព្រះរាជក្រឹត្យបញ្ញាតែក្នុងវិស័យរដ្ឋបាល និងក្នុងនីតិវិធីតុលាការខ្លះតែប៉ុណ្ណោះ។

---

[1] សៀវភៅ វចនានុក្រមខ្មែរសម្តេចព្រះសង្ឃរាជជួនណាត ភាគទី១ ភាគទី២

[2] សៀវភៅ នីតិរដ្ឋបាល និងការងាររដ្ឋបាល រៀបរៀងដោយឯកឧត្តមបណ្ឌិត សំ សារ៉ាក់

[3] មាត្រា៤ សេចក្តីសម្រេចស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

❖ **ការរៀបចំរដ្ឋបាលដែនដីមាន៖**

**ក. ដី៖** ដែលជាអតីតរាជាណាចក្រនៃប្រទេសដែលស្តេចខ្មែរវាយយកមកចំណុះរួមបញ្ចូលយកជាដីខ្មែរតែម្តង។ តាំងពីបរាជ័យនៅលង្វែកកាលពីក្នុងឆ្នាំ ១៥៩៣ មកឯកសារសំខាន់ៗបានបាត់អស់ ហេតុដូចនេះយើងពុំអាចដឹងដោយច្បាស់ថាដីនោះមានចំនួនប៉ុន្មានពិតប្រាកដទេ។ យើងមិនដឹងច្បាស់ថាមានខេត្តចំនួន ៩០ ឬ ១០១ខេត្តទេ ពីព្រោះវាទៅជារឿងព្រេងអស់ទៅហើយ ដោយសារការរលំរលាយនៃបន្ទាយលង្វែកនោះ។ ស្តេចដែលត្រូវកាន់កាប់ដីនោះគេហៅថា ស្តេចក្រាញ់ ដែលមានអំណាចតែងតាំង ឬដេញចោលមន្ត្រីទាំងអស់ដែលនៅក្នុងដីនោះស្តេចក្រាញ់មានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ។ ចាប់តាំងពីពាក់កណ្តាលសតវត្សទី១៩ មកព្រះបាទអង្គឌួង (សោយរាជ្យពីឆ្នាំ១៨៤៥ ដល់១៨៦០) បានលុបចោលស្តេចក្រាញ់ជាបន្តបន្ទាប់មកលើការកាន់កាប់ដីទាំងនោះ និងដកអំណាចអស់ពីស្តេចក្រាញ់ឱ្យនៅសល់តែងារប៉ុណ្ណោះ។

**ខ. មឿង៖** គឺជាការបែងចែករដ្ឋបាលដែនដី។ មន្ត្រីដែលគ្រប់គ្រងកាន់កាប់មឿងក្នុងព្រះនាមនៃព្រះមហាក្សត្រគេហៅថា **ចៅមឿង**។ ព្រះបាទអង្គឌួងក្រោយមកព្រះអង្គមិនចង់ឱ្យមានឈ្មោះមឿងដែលជាឈ្មោះសៀម ព្រះអង្គក៏ឱ្យផ្លាស់ឈ្មោះ ហើយហៅថាខេត្តវិញ។ ដូច្នេះឈ្មោះខេត្ត កើតតាំងពីសម័យព្រះអង្គឌួងហើយនៅជាប់រហូតដល់សព្វថ្ងៃនេះ។ នៅឆ្នាំ១៨៨៤ មាន ៥៧ ខេត្ត។

**គ. ស្រុក៖** ជាឈ្មោះមួយដែលខ្មែរទូទៅហៅសម្រាប់សម្គាល់ភូមិកំណើតរបស់ខ្លួនកាលមុនសម័យបារាំងចូលមក។ ស្រុក គឺមិនមែនជាមណ្ឌលរដ្ឋបាលឡើយ។ ស្រុកនេះជាភូមិឥឡូវយើងហៅថាឃុំ កើតឡើងពីគ្រួសារមួយ ឬពីរ ហេតុដូច្នេះបានជាជួនកាលគេឱ្យឈ្មោះភូមិ ថាស្រុក។ កាលសម័យនោះ កាលណារាស្ត្រនិយាយថាចៅហ្វាយស្រុក គាត់ចង់និយាយថា ចៅហ្វាយខេត្តវិញទេ។ ពួកចាស់ៗក្នុងស្រុកជំនុំគ្នាជាក្រុមជំនុំហើយចាត់ក្នុងចំណោមជនដែលមានវ័យក្មេងជាងគាត់ហើយដែលមានបញ្ញា ឆ្លាតវាងវៃឱ្យធ្វើការឱ្យស្រុកខ្លួនគេហៅ មេស្រុក។

ដូច្នេះតាមប្រវត្តិសាស្ត្រ មេស្រុកគឺជាអ្នកជំនួយការតែប៉ុណ្ណោះ។ ចាស់ៗទាំងនោះដល់ក្រោយមកក៏បញ្ចូលក្នុងក្រុមជំនុំរបស់ស្រុក នូវអតីតមន្ត្រី អាចារ្យវត្ត ឬអ្នកប្រាជ្ញអក្សរ សាស្ត្រដើម្បីជួយគិតការងារ។ គេឱ្យឈ្មោះក្រុមនោះ ថាក្រុមពញ្ញា។ ពួកនេះធ្វើការឥតបៀវត្សអ្វីទេ។ ក្រុមពញ្ញានេះ បានបង្កើតភ្នាក់ងារជំនួយមេស្រុកដែលគេហៅថា ជំទប់។ ហើយជំទប់ក៏អាចរកស្មៀនឱ្យជួយសរសេរ ឬធ្វើការងារផ្សេងៗបានដែរ។ គេទាំងអស់ធ្វើការគ្មានប្រាក់ខែទេ ពីព្រោះពុំទាន់មានការបង្កើតលុយចាយនៅឡើយ។ គេទទួលបានអំណោយជារង្វាន់ដូចជា អង្ករ ត្រី។ ព្រះបាទអង្គឌួងទ្រង់បានបង្កើតប្រាក់ឱ្យចាយនៅក្នុងពាក់កណ្តាលសតវត្សទី១៩។[4]

---

[4] សៀវភៅ នីតិរដ្ឋបាល ស្តីពីចំណេះដឹង និងការងាររដ្ឋបាល កិច្ចការលេខាធិការ និងបណ្ណាសារដ្ឋាន , បណ្ឌិត ឯកឧត្តម សំ សារ៉ាក់

### ១.២.២. សម័យអាណានិគមបារាំង

យើងបានដឹងហើយថា បារាំងបានធ្វើសន្ធិសញ្ញាមួយនៅឆ្នាំ១៨៦៣ ដាក់ប្រទេសកម្ពុជាឱ្យនៅក្រោមអាណាព្យាបាលរបស់ប្រទេសបារាំង។[5] ចំពោះស្ថាប័នរដ្ឋបាលដែនដីត្រូវបានបញ្ជាក់នៅក្នុងកំណែទម្រង់ និងសន្ធិសញ្ញាដូចខាងក្រោមគឺៈ

- ➢ កំណែទម្រង់ព្រះរាជបញ្ញត្តិ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៨៧៧

នៅក្នុងបញ្ញត្តិទាក់ទងនឹងរដ្ឋបាល បានចែងថាៈ

- ទឹកដីខ្មែរទាំងមូល ត្រូវបែងចែកជា មណ្ឌលរដ្ឋបាលធំៗប្រាំ (ហៅថាកំណាន់ខេត្ត) ស្របតាមចំនួននៃរដ្ឋមន្ត្រីទាំងប្រាំ ដែលត្រូវគ្រប់គ្រងមណ្ឌលនីមួយៗ។ ចំនួនខេត្តត្រូវ បង្រួមពី៥៧ខេត្តមកនៅត្រឹមតែ៥០ខេត្តវិញ។
- អំណេះតទៅ ពួកមន្ត្រីត្រូវទទួលប្រាក់បៀវត្សន៍ដែលមានកម្រិតជាក់លាក់ ហើយត្រូវហាមឃាត់ការធ្វើជំនួញ។
- ពួកឧញ៉ាហ្លួង ដែលមានភារៈទៅត្រួតពិនិត្យមើលតាមខេត្តនានាត្រូវលប់ចោលព្រោះពួកនេះបានទាញយកប្រយោជន៍ពីព្រះរាជាផង និងពីប្រជារាស្ត្រផង។
- ម្យ៉ាងទៀតប្រជារាស្ត្រ មានសិទ្ធិជ្រើសរើស មេស្រុក មេឃុំ និងជំទប់របស់ខ្លួនដោយខ្លួនឯង។[6]

- ➢ អនុសន្ធិសញ្ញា បារាំង ខ្មែរ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ បានចែងថាៈ

- តាមមាត្រា៣ បានចែងថាៈ ក្នុងការគ្រប់គ្រងខេត្តដែលគ្រប់គ្រងដោយមន្ត្រីខ្មែរត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរបារាំង។
- តាមមាត្រា៤-៥បានចែងថាៈ រដ្ឋាភិបាលបារាំង មានសិទ្ធិអាចតែងតាំងរេស៊ីដង់និងរេស៊ីដង់រងបារាំងឱ្យត្រួតពិនិត្យមន្ត្រីខ្មែរនៅតាមបណ្តាខេត្តនានា និងនៅគ្រប់ទីកន្លែង ដែលបារាំងយល់ថាគួរដាក់។ មន្ត្រីបារាំងទាំងអស់នោះ ត្រូវស្ថិតក្រោមឱវាទរបស់រេស៊ីដង់ជាន់ខ្ពស់បារាំងម្នាក់ដែលអាចសុំធ្វើសវនាការជាមួយព្រះរាជាបានជានិច្ច។
- តាមមាត្រា៩ បានចែងថា ដីធ្លីក្នុងព្រះរាជាណាចក្រទាំងមូលពីដើមជាកម្មសិទ្ធិផ្តាច់មុខរបស់ព្រះរាជា ឥឡូវពួកអាជ្ញាធរបារាំង និងអាជ្ញាធរខ្មែរ អាចរៀបចំឱ្យមានកម្មសិទ្ធិឯកជនលើដីធ្លីនេះបាន។

---

[5] សៀវភៅ ប្រវត្តិស្ថាប័នខ្មែរ សាស្ត្រាចារ្យ ពៅ សាវឿន បោះពុម្ពឆ្នាំ២០១៥ ទំព័រ១១២

[6] សៀវភៅ ប្រវត្តិស្ថាប័នខ្មែរ សាស្ត្រាចារ្យ ពៅ សាវឿន បោះពុម្ពឆ្នាំ២០១៥ ទំព័រ១១២

- តាមមាត្រា១០ បានចែងថាៈ ទីក្រុងភ្នំពេញ ត្រូវគ្រប់គ្រងដោយមន្ត្រីបារាំងម្នាក់ និងអមដោយក្រុម ប្រឹក្សាមួយ ដែលមានសមាជិក១៣នាក់ ក្នុងនោះមានជនជាតិបារាំង៦នាក់ ជនបរទេស៤នាក់ និងជនជាតិខ្មែរ៣នាក់។[7]

### ១.២.៣. សម័យក្រោយអាណានិគមបារាំង

ក្រោយពីបានទទួលឯករាជ្យមកដល់ឆ្នាំ១៩៧៥ បារាំងបានកាន់កាប់ប្រទេសខ្មែរជាង៩០ឆ្នាំទើបសុខចិត្តប្រគល់ឱ្យខ្មែរនូវឯករាជ្យភាពជាតិវិញនៅឆ្នាំ១៩៥៣ ដោយសារស្នាព្រះហស្តរបស់ព្រះបាទនរោត្តម សីហនុ ព្រះមហាក្សត្រខ្មែរ និងដោយសារការរួមសាមគ្គីរបស់ប្រជាពលរដ្ឋខ្មែ ប្រកបដោយសេចក្តីប្តេជ្ញាចិត្ត យ៉ាងមុតមាំ។ បារាំងដកចេញទៅមែនតែអ្វីៗដែលបារាំងបានបង្កើតហើយក្នុងវិស័យរដ្ឋបាល ព្រមទាំង រចនាសម្ព័ន្ធទាំងរបៀបធ្វើការក៏នៅបន្តជាប់ជានិច្ចក្នុងរបបសង្គមរាស្ត្រនិយម(ព្រះរាជាណាចក្រទី១) ក៏ដូច ជារបបសាធារណៈខ្មែរដែរ។

➢ **របបសង្គមរាស្ត្រនិយម (១៩៤៧-១៩៧០)**

រដ្ឋធម្មនុញ្ញទី១នៃប្រទេសកម្ពុជា នៅថ្ងៃទី៦ ឧសភា ឆ្នាំ១៩៤៧ បានបង្កើតជារដ្ឋរាជានិយម ដែលទទួលឥទ្ធិពលខ្លាំងពីប្រទេសបារាំង (ជាការចំលងពីរដ្ឋធម្មនុញ្ញបារាំងនៅឆ្នាំ១៩៤៦)។ ដូចនេះគ្មានអ្វីប្លែកទេកាលដែលរៀបចំដែនដីនៃប្រទេសកម្ពុជា បង្ហាញពីលក្ខណៈគោលការណ៍ដូចប្រទេសបារាំងប្រការកាន់តែច្បាស់ គឺប្រទេសកម្ពុជាបានជ្រើសរើសដូចប្រទេសបារាំងនូវការលាយបញ្ចូលគ្នានៃរូបមន្តចាត់តាំងដែនដី វិមជ្ឈការ ទទួលស្គាល់ស្វ័យភាពមួយចំនួននៅថ្នាក់ខេត្ត និង ថ្នាក់ឃុំ និងវិសហមជ្ឈការ (ការបែងអំណាច ចំពោះអ្នកតំណាងអំណាចកណ្តាល ទេសាភិបាល )។

**ខាងផ្នែករៀបចំរដ្ឋបាលដែនដី គេឃើញមានៈ**

- ភូមិភាគ៨ ដែលភូមិភាគនីមួយៗរួមមាន ខេត្តមួយ ឬច្រើន។ ភូមិភាគទាំងនោះមិន មែនជាមណ្ឌលរដ្ឋបាលឡើយ ប៉ុន្តែជាមណ្ឌលបោះឆ្នោតដោយធ្វើការបោះឆ្នោតជ្រើសតាំងអ្នកតំណាងម្នាក់តាមភូមិភាគនីមួយៗ
- ឱ្យចូលរួមក្នុងក្រុមប្រឹក្សាព្រះរាជអាណាណាចក្រ (ជាព្រឹទ្ធសភា នៅសម័យកាលនោះ)។
- ខេត្ត (Provinces) បែងចែកជាស្រុក (District) ហើយបែងចែកជាឃុំ (Communes)។

[7] សៀវភៅ ប្រវត្តិស្ថាប័នខ្មែរ សាស្ត្រាចារ្យ ពៅ សារឿន បោះពុម្ពឆ្នាំ២០១៥ ទំព័រ១១២

- ក្រុងភ្នំពេញមួយ រួមនិងអង្គការសភាប្រជាជនភ្នំពេញមួយដែល មានសមាជិក ៧រូប។ សភាក្រុងនេះរៀបចំសមត្ថកិច្ចដូចខេត្តដែរ ក្រុងបែងចែកជា៧សង្កាត់ដែលគ្រប់គ្រង ដោយប្រធានសង្កាត់ម្នាក់ តែងតាំងដោយប្រកាសនៃរាជប្រតិភូក្រុង។

យើងអាចសង្កេតឃើញថា វិមជ្ឈការនៅថ្នាក់ខេត្ត និង ថ្នាក់ឃុំ គឺអនុវត្តតាមសម័យកាល ខេត្តបង្កើតជាសមូហភាពដែនដីដោយរដ្ឋធម្មនុញ្ញជាគ្រឹះ (មាត្រា ៨៤-៨៥-៨៦ និង៨៧ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៤៧) រីឯថ្នាក់ឃុំគឺជាសមូហភាពមូលដ្ឋានដោយនីតិបញ្ញត្តិជាគ្រឹះ (ក្រមចុះថ្ងៃទី១ កក្កដា ១៩៥៩)។

ខេត្តមានសភាប្រជាជនខេត្តមួយ ដែលជ្រើសតាំងសំរាប់២ឆ្នាំ ដោយការបោះឆ្នោតសកល និង ចំពោះ។ អង្គការសម្រេចនេះ មានបេសកម្មការពារផលប្រយោជន៍ទូទៅរបស់សមូហភាព និងអនុវត្តការត្រួតពិនិត្យ ០១ ចំនួន ចំពោះអ្នកតំណាងនៃអំណាចកណ្តាល ទេសាភិបាល។ ដោយគួរឱ្យស្តាយដំណើរការនៃសភានេះ មិនអាចក្លាយ ទៅជាគោលការណ៍ ដែលទុកជាវិធាន ដែលគេសង្ឃឹមបានឡើយ។ ទំនាក់ទំនងរវាងទេសាភិបាល និងសភាប្រជាជនតែងតែកើតឡើងនូវបរិយាកាសអាប់អួរ និង ទំនាស់គ្នា។ ឃុំគឺជាសមូសភាពសាធារណៈនៃព្រះរាជាណាចក្រ។ យោងតាមក្រមឆ្នាំ ១៩៥៩ ឃុំមានលក្ខណៈនិតិបុគ្គល។ ក្នុងន័យនេះឃុំមាន សិទ្ធិ កម្មសិទ្ធិលើសង្ហារឹមទ្រព្យ និង អសង្ហារឹម មានសិទ្ធិភាតិសន្យា និង សិទ្ធិប្តឹង ទៅតុលាការ។

ក្នុងការគ្រប់គ្រង ឃុំរៀបចំអង្គការសំរាប់សម្រេចមួយ គឺក្រុមប្រឹក្សាឃុំ ជ្រើសតាំងសំរាប់៤ឆ្នាំ ដែលមានសមត្ថកិច្ចដូចក្រុមប្រឹក្សាឃុំនៅប្រទេសបារាំងបច្ចុប្បន្ន (ត្រួតពិនិត្យគ្រប់សកម្មភាពរបស់ឃុំ និងអំណាចនីតិប្រតិបត្តិ ដែលដឹកនាំដោយមេឃុំ ដែលជាតំណាងនៃរដ្ឋផង និងសមូហភាពផង។

ទាក់ទងនិងអាណាព្យាបាល ឃុំឋិតក្រោមការត្រួតពិនិត្យ ២គឺ ៖

- ទី១ : ពីតំណាងរដ្ឋអនុវត្តន៍ដោយប្រធានស្រុក និងទេសាភិបាល (ចៅហ្វាយខេត្ត ទៅ លើ បុគ្គល និងលិខិតទូទៅ។
- ទី២ : ពីសភាខេត្តអំពីថវិកា។[8]

➢ **របបសាធារណរដ្ឋខ្មែរ ( ១៩៧០-១៩៧៥ )**

ប្រទេសកម្ពុជា បានឆ្លងកាត់របបរាជានិយម ទៅរបបសាធារណៈនិយម ដែលបង្កើតឡើងក្រោយពីរដ្ឋប្រហា ១៩៧០។ រដ្ឋធម្មនុញ្ញនៅថ្ងៃទី ៣០ មេសា ១៩៧២ បញ្ចេញឱ្យឃើញយ៉ាងច្បាស់ក្រឡែតពីឥទ្ធិពលបារាំង និងអាមេរិកដែលទាក់ទងទៅនឹងច្បាប់ និង ការរៀបចំអំណាចរដ្ឋ។ រដ្ឋធម្មនុញ្ញគ្រោងទុកការបែងចែក ដែន ដីជាខេត្ត ក្រុង ឃុំ និង សង្កាត់ ដែលគ្រប់គ្រងទៅតាមលក្ខ័ណ្ឌ នៃច្បាប់អង្គការចាត់តាំង ក្នុងនោះគេឃើញមាន វិមជ្ឈការ

[8] សៀវភៅ ប្រវត្តិស្ថាប័នខ្មែរ រៀបរៀងដោយ សាស្ត្រាចារ្យ គឹម ណារិន ទំព័រទី៩-១០

នៅថ្នាក់ខេត្ត និង ថ្នាក់ឃុំ។ ប៉ុន្តែជារួម ការរៀបចំទាំងនេះ មិនអាចអនុវត្តន៍បានឡើយ ដោយស្ថានភាព សង្គ្រាម នៃប្រទេស។

ដោយដឹងថា រដ្ឋធម្មនុញ្ញ បានអនុម័តហើយ តែរដ្ឋាភិបាលមិនអាចត្រួតត្រាលើសពី ១ភាគ៤ នៃដែនដី ឡើយ ហើយត្រូវបិតក្នុងសង្គ្រាមឥតឈប់ឈរទៀត។ ដូចនេះការកំរិតរង្វង់របស់រដ្ឋធម្មនុញ្ញ ក្លាយជាឥតន័យ។[9]

## ១.៣. សញ្ញាណរដ្ឋបាលថ្នាក់ក្រោមជាតិ

### ១.៣.១. និយមន័យ

រដ្ឋបាលថ្នាក់ក្រោមជាតិសំដៅទៅលើ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

រាជធានី គឺជារដ្ឋបាលរាជធានីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី។ ខេត្ត គឺជារដ្ឋបាលខេត្តដែល ស្ថិតក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត។

ក្រុងគឺជារដ្ឋបាលក្រុងដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង។ ស្រុកគឺជារដ្ឋបាលស្រុកដែល ស្ថិតក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាស្រុក។ ខណ្ឌគឺជារដ្ឋបាលខណ្ឌដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ខណ្ឌ។ ឃុំគឺជារដ្ឋបាលឃុំដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ ហើយចំណែកឯសង្កាត់គឺជារដ្ឋបាល សង្កាត់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាសង្កាត់។[10]

### ១.៣.២. ចរិតលក្ខណៈ

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្តល់និងបម្រើសេវាសាធារណៈដល់ប្រជាពលរដ្ឋដូចជាការផ្តល់លិខិត អនុញ្ញាតអ្វី មួយ សេវាសន្តិសុខ សេវាយុត្តិធម៌ សេវាលើកកម្ពស់ពាណិជ្ជកម្ម វិនិយោគ សេវាហេដ្ឋារចនាសម្ព័ន្ធជាដើម ។

ការកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របទៅនឹងចរិតលក្ខណៈ នៃរដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទនីមួយៗ រួមមានការកែសម្រួលរដ្ឋបាលរាជធានីភ្នំពេញឱ្យមានរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងារតាមចរិតលក្ខណៈជារដ្ឋបាលក្រុងមេត្រូប៉ូលីតែន រដ្ឋបាលខេត្តឱ្យមានរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងារតាមចរិតលក្ខណៈជារដ្ឋបាលតំបន់ និងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ឱ្យមានរចនាស ម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងារតាមចរិតលក្ខណៈជារដ្ឋបាលមូលដ្ឋាន។ ការលើកកម្ពស់សមត្ថភាពគ្រប់គ្រងកិច្ច ការរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការពង្រឹង និងការកែលម្អប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធាន មនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។[11]

[9] សៀវភៅ ប្រវត្តិស្ថាប័នខ្មែរ, សាស្ត្រាចារ្យ គឹម ណារិន ទំព័រ១០-១១

[10] គេហៈទំព័រ https://www.khsearch.com/qna/24455

[11] គេហៈទំព័រ https://ncdd.gov.kh/national-program-kh/

### ១.៣.៣. វិមជ្ឈការ និងវិសហមជ្ឈការនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឱ្យមានគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ គោលនយោបាយរបស់រាជរដ្ឋាភិបាលនេះគឺជាការផ្ទេរការទទួលខុសត្រូវ និងធនធានដល់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ។ ជាដំបូងរាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ដោយដោះស្រាយតម្រូវការនៅតាមទីជនបទទទួលបានប្រសិទ្ធិភាពជាមួយនឹងជោគជ័យនេះ រាជរដ្ឋភិបាលបានពង្រីកគោលនយោបាយរបស់ខ្លួនដើម្បីឱ្យមានក្រុមប្រឹក្សាផ្សេងទៀតដែលត្រូវបោះឆ្នោតជ្រើសរើសឡើងនៅថ្នាកក្រោមជាតិ គឺនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌថែមទៀត។

ទិសដៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺដើម្បីពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន លើកកម្ពស់ការអភិវឌ្ឍមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។ វិមជ្ឈការ ត្រូវតែមានអាជ្ញាធរថ្នាក់ក្រោមជាតិមួយ ត្រូវបានបោះឆ្នោតជ្រើសរើសឡើង ដើម្បីជាមធ្យោបាយសម្រាប់អនុវត្តការងារ។ ជាគោលការណ៍ វិមជ្ឈការអាចអនុវត្តចំពោះរដ្ឋបាលនានានៅក្នុងថ្នាក់ក្រោមជាតិទាំងអស់ឱ្យតែរដ្ឋបាលទាំងនោះបោះឆ្នោតជ្រើសរើសឡើង។ នៅក្នុងវិមជ្ឈការ ក្រុមប្រឹក្សាជាប់ឆ្នោតត្រូវតែទទួលបាននូវការផ្ទេរធនធានចាំបាច់ ដើម្បីសម្រេច អនុវត្ត និងគ្រប់គ្រងនូវមុខងាររបស់ខ្លួន។ ធនធានទាំងនោះរួមមាន៖ ហិរញ្ញវត្ថុ បុគ្គលិក និងទ្រព្យសម្បត្តិចាំបាច់ ដើម្បីអនុវត្តន៍នូវមុខងារនីមួយៗ។[12]

## ១.៤. ការរៀបចំរដ្ឋបាលនៅថ្នាក់ក្រោមជាតិ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកទី១៣ មាត្រា១៤៥ ថ្មី បានចែងអំពីរដ្ឋបាលដែនដីក្នុងព្រះរាជាណាចក្រកម្ពុជា មានខេត្ត ក្រុង ស្រុក ខ័ណ្ឌ និងឃុំ សង្កាត់។[13]

រដ្ឋបាលខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាប័នចំណុះក្រសួងមហាផ្ទៃផ្ទាល់ និងជាតំណាងរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងដែនដីនៃខេត្ត ក្រុង មានវិសាលភាព និងសមត្ថភាពគ្រប់គ្រងលើវិស័យរដ្ឋបាល និងនយោបាយ ដើម្បីធានាថែរក្សាសន្តិសុខសាធារណៈ ការពារសិទ្ធិ សេរីភាព លើកតម្កើងកម្រិតជីវភាពរស់នៅឈានទៅអភិវឌ្ឍន៍លើគ្រប់វិស័យ។[14]

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ នៅក្នុងឆ្នាំ២០០២ និងឆ្នាំ២០០៩ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំឡើងវិញស្របតាម

[12] សៀវភៅ នីតិរដ្ឋបាលទូទៅ សាស្ត្រាចារ្យ ហៀង សាង បោះពុម្ពលើកទី៥ ឆ្នាំ២០១៩ ទំព័រទី ១៦៦

[13] មាត្រា១៤៥ថ្មី រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[14] សៀវភៅ, ប្រវត្តិស្ថាប័នខ្មែរ សាស្ត្រាចារ្យ ពៅ សាវឿន បោះពុម្ពឆ្នាំ២០១៥ ទំព័រទី២៣៤

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការ គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។[15]

បច្ចុប្បន្ន ប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានចែកចេញជាពីរប្រភេទគឺ៖

ប្រព័ន្ធរដ្ឋបាលខេត្ត ដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់ និង ប្រព័ន្ធរដ្ឋបាលមូលដ្ឋានដែលរួមមានប្រព័ន្ធ០២ថ្នាក់ និងប្រព័ន្ធ០៣ថ្នាក់

- ប្រព័ន្ធ០២ថ្នាក់៖ ស្រុក ឃុំ និងក្រុង សង្កាត់
- ប្រព័ន្ធ០៣ថ្នាក់៖ រាជធានី-ខណ្ឌសង្កាត់

តើរដ្ឋបាលខេត្ត និងរដ្ឋបាលមូលដ្ឋានមានលក្ខណៈខុសគ្នាដូចម្តេច?

រដ្ឋបាលខេត្ត ប្រទេសភាគច្រើនហៅថា "រដ្ឋបាលតំបន់" មានមុខងារសំខាន់ៗ០៣ គឺ៖

១. អនុវត្តមុខងារជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននៅថ្នាក់ជាតិក្នុងការគាំទ្រ និងសម្របសម្រួលរដ្ឋបាលមូលដ្ឋានក្នុងដែនដីរបស់ខ្លួន ទាំងរដ្ឋបាលទីប្រជុំជន(ក្រុង) និងជនបទ (ស្រុក ឃុំ និងសង្កាត់ក្នុងស្រុក)។ (តាមប្រព័ន្ធវិសហមជ្ឈការ)

២. អនុវត្តមុខងាររបស់ថ្នាក់ជាតិដែលថ្នាក់ជាតិធ្វើប្រតិភូកម្មពិសេសមុខងារពាក់ព័ន្ធសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ច្បាប់ យុត្តិធម៌សង្គម ឬមុខងារពាក់ព័ន្ធការអភិវឌ្ឍ ការផ្តល់សេវាសង្គម ដែលថ្នាក់ជាតិមិនទាន់ប្រគល់ឱ្យពេញលេញ។ (តាមប្រព័ន្ធវិសហមជ្ឈការ)

៣. អនុវត្តមុខងារក្នុងការផ្តល់សេវា និងការអភិវឌ្ឍ ដែលមានផលប៉ះពាល់ក្នុងក្របខ័ណ្ឌ ខេត្តទាំងមូល ហើយដែលមិនអាចរ៉ាប់រងអនុវត្តបានដោយរដ្ឋបាលមូលដ្ឋាន។ (តាមប្រព័ន្ធវិមជ្ឈការ)។[16]

រដ្ឋបាលមូលដ្ឋាន គឺជារដ្ឋបាលដែលនៅកៀក ឬនៅជាប់ផ្ទាល់ជាមួយប្រជាពលរដ្ឋដែលមាន លទ្ធភាពសមត្ថភាពក្នុងការផ្តល់សេវា និងការអភិវឌ្ឍបានឆាប់រហ័សជាងថ្នាក់ជាតិ មានប្រសិទ្ធភាព និងមានភាពឆ្លើយតបជាងថ្នាក់ជាតិ ចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋតាមមូលដ្ឋានខុសៗគ្នា។ ជាគោលការណ៍ និងជាបទពិសោធន៍អន្តរជាតិ ថ្នាក់ជាតិតែងតែផ្ទេរមុខងារទាំងមុខងារតាមប្រព័ន្ធវិមជ្ឈការ(ការប្រគល់) និងមុខងារតាមប្រព័ន្ធវិសហមជ្ឈការ(ការធ្វើប្រតិភូកម្ម) កាន់តែច្រើនឡើងៗ ឱ្យទៅរដ្ឋបាលមូលដ្ឋានដើម្បីបង្កិតសេវា និងការអភិវឌ្ឍឱ្យកៀកជិតនឹងប្រជាជន ពីព្រោះតម្រូវការក្នុង ជីវភាពប្រចាំថ្ងៃរបស់ប្រជាជនមានការកើនឡើងជារៀងរាល់ថ្ងៃ។[17]

---

[15] សៀវភៅ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា, ឧទ្ទេសនាមដោយ សម្តេចក្រឡាសហោម ស ខេង ឆ្នាំ២០១៧ ទំព័រ២៧

[16] សៀវភៅ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា, ឧទ្ទេសនាមដោយ សម្តេចក្រឡាសហោម ស ខេង ឆ្នាំ២០១៧ ទំព័រ២៨

[17] សៀវភៅ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា, ឧទ្ទេសនាមដោយ សម្តេចក្រឡាសហោម ស ខេង ឆ្នាំ២០១៧ ទំព័រ២៨

### ១.៤.១. អំពីរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាពដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។[18]

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ ការកំណត់ឈ្មោះខេត្ត និងការកំណត់ព្រំប្រទល់របស់រាជធានីភ្នំពេញ ត្រូវសម្រេចដោយព្រះរាជក្រឹត្យតាមសំណើររបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[19] ចំពោះការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ ការកំណត់ឈ្មោះក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចដោយអនុក្រឹត្យ តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[20]

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជានីតិបុគ្គលនៃនីតិសាធារណៈ។[21] នីតិបុគ្គលនីមួយៗ ត្រូវមានក្រុមប្រឹក្សាមួយជាតំណាងដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។[22]

### ១.៤.២. រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

❖ **ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោតអសកល ស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលហៅថា "**ក្រុមប្រឹក្សា**"។[23]

ក្រុមប្រឹក្សានីមួយៗមានអាណត្តិប្រាំ(០៥)ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ អាណត្តិរបស់ក្រុមប្រឹក្សាត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់។[24] ក្រុមប្រឹក្សាថ្មីមានប្រធានមួយ(០១)នាក់ ដែលជាបេក្ខជនស្ថិតនៅលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេនៅក្នុងក្រុមប្រឹក្សា។[25]

---

[18] មាត្រា២ ប្រកាសលេខ ០១៧ នស រកម ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
[19] មាត្រា៦ ប្រកាសលេខ ០១៧ នស រកម ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
[20] មាត្រា៧ ប្រកាសលេខ ០១៧ នស រកម ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
[21] មាត្រា៩ ប្រកាសលេខ ០១៧ នស រកម ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
[22] មាត្រា១០ ប្រកាសលេខ ០១៧ នស រកម ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
[23] មាត្រា១៤ ប្រកាសលេខ ០១៧ នស រកម ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
[24] មាត្រា១៥ ប្រកាសលេខ ០១៧ នស រកម ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
[25] មាត្រា១៧ ប្រកាសលេខ ០១៧ នស រកម ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រ និងកត្តាភូមិសាស្ត្រ ដូចជាក្រុមប្រឹក្សារាជធានីមានចំនួនសមាជិកមិនលើសពី២១រូប ក្រុមប្រឹក្សាខេត្តមានសមាជិកពី០៩ដល់២១រូប ក្រុមប្រឹក្សាក្រុងមានសមាជិកពី ០៧ ដល់១៥រូប និងក្រុមប្រឹក្សាស្រុកនិងក្រុមប្រឹក្សាខណ្ឌ មានសមាជិកពី ០៧ ដល់ ១៩ រូប។[26]

ការប្រជុំរបស់ក្រុមប្រឹក្សាមានពីរប្រភេទ ជាអាទិ៍ ការប្រជុំសាមញ្ញ ៖ ក្រុមប្រឹក្សាត្រូវប្រជុំសាមញ្ញយ៉ាងហោចណាស់ចំនួន ១២ ដង/ឆ្នាំ។ ការប្រជុំវិសាមញ្ញ ៖ ក្រុមប្រឹក្សាអាចប្រជុំវិសាមញ្ញ ៖ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានតាមការចាំបាច់ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬពិសេស។

កិច្ចប្រជុំ អាចដំណើរការបាន លុះត្រាតែមានវត្តមានសមាជិកមិនតិចជាងពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាទាំងមូល ។ ការអនុម័តដីកា និងសេចក្តីសម្រេចដែលមានសុពលភាព គឺត្រូវមានសម្លេងគាំទ្រលើសពីពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល។

ក្រុមប្រឹក្សានីមួយៗ មានកាតព្វកិច្ចបង្កើតគណៈកម្មាធិការពិគ្រោះយោបល់យ៉ាងតិចចំនួនបី ជាអាទិ៍ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ និងគណៈកម្មាធិការលទ្ធកម្ម។ ក្រុមប្រឹក្សានីមួយៗ អាចបង្កើតគណៈកម្មាធិការផ្សេងៗបន្ថែមទៀត ដើម្បីជួយការងាររបស់ខ្លួនតាមការចាំបាច់ ប៉ុន្តែមិនត្រូវមានតួនាទី ភារកិច្ច ត្រួតគ្នាជាមួយគណៈកម្មាធិការខាងលើនេះ ឡើយ។ ក្រុមប្រឹក្សា ជាអ្នកសម្រេចអំពីចំនួនសមាជិក អំពីការតែងតាំងប្រធាន អនុប្រធាន និងអំពីការកំណត់តួនាទី ភារកិច្ចសកម្មភាពរបស់គណៈកម្មាធិការនីមួយៗដែលខ្លួនបានបង្កើតឡើង។ ក្រុមប្រឹក្សា អាចតែងតាំងសមាជិកក្រុមប្រឹក្សា អភិបាល អភិបាលរង បុគ្គលិក ក្រុមប្រឹក្សាជាសមាជិក គណៈកម្មាធិការបាន ហើយអាចបញ្ឈប់សមាជិកណាម្នាក់វិញក៏បានដែរ។ គណៈកម្មាធិការនីមួយៗ ត្រូវរាយការណ៍អំពីសកម្មភាពរបស់ខ្លួនឱ្យបានទៀងទាត់ ជូនក្រុមប្រឹក្សា និងគណៈអភិបាល។[27]

- **គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាននូវគណៈអភិបាល។ គណៈអភិបាល រួមមានអភិបាល និងអភិបាលរងមួយចំនួន។[28] រាជធានីភ្នំពេញ មានគណៈអភិបាលយ៉ាងច្រើនចំនួន ០៧ រូប ខេត្តមានចំនួនពី ០៣ ទៅ ០៧ រូប ចំណែកក្រុង ស្រុក ខណ្ឌ មានចំនួនពី ០៣ ទៅ ០៥ រូប។ ចំនួនជាក់ស្តែងនៃគណៈអភិបាល សម្រាប់ខេត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[29]

[26] មាត្រា១៨ ប្រកាសលេខ ០១៧ នស រកម ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

[27] សៀវភៅ រដ្ឋបាលបាលសាធារណៈ, សាស្ត្រាចារ្យ ខាំ សុមករា បោះពុម្ពឆ្នាំ២០១៣ ទំព័រទី ៤១

[28] មាត្រា១៣៩ ប្រកាសលេខ ០១៧ នស រកម ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

[29] មាត្រា១៤០ ប្រកាសលេខ ០១៧ នស រកម ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

អភិបាលរាជធានី និងខេត្ត ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ រីឯអភិបាលរងរាជធានី ខេត្ត អភិបាលក្រុង ស្រុកខណ្ឌ ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។ ចំណែកអភិបាលរងក្រុង ស្រុក ខណ្ឌ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[30] ចំពោះ អាណត្តិរបស់អភិបាល អភិបាលរង មិនលើសពី ០៤ ឆ្នាំ ប៉ុន្តែ អាចតែងតាំង ០៤ ឆ្នាំទៀត សម្រាប់អាណត្តិទី២ នៅដែនសមត្ថកិច្ចដដែល(កន្លែងដដែល)។[31] គណៈអភិបាលជាសេនាធិការ (the Assistant ) ជាអ្នកអនុវត្តសេចក្តីសម្រេច និងជាអ្នកផ្តល់យោបល់ដល់ក្រុមប្រឹក្សា ដើម្បីឱ្យក្រុមប្រឹក្សាសម្រេចបាននូវការអនុវត្តមុខងារសិទ្ធិអំណាច និងភារ កិច្ចរបស់ខ្លួនស្របតាមច្បាប់។

- **នាយករដ្ឋបាល**

សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាននាយករដ្ឋបាលមួយរូប ដែលមានតួនាទីជាជំនួយការឱ្យក្រុមប្រឹក្សា និងគណៈអភិបាល។ រាជធានី មាននាយករងរដ្ឋបាលយ៉ាងច្រើនចំនួន ០៣ រូប ចំណែកឯ ខេត្ត ក្រុង ស្រុក ខណ្ឌ មាននាយករងរដ្ឋបាលយ៉ាងច្រើនចំនួន ០២ រូប ជាជំនួយ ការឱ្យនាយករដ្ឋបាល។ នាយករដ្ឋបាល និងនាយករង ត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផ្អែកតាមសំណើពីអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌយោងតាមការសម្រេចរបស់ក្រុមប្រឹក្សា នីមួយៗ។

### ១.៤.៣. អំពីឃុំ សង្កាត់

ឃុំ សង្កាត់នៅកម្ពុជា ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលបញ្ជាក់ពីលទ្ធិប្រជាធិបតេយ្យកម្រិតទាបបំផុតនៅថ្នាក់មូលដ្ឋាន។ គោលដៅនៃច្បាប់នេះ គឺកំណត់ការគ្រប់គ្រងតាមប្រព័ន្ធវិមជ្ឈការ។[32]

ឃុំ សង្កាត់ ជានីតិបុគ្គលនៃនីតិសាធារណៈ ដែលទទួលបានអំណាចដឹកនាំ និងគ្រប់គ្រង តាម រយៈការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ក្នុងក្របខណ្ឌនៃឃុំ សង្កាត់នីមួយៗ។ ឃុំសង្កាត់គ្រប់គ្រងកិច្ចការមូលដ្ឋានក្នុងដែនដីរបស់ខ្លួនដោយផ្អែកទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។[33]

[30] មាត្រា១៤១ ប្រកាសលេខ ០១៧ នស រកម ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

[31] មាត្រា១៤៧ ប្រកាសលេខ ០១៧ នស រកម ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

[32] មាត្រា១ សេចក្តីសម្រេចលេខ ០៤១/00៣ នស រកក ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់

[33] មាត្រា៥ សេចក្តីសម្រេចលេខ ០៤១/00៣ នស រកក ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់

ការបង្កើតការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំសង្កាត់ ក្នុងករណីមិនប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ត្រូវសម្រេចដោយអនុក្រឹត្យតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ តែក្នុងករណីដែលមានការប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ត្រូវសម្រេចដោយព្រះរាជក្រឹត្យតាមសំណើររបស់នាយករដ្ឋមន្ត្រីក្រសួង ផ្អែកលើសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[34]

### ១.៤.៤. រដ្ឋបាល ឃុំ សង្កាត់

- **ក្រុមប្រឹក្សាឃុំ សង្កាត់**

ក្រុមប្រឹក្សាឃុំសង្កាត់ ជាអង្គការតំណាងប្រជាពលរដ្ឋមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំសង្កាត់របស់ខ្លួន ក្រុមប្រឹក្សានេះ ជ្រើសរើសឡើងតាមការបោះឆ្នោតដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួន ហើយមានអាណត្តិ ០៥ ឆ្នាំ មានសមាជិកពីចំនួន ០៥ រូបទៅ ១១ រូប ទៅតាមភូមិសាស្ត្រ និងតាមប្រជាសាស្ត្ររបស់ឃុំ សង្កាត់នីមួយៗ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ចជាអធិបតីក្នុងសម័យប្រជុំនានាធានាឱ្យមានកិច្ចប្រជុំយ៉ាងតិច ០១ ដងក្នុងមួយខែ ព្រមទាំងរក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ។ ការប្រជុំត្រូវធ្វើជាសាធារណៈ និងមានលក្ខណៈប្រជាធិតេយ្យ ប៉ុន្តែអាចប្រជុំជាសម្ងាត់បាន។ ការប្រជុំរបស់ក្រុមប្រឹក្សាឃុំសង្កាត់ នឹងយកជាការបានលុះត្រាតែមានចំនួនលើសពីពាក់កណ្តាល នៃសមាជិកក្រុមប្រឹក្សាទាំងមូលចូលរួមការបោះឆ្នោត។ ការអនុម័តត្រូវធ្វើដោយសំឡេងភាគច្រើនដាច់ខាត នៃសមាជិកក្រុមប្រឹក្សាទាំងមូលដើម្បីសម្រេចបញ្ហាណាមួយដូចជា៖ អនុម័ត លើគម្រោងផែនការអភិវឌ្ឍន៍គម្រោងថវិកា បទបញ្ជាផ្ទៃក្នុង និងដីកាឃុំ សង្កាត់ ការកំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាន និងកម្រៃសេវាផ្សេងៗទៀត ព្រមទាំងកិច្ចការផ្សេង ទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ មានសេរីភាពក្នុង ការបញ្ចេញមតិ និងមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបាន សំដែងយោបល់ ឬបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បានឡើយ។

- **មេឃុំ ចៅសង្កាត់**

មេឃុំ ចៅសង្កាត់បំពេញតួនាទី ភារកិច្ចអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងបទបញ្ញត្តិគោលការណ៍ដែលបានទទួលពីក្រុមប្រឹក្សាឃុំ សង្កាត់។ មេឃុំ ចៅ សង្កាត់ ត្រូវធ្វើ សេចក្តីរាយការណ៍ អំពីសកម្មភាពការងារឱ្យបានយ៉ាងតិចមួយដងក្នុងមួយខែ និងផ្តល់យោបល់ផ្សេងៗ ព្រមទាំងជួយដល់ក្រុមប្រឹក្សាឃុំ

---

[34] មាត្រា៦ សេចក្តីសម្រេចលេខ ០៤១/00៣ នស រកក ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់

សង្កាត់ ក្នុងការរៀបចំផែនការហិរញ្ញវត្ថុ ការចាត់ចែងអនុ វត្ត នូវតួនាទី មុខងារ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ រួមទាំងអនុវត្តកិច្ចការផ្សេងទៀតដែល ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនប្រគល់ឱ្យ។[35]

❖ **ជំទប់ ចៅសង្កាត់រង**

ជំទប់ ឬចៅសង្កាត់រង ជាជំនួយការរបស់មេឃុំ ចៅសង្កាត់ ក្នុងការអនុវត្តភារកិច្ចដែលមឃុំ ចៅសង្កាត់ប្រគល់ឱ្យ និងជំនួសមេឃុំ ចៅសង្កាត់តាមឋានានុក្រម នៅពេលដែលមេឃុំ ចៅសង្កាត់ អវត្តមាន។

ជំទប់ទី១ ឬចៅសង្កាត់រងទី១ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រីឯ ជំទប់ទី២ ឬ ចៅសង្កាត់រង ទី២ ទទួលជួយមេឃុំ ចៅសង្កាត់ លើកិច្ចការរដ្ឋបាលសង្គមកិច្ច សេវាសាធារណៈ និងសណ្តាប់ធ្នាប់។ ក្រៅពីនេះ មេឃុំ ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមទៀត។

❖ **ស្មៀន និងមេភូមិ**

ស្មៀន ជាមន្ត្រីស្ថិតនៅក្នុងក្របខណ្ឌលេខារដ្ឋបាល នៃក្រសួងមហាផ្ទៃ ដែលត្រូវទៅធ្វើ ការនៅតាមសាលាឃុំ សង្កាត់ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ស្មៀនឃុំ សង្កាត់ ត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលំអៀងក្នុងការងាររបស់ខ្លួន និងត្រូវផ្តល់ សមភាពដល់ប្រជាពលរដ្ឋទាំងអស់ និងដល់សមាជិកក្រុមប្រឹក្សាទាំងអស់ ស្មៀនឃុំសង្កាត់ ទទួលខុសត្រូវដោយផ្ទាល់ និងជាប្រចាំចំពោះក្រុមប្រឹក្សាឃុំសង្កាត់របស់ខ្លួន ទទួលខុសត្រូវចំពោះ រដ្ឋមន្ត្រីមហាផ្ទៃ និង អាជ្ញាធររដ្ឋ។

ស្មៀនឃុំ សង្កាត់ ត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលំអៀងក្នុងការងាររបស់ខ្លួន និងត្រូវផ្តល់ សមភាពដល់ប្រជាពលរដ្ឋទាំងអស់ និងដល់សមាជិកក្រុមប្រឹក្សាទាំងអស់ ស្មៀនឃុំសង្កាត់ ទទួលខុសត្រូវដោយផ្ទាល់ និងជាប្រចាំចំពោះក្រុមប្រឹក្សាឃុំសង្កាត់របស់ខ្លួន ទទួលខុសត្រូវចំពោះ រដ្ឋមន្ត្រីមហាផ្ទៃ និង អាជ្ញាធររដ្ឋ។

មេភូមិ ភូមិ គឺជាកន្លែងប្រមូលផ្តុំដោយផ្ទះ និងគ្រួសារប្រជាពលរដ្ឋជាច្រើន។ ភូមិ នីមួយៗ ត្រូវបានគ្រប់គ្រងដោយមេភូមិ និងអនុប្រធានភូមិម្នាក់។ មេឃុំចៅសង្កាត់ ជំទប់ ចៅ សង្កាត់រង ជាអ្នកជ្រើសរើសបេក្ខជនមេភូមិ ក្នុងមួយភូមិយ៉ាងតិច ០៣ រូប ដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់បោះឆ្នោត។ អ្នកដែលទទួលបានការគាំទ្រលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានធ្វើជាមេភូមិ។ បន្ទាប់ពីបានទទួលការគាំទ្ររួចហើយទើបមេភូមិនោះជ្រើសរើសអនុ ប្រធានម្នាក់និងសមាជិកដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ បោះឆ្នោតតាមសម្លេងភាគច្រើន។[36]

[35] សៀវភៅ រដ្ឋបាលបាលសាធារណៈ, សាស្ត្រាចារ្យ ខាំ សុមករា បោះពុម្ពឆ្នាំ២០១៣ ទំព័រទី ៥០

[36] សៀវភៅ រដ្ឋបាលបាលសាធារណៈ, សាស្ត្រាចារ្យ ខាំ សុមករា បោះពុម្ពឆ្នាំ២០១៣ ទំព័រទី ៥១

# ជំពូកទី២
# ដំណើរការនៃការប្រព្រឹត្តទៅរបស់
# រដ្ឋបាលថ្នាក់ក្រោមជាតិ

# ជំពូកទី២
# ដំណើរការនៃការប្រព្រឹត្តទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

## ២.១. ទិដ្ឋភាពទូទៅនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

បច្ចុប្បន្នកម្ពុជាមានរាជធានី-ខេត្ត ចំនួន២៥ ក្រុងចំនួន២៧ ស្រុកចំនួន១៦២ ខណ្ឌចំនួន១៤ ឃុំចំនួន១,៤០៥ សង្កាត់ចំនួន២៤១ និងភូមិចំនួន១៤,៣៩៤។ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាពដើម្បី បង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយ រិមជ្ឈការ និងវិសហមជ្ឈការ។[37]

- ❖ **រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ**

**បច្ចុប្បន្ន**




[37] គេហៈទំព័រ http://m.freshnewsasia.com/index.php/en/localnews/151347-2020-03-12-11-19-38.html

## ❖ រចនាសម្ព័ន្ធរដ្ឋបាលរាជធានី ខេត្ត




រចនាសម្ព័ន្ធរដ្ឋបាលរាជធានី ខេត្ត មានដូចទៅនឹងគំនូសបំព្រួញខាងលើ ដែលចែកចែញជា ក្រុមប្រឹក្សាភិបាល ដែលកើតចេញពីការបោះឆ្នោតអសកល បន្ទាប់មកគឺគណៈអភិបាល ជាអ្នកធ្វើការសម្រេចលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។ នាយករដ្ឋបាល ជាជំនួយការឱ្យក្រុមប្រឹក្សា និងគណៈអភិបាលក្នុងការចាត់ចែងកិច្ចការរដ្ឋបាលផ្សេង។

❖ រចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុកខណ្ឌ




❖ រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់




**<u>សម្គាល់</u>**៖ ភូមិ ពុំមែនជាថ្នាក់រដ្ឋបាលនោះឡើយ។ ភូមិ គឺជាភ្នាក់ងាររបស់ឃុំ សង្កាត់ ដែលត្រូវបានបង្កើតឡើងក្នុងគោលដៅសម្រាប់បម្រើឱ្យការគ្រប់គ្រងប្រជាពលរដ្ឋ និងជាអ្នកអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងភូមិនីមួយ។

## ២.២. រចនាសម្ព័ន្ធភារៈនារ

តាមរយៈការធ្វើប្រតិភូកម្មអំណាច អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ត្រូវបំពេញការងារក្នុងនាមជាភ្នាក់ងារដែលត្រូវបានតែងតាំងឱ្យគ្រប់គ្រងដឹកនាំនៅរដ្ឋបាលថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនោះ។ ដោយឡែកមេឃុំ ចៅសង្កាត់ ត្រូវបានតែងតាំងដោយការបោះឆ្នោតជាសាកលដែលមានអាណត្តិ ៥ឆ្នាំ។

### ២.២.១. រចនាសម្ព័ន្ធភារៈនារ របស់រដ្ឋបាលរាជធានី ខេត្ត

រដ្ឋបាលរាជធានី ខេត្ត ត្រូវដឹកនាំ គ្រប់គ្រងដោយក្រុមប្រឹក្សារាជធានី ខេត្ត។ ក្រុមប្រឹក្សា មានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា គឺដើម្បីសម្រេចគោលបំណងក្នុងការបង្កើត ការជម្រុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ។ ក្រុមប្រឹក្សាមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិរបស់ខ្លួនដោយការធ្វើដីកា។ ដីការបស់ក្រុមប្រឹក្សា មានវិសាលភាពដើម្បីកំណត់ ដើម្បីហាមឃាត់ ឬដើម្បីត្រួតពិនិត្យលើសកម្មភាព លើនីតិវិធី ឬកិច្ចការណាមួយដែលស្ថិតក្នុងវិសាលភាពនៃមុខងារ។ សិទ្ធិអំណាចខាងប្រតិបត្តិ ក្រុមប្រឹក្សាត្រូវបំពេញតួនាទី និងភារកិច្ចចម្បងក្នុងការធ្វើសេចក្តីសម្រេចក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចនេះត្រូវបានអនុវត្តយ៉ាងត្រឹម។[38]

អំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិទាំងអស់ ដែលក្រុមប្រឹក្សារាជធានីខេត្តបានសម្រេចរួចហើយគណៈអភិបាលរាជធានីត្រូវទទួលខុសត្រូវ នៅក្នុងការចាត់ចែងអនុវត្តក្នុងនាមក្រុមប្រឹក្សារាជធានីរបស់ខ្លួន។ ដូច្នេះគណៈអភិបាលរាជធានី គឺជាអ្នកអនុវត្តទាំងសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិរបស់ក្រុមប្រឹក្សារាជធានីខេត្ត។ ក្រុមប្រឹក្សារាជធានី ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយគណៈអភិបាលរាជធានី ដើម្បីធានាថាគណៈអភិបាលរាជធានី អនុវត្តកិច្ចការទាំងនោះបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុនានា និងការសម្រេចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត។[39]

គណៈអភិបាលរាជធានីខេត្តត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារាជធានីខេត្ត រៀងរាល់កិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សារាជធានីខេត្ត។ គណៈអភិបាលរាជធានីខេត្ត ត្រូវមានគណៈនេយ្យភាពចំពោះក្រុមប្រឹក្សារាជធានីខេត្តរបស់ខ្លួនអំពីការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សារាជធានី និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

[38] មាត្រា ៣០-៣២-៥៤ ប្រកាសលេខ ០១៧ នស រកម ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

[39] សៀវភៅ សេចក្តីផ្តើមរដ្ឋបាលសាធារណៈ, សាស្ត្រាចារ្យបណ្ឌិត សឿន សោភ័ណ បោះពុម្ពឆ្នាំ ២០២១ ទំព័រទី១១១

អភិបាលរាជធានីខេត្ត មាននាយករដ្ឋបាលសាលារាជធានីខេត្ត ជាជំនួយការ។ នាយករដ្ឋបាល មានភារកិច្ចរៀបចំ និងដាក់ជូនគណៈអភិបាលនូវវិធានការ និងគោលការណ៍ក្នុងការអនុវត្តដីកា និងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា និងពិនិត្យ សម្រេចនូវកិច្ចការរដ្ឋបាលប្រចាំថ្ងៃ។ រៀបចំសេចក្ដីព្រាងរបៀបវារៈ ឯកសារ ខ្លឹមសារ និងកិច្ចការនានាសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សា ព្រមទាំងធ្វើកំណត់ហេតុកិច្ចប្រជុំក្រុមប្រឹក្សា ធានាក្នុងការទទួល និងបែងចែកលិខិតស្នាម ឯកសារនានាឱ្យបានត្រឹមត្រូវ។ រក្សាទុកដាក់ឱ្យបានត្រឹមត្រូវ និងគង់វង្សនូវឯកសារ និងលិខិតបទដ្ឋាន គ្រប់គ្រង និងប្រើប្រាស់ត្រារដ្ឋបាលខេត្ត។ គណៈអភិបាល អាចធ្វើប្រតិភូកម្មដល់នាយករដ្ឋបាលឱ្យលើកយោបល់លើកិច្ចការណាមួយដែលស្ថិតក្នុងវិសាលភាពនៃតួនាទី ភារកិច្ចរបស់ខ្លួនដើម្បីគណៈអភិបាលពិនិត្យសម្រេចតាមការចាំបាច់៖ ចាត់ចែងកិច្ចការរដ្ឋបាល ធានានិរន្តភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាល។ ដោយមានការដឹកនាំ ណែនាំពីគណៈអភិបាល នាយករដ្ឋបាលត្រូវធានា ឱ្យនាយកទីចាត់ការមន្ត្រីបុគ្គលិកទាំងអស់ អនុវត្តការងារឱ្យបានត្រឹមត្រូវតាមច្បាប់នីតិវិធីនានា និងការសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាល។[40]

សាលារាជធានីខេត្ត គឺជាការិយាល័យធ្វើការរបស់ក្រុមប្រឹក្សា និងគណអភិបាលរាជធានីខេត្តហើយមានទីចាត់ការមួយចំនួនជាចំណុះ ដែលស្ថិតនៅក្រោមការគ្រប់គ្រងដឹកនាំផ្ទាល់ដោយនាយករដ្ឋបាល។ ទីចាត់ការនីមួយៗមាននាយកទីចាត់ការមួយ(០១)រូប និងនាយករងទីចាត់ការពីរ(០២)រូប ដែលទទួលខុសត្រូវដោយផ្ទាល់ចំពោះនាយករដ្ឋបាល។ ទីចាត់ការនីមួយៗមានការិយាល័យមួយចំនួនចំណុះ ដែលដឹកនាំដោយប្រធានមួយ(០១)រូប និងអនុប្រធានពីរ(០២)រូប។ ការិយាល័យនីមួយៗមានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការ និងទទួលខុសត្រូវដោយផ្ទាល់ចំពោះនាយកទីចាត់ការរបស់ខ្លួន និងចំពោះនាយករដ្ឋបាលនៃសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌរបស់ខ្លួន។ ទីចាត់ការនៃសាលារាជធានី ខេត្តរួមមាន ទីចាត់ការរដ្ឋបាល ទីចាត់ការផែនការ និងវិនិយោគ ទីចាត់ការហិរញ្ញវត្ថុ ទីចាត់ការរៀបចំក្រុង ទីចាត់ការគ្រប់គ្រងធនធានមនុស្ស ទីចាត់ការអន្តរវិស័យ ទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស និងទីចាត់ការគ្រប់គ្រងកាកសំណល់។

### ២.២.២. រចនាសម្ព័ន្ធការងារ របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

រចនាសម្ព័ន្ធការងារ របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក៏មិនខុសគ្នាទៅនឹងរចនាសម្ព័ន្ធការងាររបស់រដ្ឋបាលរាជធានី ខេត្តដែរ។ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវដឹកនាំ និងគ្រប់គ្រងដោយក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ។ ក្រុមប្រឹក្សាមានសិទ្ធិអំណាចធ្វើសេចក្ដីសម្រេចខាងបញ្ញត្តិ និងសិទ្ធិអំណាចធ្វើសេចក្ដីសម្រេចខាងប្រតិបត្តិ ក្រុមប្រឹក្សា

[40] សៀវភៅ សេចក្ដីផ្ដើមរដ្ឋបាលសាធារណៈ, សាស្ត្រាចារ្យបណ្ឌិត សឿន សោភ័ណ បោះពុម្ពឆ្នាំ ២០២១ ទំព័រទី១១២

ក្រុង ស្រុក ខណ្ឌ ត្រូវប្រើប្រាស់អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ខ្លួនដោយផ្អែកតាមគោលការណ៍ បែបបទ និងនីតិវិធីដែលកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌបានសម្រេចរួចហើយ គណៈអភិបាលក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវចាត់ចែងអនុវត្តក្នុងនាមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌរបស់ខ្លួន។ ដូច្នេះ គណៈអភិបាលក្រុង ស្រុក គឺជាអ្នកអនុវត្តទាំងសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីធានាថា គណៈអភិបាលក្រុង ស្រុក ខណ្ឌអនុវត្តកិច្ចការទាំងនោះបានត្រឹមត្រូវ តាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការសម្រេចរបស់ក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ។ គណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌរបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។

គណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌរបស់ខ្លួនអំពីការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។ អភិបាល ក្រុង ស្រុក ខណ្ឌ មាននាយករដ្ឋបាលសាលា ក្រុង ខណ្ឌជាជំនួយការ។ នាយករដ្ឋបាល ត្រូវរៀបចំសេចក្តីរាយការណ៍អំពីសកម្មភាព និងលទ្ធផលនៃការ អនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាល និងតំណាងក្រសួង ស្ថាប័ននានា ព្រមទាំងស្ថានភាពនៃការងារទាំងនោះ ក្នុងរបាយការណ៍ ប្រចាំខែ ត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំដើម្បីរាយការណ៍ជូនក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌរបស់ខ្លួន។ នាយករដ្ឋបាល ត្រូវធានាឱ្យការិយាល័យ មន្ត្រីបុគ្គលិកទាំងអស់អនុវត្តការងារបានត្រឹមត្រូវទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត នីតិវិធីនានា និងតាមការសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌរបស់ខ្លួន។

សាលាក្រុង ស្រុក ខណ្ឌ គឺជាការិយាល័យធ្វើការរបស់ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ។ សាលាក្រុង ស្រុក ខណ្ឌ មានការិយាល័យមួយចំនួនចំណុះ ដែលស្ថិតនៅក្រោមការដឹកនាំគ្រប់គ្រងដោយនាយករដ្ឋបាល។ ការិយាល័យនីមួយៗត្រូវមានការទទួលខុសត្រូវចំពោះនាយករដ្ឋបាលនៃសាលាក្រុង ស្រុក ខណ្ឌ។

ការិយាល័យចំណុះចាំបាច់របស់សាលាក្រុង ស្រុក ខណ្ឌមាន៖ ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ គឺជាសេនាធិការឱ្យក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌលើកិច្ចការសំខាន់ៗដូចជា៖ ការងាររដ្ឋបាល លិខិតស្នាមផ្សេងៗ ទំនាក់ទំនងសាធារណៈ និងការងារពិធីការ ការងារស្ថិតិប្រជាពលរដ្ឋ និងការងារអត្រានុកូលដ្ឋាន។ ការងារបុគ្គលិក ក្របខ័ណ្ឌ បៀវត្ស និងកម្រៃផ្សេងៗរបស់មន្ត្រី បុគ្គលិកសាលាក្រុង ស្រុក ខណ្ឌ សហការរៀបចំនីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ និងល័ក្ខខណ្ឌការងាររបស់មន្ត្រី បុគ្គលិកសាលាក្រុង ស្រុក ខណ្ឌ។

ទទួល និងបែងចែកលិខិតស្នាម ឯកសារនានាឱ្យបានត្រឹមត្រូវដល់សមាជិកក្រុមប្រឹក្សា អភិបាល ស្រុក ខណ្ឌ និងអភិបាលរងក្រុង ស្រុក ខណ្ឌ ព្រមទាំងក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ការិយាល័យជំនាញ និងអ្នកពាក់ព័ន្ធ។ សិក្សា និងលើកយោបល់ទាក់ទងនឹងការពិនិត្យនីត្យានុកូលភាព នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ និងសង្កាត់នានាក្នុងក្រុង ស្រុក ខណ្ឌ។

ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ អនុវត្តលើកិច្ចការសំខាន់ៗដូចជាៈ សិក្សា និងរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់ក្រុង ស្រុក ខណ្ឌ រួមទាំងសមាសភាគនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់ក្រុមប្រឹក្សាប្រភេទរួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នា ក្រសួង ស្ថាប័ន មន្ទីរ ឬការិយាល័យ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធ អនុវត្តគម្រោង កម្មវិធីអភិវឌ្ឍន៍ សម្របសម្រួលកិច្ចសហប្រតិបត្តិ ការអភិវឌ្ឍន៍ និងការផ្តល់សេវារវាងឃុំ សង្កាត់នានាក្នុងស្រុក ក្រុង ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីវិភាគវាយតម្លៃដំណើរការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងក្រុង ស្រុក ខណ្ឌ។ សិក្សា វាយតម្លៃ និងលើកយោបល់អំពីសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងតម្រូវការគាំទ្រ ដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់ឃុំ សង្កាត់។ គាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការកសាង និងការអនុវត្តផែនការអភិវឌ្ឍ និងពិនិត្យរបាយការណ៍អនុវត្តផែនការអភិវឌ្ឍន៍របស់ ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

ការិយាល័យអន្តរវិស័យនៃសាលាក្រុង ស្រុក ខណ្ឌ មានកិច្ចការសំខាន់ៗដូចជាៈ សិក្សា និងលើកយោបល់ទៅលើការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ ឬបានផ្ទេរស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានកំណត់។ ការងារដីធ្លី និងសំណង់ ដែលរួមមានពាក្យសុំកាន់កាប់ដីធ្លី សាងសង់ រុះរើ ជួសជុល កែលម្អសំណង់នានា ការអនុវត្តមុខងារនិងភារកិច្ចនានាដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្ម ការងារសណ្តាប់ធ្នាប់សាធារណៈ កិច្ចការច្បាប់ និងសិទ្ធិមនុស្ស។ ការងារសម្រុះសម្រួល ផ្សះផ្សាទំនាស់ផ្សេងៗក្នុងដែនសមត្ថកិច្ចរបស់ក្រុង ស្រុក ខណ្ឌ ស្របទៅតាមច្បាប់ និងនីតិវិធីជាធរមាន។ ការងារសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ សាសនា និងការការពារបរិស្ថាន ធនធានធម្មជាតិ បេតិកភ័ណ្ឌ រមណីដ្ឋាន និងតំបន់ប្រវត្តិសាស្ត្រ ដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា។

### ២.២.៣. រចនាសម្ព័ន្ធភារៈងារ របស់រដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានប្រធាន ក្រុមប្រឹក្សាឃុំសង្កាត់ជាមេឃុំ ចៅសង្កាត់។[41] មេឃុំ ចៅសង្កាត់ មានជំនួយការពីររូបគឺ ជំទប់ទី០១ រូប និងជំទប់ទី២ រូប ឬចៅសង្កាត់រងទី១ មួយរូប និង ចៅសង្កាត់រងទី២ មួយរូប ហើយ មានសិទ្ធិចាត់ តាំងគណៈកម្មាធិការនានា ដែលអាចយក

[41] មាត្រា២៥ , សេចក្តីសម្រេចលេខ ០៤១/00៣ នស រកក ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់

សមាជិកក្រុមប្រឹក្សាឬអាចយកប្រជាពលរដ្ឋក្នុងឃុំសង្កាត់ឱ្យធ្វើជាប្រធានក៏បានដើម្បីផ្តល់យោបល់និងជួយកិច្ចការផ្សេងៗព្រមទាំងអាចជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋ តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងអាណត្តិដើម្បីជួយកិច្ចការរបស់ខ្លួនតាមសេចក្តីត្រូវការចាំបាច់។[42]

ឃុំ សង្កាត់មានស្មៀនឃុំសង្កាត់ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលមានភារកិច្ចជួយកិច្ចការ និងធានានិរន្តភាពកិច្ចការរដ្ឋបាល ក្នុងឃុំសង្កាត់ដូចជា គ្រប់គ្រងត្រា និងសំណុំឯកសារ ទទួលនិង បែងចែកលិខិតឱ្យបានត្រឹមត្រូវ ជួយរៀបចំកិច្ចប្រជុំធ្វើលិខិតអញ្ជើញ សេចក្តីព្រាងរបៀបវារៈប្រជុំ របាយការណ៍ឯកសារផ្សេងៗ ដើម្បីដាក់ជូន ក្រុមប្រឹក្សា ពិនិត្យពិភាក្សា និងសម្រេច ធ្វើសេចក្តីព្រាងកំណត់ហេតុប្រជុំផ្សេងៗ ផ្តល់ព័ត៌មាន និងយោបល់ដល់ក្រុមប្រឹក្សាជួយធ្វើសេក្តីសម្រេច និង អនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់ បិទផ្សាយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា លើក្តារខៀនព័ត៌មានជាសាធារណៈ ព្រមទាំងកត់ត្រា ថែរក្សាការពារចលនវត្ថុ និងអចលនវត្ថុជា ទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់។ ឃុំសង្កាត់នីមួយៗ មានមេភូមិម្នាក់សម្រាប់ភូមិនីមួយៗ ដែលជ្រើសរើសដោយក្រុមប្រឹក្សាឃុំ សង្កាត់។[43]

មេភូមិ មានភារកិច្ចដូចជា ទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងក្រុមប្រឹក្សា ផ្តល់ និងស្នើសុំយោបល់ និងរាយការណ៍រាល់បញ្ហាដែលទាក់ទងនឹងភូមិរបស់ខ្លួនដល់ក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ដើម្បីចាត់ចែងសម្របសម្រួលការងារ ឬផលប្រយោជន៍នៅក្នុងភូមិនីមួយៗ ព្រមទាំងអនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សា ឬមេឃុំ ចៅសង្កាត់ប្រគល់ឱ្យដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់ សាធារណៈ និងអភិវឌ្ឍសេដ្ឋកិច្ច សង្គមក្នុងភូមិ។

## ២.៣. ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ អនុវត្តការគ្រប់គ្រងតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ។

### ២.៣.១. ការគ្រប់គ្រងបែបវិសហមជ្ឈការ

វិសហមជ្ឈការ សំដៅទៅលើការធ្វើប្រតិភូកម្មការងារពីថ្នាក់ជាតិទៅឱ្យអង្គភាពថ្នាក់ក្រោមជាតិ ដទៃទៀត។ ឬក៏ន័យមួយទៀត វិសហមជ្ឈការគឺជាបច្ចេកទេសគ្រប់គ្រងរដ្ឋបាលមួយ ដែលអាជ្ញាធររដ្ឋបាលកណ្តាល រំលែកកិច្ចការមួយចំនួនទៅឱ្យអាជ្ញាធររដ្ឋបាលមូលដ្ឋានធ្វើការសម្រេចដោយខ្លួនឯងផ្ទាល់តាមការកំណត់ ហើយសម្រេចតាងនាមអាជ្ញាធររដ្ឋបាលកណ្តាល។[44]

---

[42] មាត្រា២៦ សេចក្តីសម្រេចលេខ ០៤១/០០៣ នស រកក ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់

[43] មាត្រា២៨ សេចក្តីសម្រេចលេខ ០៤១/០០៣ នស រកក ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់

[44] សៀវភៅ នីតិរដ្ឋបាលទូទៅ សាស្ត្រាចារ្យ ហៀង សាង បោះពុម្ពលើកទី៥ ឆ្នាំ២០១៩ ទំព័រទី ១៥៤

ដូច្នេះអាជ្ញាធរមូលដ្ឋាន ធ្វើការសម្រេចកិច្ចការចាំបាច់ និងបន្ទាន់ខ្លះៗនៅនឹងកន្លែង (មូលដ្ឋាន) ដោយមិនចាំបាច់សុំការអនុញ្ញាត ក្នុងការសម្រេចពីអាជ្ញាធររដ្ឋបាលកណ្តាលដូចមុនឡើយ ព្រោះអាជ្ញាធរមូលដ្ឋាននៅពេលនេះ ទទួលបានសិទ្ធិអំណាចក្នុងការសម្រេចតាមការកំណត់ឱ្យក្នុងលក្ខខណ្ឌដែលចែងច្បាស់លាស់ទៅហើយ។ ការគ្រប់គ្រងរដ្ឋបាលតាមប្រភេទនេះ គឺជាការគ្រប់គ្រងតាមឋានានុក្រមរដ្ឋបាលដែលអំណាចកណ្តាល បានផ្តល់ឱ្យរដ្ឋបាលក្រោមជាតិសម្រេចតាមលំដាប់ថ្នាក់រៀងៗខ្លួន។

ការរំលែកអំណាចកណ្តាលក្នុងការសម្រេចនេះ គេប្រើវិធីមួយហៅថាប្រតិភូកម្មដែលចែកចេញជាពីរគឺ៖

- **ប្រតិភូកម្មអំណាច៖** គឺជាការផ្ទេរសមត្ថកិច្ចមួយផ្នែកទៅឱ្យអាជ្ញាធររដ្ឋបាលទាំងឡាយនៅក្នុងឋានានុក្រមរដ្ឋបាលរបស់ខ្លួនប៉ុណ្ណោះ។ ប្រតិភូកម្មអំណាចនេះធ្វើទៅបាន លុះត្រាតែមានលិខិតបទដ្ឋានគតិយុត្តចែងប៉ុណ្ណោះ។ ប្រតិភូកម្មមិនពុំអាចធ្វើតាមការនឹកឃើញ ហើយក៏ពុំអាចធ្វើទាំងស្រុងដែរ។
- **ប្រតិភូកម្មហត្ថលេខា៖** គឺជាវិធីមួយដែលតាមរយៈនេះ អាជ្ញាធររដ្ឋបាលនីមួយៗបានប្រគល់ទៅឱ្យសហការីណាម្នាក់របស់ខ្លួននូវការចុះហត្ថលេខាជំនួសលើសេចក្តីសម្រេចខ្លះដែលនេះជាភាពងាយស្រួលមួយផ្នែកការងារគ្រប់គ្រងរដ្ឋបាល ដោយពុំចាំបាច់ធ្វើប្រតិភូកម្មអំណាចទៀតទេ។ សហការីនេះមិនអាចផ្ទេរការចុះហត្ថលេខាជំនួសទៅឱ្យជនទីបីបានឡើយ។ ប្រតិភូកម្មហត្ថលេខានេះ ត្រូវប្រគល់ឱ្យចំឈ្មោះបុគ្គលដែលជាសហការីដោយបញ្ជាក់ពីឋានៈ តួនាទីឱ្យបានច្បាស់លាស់ ហើយត្រូវធ្វើសាជាថ្មីបើមានការផ្លាស់ប្តូរបុគ្គល។[45]

ការធ្វើប្រតិភូកម្មហត្ថលេខា គឺមានតែលើការចុះហត្ថលេខាប៉ុណ្ណោះ ដោយគ្មានប៉ះពាល់ ដល់ការបែងចែកអំណាចទេ។ អាជ្ញាធរដែលផ្ទេរហត្ថលេខាអាចរក្សាសិទ្ធិចុះហត្ថលេខាវិញគ្រប់ពេលវេលា។

**សម្គាល់៖** ប្រតិភូកម្មហត្ថលេខានេះ គឺផ្ទេទៅឱ្យបុគ្គលណាម្នាក់ដើម្បីចុះហត្ថលេខាជួសនោះបុគ្គលដែលទទួលបានការផ្ទេរនេះមិនអាចផ្ទេរការចុះហត្ថលេខាបន្តទៅបុគ្គលផ្សេងទៀតបានទេ អាចផ្ទេរបានទៅបុគ្គលផ្សេងបានលុះត្រាតែមានការយល់ព្រមពីម្ចាស់ហត្ថលេខា។ ប្រតិភូកម្មហត្ថលេខានេះជាវិធីមួយមានភាពទន់ភ្លន់ជាងប្រតិភូកម្មអំណាចក្នុងការអនុវត្ត។

### ២.៣.២. ការគ្រប់គ្រងបែបវិមជ្ឈការ

វិមជ្ឈការ គឺសំដៅទៅលើការផ្ទេរនូវមុខងារ និងធនធានមួយចំនួនរបស់រដ្ឋាភិបាល ទៅឱ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដែលជាប់ឆ្នោតហើយក្រុមប្រឹក្សានេះត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន។ វិមជ្ឈការជាការផ្តល់នូវអំណាច និងឆន្ទានុសិទ្ធិពេញលេញដល់ក្រុមប្រឹក្សាដើម្បីធ្វើសេចក្តីសម្រេចចិត្តដែលឆ្លុះបញ្ចាំងពីសេចក្តី

[45] សៀវភៅ នីតិរដ្ឋបាលទូទៅ សាស្ត្រាចារ្យ ហៀង សាង បោះពុម្ពលើកទី៥ ឆ្នាំ២០១៩ ទំព័រទី ១៥៦-១៥៧

ត្រូវការ ផលប្រយោជន៍ និងតថភាពនៅមូលដ្ឋាន។ ប៉ុន្តែអំណាច និងឆន្ទានុសិទ្ធិដែលក្រុមប្រឹក្សាទទួលបានត្រូវមានដែនកំណត់។ វិមជ្ឈការ គឺមានគោលបំណងផ្តល់នូវសិទ្ធអំណាចនៅក្នុងការសម្រេចខាងផ្នែករដ្ឋបាល និងផ្នែកហិរញ្ញវត្ថុបានដោយពេញលេញ និងស្វយ័តដោយពុំចាំបាច់មានការអនុញ្ញាតពីអាជ្ញាធរណាមួយឡើយ។ លើកលែងតែមានអត្ថបទច្បាប់ដែលបង្កើតអង្គការសម្ព័ន្ធភាពដែនដីបានកំណត់ផ្សេងពីនេះ។

មានលក្ខខណ្ឌមួយចំនួន ដើម្បីចាត់ទុកជាប្រព័ន្ធវិមជ្ឈការបាន លុះត្រាតែ មានក្រុមប្រឹក្សា តំណាងឱ្យអាជ្ញាធរនៃអំណាចនៅថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សានេះកើតឡើងដោយការបោះឆ្នោតជាសកល ឬជាអសកល។ មានសិទ្ធរក្សាទុកនៅថវិកាដោយឡែករបស់ខ្លួនសម្រាប់បំរើការអភិវឌ្ឍន៍មូលដ្ឋាន។ មានសិទ្ធ និងអំណាចស្វយ័តក្នុងការសំរេចលើបញ្ហាអ្វីមួយក្នុងរង្វង់ដែនសមត្ថ កិច្ចរបស់ខ្លួន។ ការផ្តល់ស្វ័យភាពពីអំណាចរដ្ឋបាលកណ្តាលនេះនៅតែអមទៅដោយការត្រួតពិនិត្យខ្លាំង ឬតិចពីរដ្ឋអំណាចកណ្តាល ដែលការត្រួតពិនិត្យនេះគេហៅថាអាណាព្យាបាលដែលប្រែប្រួលទៅតាមស្ថានការណ៍នៃពេលវេលា។[46]

**២.៣.២.១. ការគ្រប់គ្រងរដ្ឋបាល**

ក្នុងការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ រាជរដ្ឋាភិបាលបានផ្ទេរទាំងស្រុង ឬផ្នែកណាមួយនៃសិទ្ធអំណាចឱ្យអាជ្ញាធរមូលដ្ឋានក្នុងការសម្រេច និងការទទួលខុសត្រូវសម្រាប់ការផ្តល់សេវាសាធារណៈចាត់ចែងការងារដើម្បីបម្រើផលប្រយោជន៍របស់មូលដ្ឋានខ្លួន។ វិមជ្ឈការ តម្រូវឱ្យរាជរដ្ឋាភិបាលលះបង់ និងផ្ទេរភាពជាម្ចាស់លើមុខងារសមស្របទៅឱ្យក្រុមប្រឹក្សាដែលជាប់ឆ្នោត។ មុខងារអាចមានអត្ថន័យច្រើនយ៉ាងមុខងារអាចជាសេវាដែលផ្តល់ឱ្យប្រជាពលរដ្ឋ។

លើសពីនេះទៅទៀត ក៏មានមុខងារដែលទាក់ទងនឹងវិស័យនានាដូចជា មុខងារធ្វើផែនការរៀបចំថវិកា ការធ្វើលទ្ធកម្មការត្រួតពិនិត្យ និងការវាយតម្លៃគ្រប់គ្រងបុគ្គលិក និងការចេញដីការជាដើម។ ការគ្រប់គ្រងរដ្ឋបាលក្នុងប្រព័ន្ធនេះ មានការទទួលស្គាល់នៅក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់ ដូចជាអំ ណាចរបស់ក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សុទ្ធតែជាអំណាចស្វ័យសម្រេចក្នុងដែន សមត្ថកិច្ចរបស់ខ្លួន ហើយមានការទទួលស្គាល់ដោយច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ចំណែកសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក៏មានការទទួលស្គ ល់ដោយច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់ដែរ។

---

[46]https://doungpiseth.files.wordpress.com/2011/07/e19e94e19f92e19e9ae19e96e19f90e19e93e19f92e19e92e19e82e19f92e19e9ae19e94e19f8be19e82e19f92e19e9ae19e84e19e9ae19e8ae19f92e19e8be19e94.pdf

### ២.៣.២.២. ការគ្រប់គ្រងហិរញ្ញវត្ថុ

ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងច្បាប់រៀបចំអង្គការបានតម្រូវឱ្យក្រុមប្រឹក្សាតាមប្រភេទនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិសមស្រប ដើម្បីក្រុមប្រឹក្សា អនុវត្តមុខងារ និងការទទួលខុសត្រូវនានាសំដៅឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ ដើម្បីធានាឱ្យក្រុមប្រឹក្សាគ្រប់គ្រងចាត់ចែងហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិដែលបានប្រគល់ឱ្យមានលក្ខណៈតម្លាភាព មានសុចរិតភាពខ្ពស់បំផុត និងមានគណនេយ្យភាពចំពោះមូលដ្ឋាន និងចំពោះរាជរដ្ឋាភិបាលអំពីវិធានការខាងផ្លូវច្បាប់ ច្បាប់រៀបចំអង្គការបានតម្រូវឱ្យមានច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្រុមប្រឹក្សាត្រូវធានាអនុវត្តតាមបទដ្ឋានវិធាន ប្រព័ន្ធ និងនីតិវិធីដែលទាក់ទងដល់ការរៀបចំការអនុម័ត និងការអនុវត្ត ថវិកា គណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ទ្រព្យសម្បត្តិ ព្រមទាំងការ ធ្វើសវនកម្មផ្ទៃក្នុង និងសវនកម្មផ្ទៃក្រៅទៅលើហិរញ្ញវត្ថុ និងថវិការបស់ក្រុមប្រឹក្សា។

ក្រុមប្រឹក្សា ត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុសាធារណៈដើម្បីជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនឹងដែលផ្តោតទៅលើតម្រូវការអភិវឌ្ឍសំខាន់ៗបំផុតរួមមាន៖

- តម្រូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំសម្រាប់ទទួលមុខងារភារកិច្ច និងធនធាន ថ្មី។
- សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋានរចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់។
- ការកាត់បន្ថយភាពក្រីក្រ។
- តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ និងកុមារ ក្រុមជនងាយរងគ្រោះដោយរួមបញ្ចូល ទាំងជនក្រីក្រ ជនជាតិដើមភាគតិច។[47]

ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុឱ្យមានតម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន។ រាជធានី ខេត្ត ក្រុង ស្រុក ត្រូវមានថវិកាផ្ទាល់របស់ខ្លួនដែលហៅកាត់ថា ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។ ខណ្ឌ និងសង្កាត់ចំណុះរាជធានី ត្រូវមានថវិការបស់ខ្លួននៅក្នុងថវិការបស់រាជធានី។ សង្កាត់ចំណុះក្រុង ត្រូវមានថវិការបស់ខ្លួននៅក្នុងថវិការបស់ក្រុង។ ក្រុមប្រឹក្សា ត្រូវអនុម័តក្របខ័ណ្ឌចំណាយរយៈពេលមធ្យមហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

---

[47] មាត្រា២៤៤ ប្រកាសលេខ ០១៧ នស រកម ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ក្នុងការគ្រប់គ្រង និងការអនុវត្តវគ្គគម្រោងថវិកាប្រចាំឆ្នាំ ត្រូវផ្អែកតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ ថវិកា ត្រូវរៀបចំឡើងដោយគោរពតាមគោលការណ៍សំខាន់ៗទាំងអស់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងត្រូវមានតុល្យភាពរវាងចំណូល និងចំណាយ។

ក្នុងការគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុ ក្រុមប្រឹក្សាត្រូវធានាអនុវត្តតាមបទដ្ឋាន វិធានប្រព័ន្ធ និងនីតិវិធីដែលបានកំណត់ទាក់ទងទៅនឹង៖

- ការរៀបចំ ការអនុម័ត និងការអនុវត្តថវិកា
- គណនេយ្យ និងរបាយការណ៍
- ទ្រព្យសកម្ម និងទ្រព្យអកម្ម
- តម្លាភាព និងគណនេយ្យភាព
- ការគ្រប់គ្រងៈ
    - ចំណូលផ្ទាល់
    - ចំណូលដែលចែករំលែកមូលនិធិផ្ទេរពីថវិកាជាតិ និងថ្លៃសេវាសម្រាប់អនុវត្តមុខងារជាភ្នាក់ងារក្នុងនាមក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ឡើយចំណូលពីប្រភពផ្សេងៗទៀត។
    - លទ្ធកម្មសាធារណៈ
- ការធ្វើសវនកម្មផ្ទៃក្នុង
- ការធ្វើសវនកម្មផ្ទៃក
- តម្រូវការផ្អែកហិរញ្ញវត្ថុសាធារណៈផ្សេងៗទៀត។

បទដ្ឋាន វិធាន ប្រព័ន្ធ និងនីតិវិធីសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដោយផ្អែកតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋដែលបាន ផ្ទេរមកឱ្យខ្លួន ឬដែលបានទទួលដោយមធ្យោបាយផ្ទាល់ខ្លួនផ្សេងទៀតឱ្យមានប្រសិទ្ធភាព។[48]

[48] សៀវភៅ ប្រវត្តិស្ថាប័នខ្មែរ, សាស្ត្រាចារ្យ ពៅ សារឿន បោះពុម្ពឆ្នាំ២០១៥ ទំព័រទី២៨៣-២៨៥

## ២.៤. មុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ជាគោលការណ៍ ការគ្រប់គ្រងតាមបែប វិមជ្ឈការ និងវិសហមជ្ឈការ គឺសំដៅដល់កិច្ចដំណើរការផ្ទេរមុខងារ សិទ្ធិអំណាច និងធនធានសមស្រប ទៅឱ្យស្ថាប័ន ឬអង្គភាព ដែលត្រូវបានធ្វើវិមជ្ឈការ នោះ។ ក្នុងន័យនេះ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបានកំណត់អំពី គោលការណ៍ និងដំណើរការក្នុងការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បី ធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានលទ្ធភាពសមស្របក្នុងការបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅមូលដ្ឋាន។

### ២.៤.១. ប្រភេទនៃមុខងារ

មុខងារដែលត្រូវផ្ទេរដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិរួមមានពីរប្រភេទ គឺមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើស។ ការផ្ទេរមុខងារទាំងនេះត្រូវធ្វើឡើងដោយប្រគល់ ឬដោយប្រតិភូកម្ម។

**ការប្រគល់មុខងារ៖** គឺជាការផ្ទេរភាពជាម្ចាស់នៃមុខងារ ការទទួលខុសត្រូវ អំណាច និងឆន្ទានុសិទ្ធិទាំងអស់ដែលចាំបាច់ ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារនោះ។ ក្នុងន័យនេះ មុខងារដែលបានផ្ទេរដោយប្រគល់ ពីថ្នាក់ជាតិឱ្យទៅប្រភេទក្រុមប្រឹក្សាណាមួយ ក្រុមប្រឹក្សានោះ នឹងក្លាយទៅជាម្ចាស់ក្នុងការគ្រប់គ្រង និងចាត់ចែងអនុវត្តមុខងារនោះ។ (មុខងារដែលផ្ទេរតាមប្រព័ន្ធវិមជ្ឈការ)

**ប្រតិភូកម្មមុខងារ៖** គឺជាការផ្ទេរនូវមុខងារ ការទទួលខុសត្រូវ អំណាច និងឆន្ទានុសិទ្ធិ ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារក្នុងនាមអាជ្ញាធរដែលធ្វើប្រតិភូកម្មដោយផ្អែកតាមតម្រូវការនៃប្រតិភូកម្មនោះ។ អាជ្ញាធរដែលបានធ្វើប្រតិភូកម្ម នៅតែរក្សាភាពជាម្ចាស់លើកិច្ចការដែលបានធ្វើប្រតិភូកម្មនោះ។[49] (មុខងារដែលផ្ទេរតាមប្រព័ន្ធសហវិមជ្ឈការ)

- <u>មុខងារជាកាតព្វកិច្ច</u>

មុខងារជាកាតព្វកិច្ច គឺជាមុខងារដែលមានលក្ខណៈជាតម្រូវការចាំបាច់ ហើយដែលត្រូវបានកំណត់ ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាស ជាសមត្ថកិច្ចរបស់អង្គភាព ឬស្ថាប័នជាក់លាក់ណាមួយ។ មុខងារជាកាតព្វកិច្ច ត្រូវភ្ជាប់ជាមួយនូវថវិកា ធនធានមនុស្ស និងសមត្ថភាពសមស្របដែលចាំបាច់ ដើម្បីអនុវត្តមុខងារនោះ។

ការផ្ទេរមុខងារជាកាតព្វកិច្ចឱ្យទៅប្រភេទក្រុម ប្រឹក្សាណាមួយ ត្រូវធ្វើឡើងដោយការប្រគល់ ប្រសិនបើមិនតម្រូវឱ្យមានការចូលរួមចំណែកជាប្រចាំ ពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល។ ផ្ទុយទៅវិញ ប្រសិនបើការផ្ទេរនោះ តម្រូវឱ្យមានការចូលរួមចំណែកជាប្រចាំពីក្រសួង ស្ថាប័នពាក់ព័ន្ធ ការផ្ទេរក្នុងករណីនេះ ត្រូវធ្វើឡើង

[49] សៀវភៅ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ, ក្រសួងមហាផ្ទៃ ឆ្នាំ២០១៨ ទំព័រទី៤៧

ដោយប្រតិភូកម្ម។ ទោះជាក្នុងករណីណាក៏ដោយ ក្រសួង ស្ថាប័នដែលផ្ទេរមុខងារនោះ ត្រូវផ្ទេរ ធនធានចាំបាច់ឱ្យដល់ប្រភេទក្រុមប្រឹក្សាដែលទទួលមុខងារនោះ ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្ត មុខងារដែលផ្ទេរនោះប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

❖ <u>មុខងារជាជម្រើស</u>

មុខងារជាជម្រើស គឺជាមុខងារដែលមិនមានលក្ខណៈជាកាតព្វកិច្ច ហើយដែលត្រូវបានកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាស។ ការផ្ទេរមុខងារជាជម្រើសដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលឱ្យទៅប្រភេទក្រុមប្រឹក្សាណាទមួយដែលសមស្រប ត្រូវធ្វើឡើងដោយប្រគល់។ ក្នុងការអនុវត្តមុខងារជាជម្រើស ក្រុមប្រឹក្សាត្រូវធ្វើការសម្រេចអំពីការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសដែលទទួលបាន ក្នុងកម្រិតអតិបរមានៃលទ្ធភាព និងធនធានដែលក្រុមប្រឹក្សាមាន។[50]

## ២.៤.២. គោលការណ៍នៃការផ្ទេរមុខងារ

ជាគោលការណ៍ ការផ្ទេរមុខងារត្រូវធ្វើឡើងដោយផ្សារភ្ជាប់ជាមួយនឹងការផ្ទេរធនធានចាំបាច់ និងត្រូវធ្វើឡើងដោយមានការគ្រោងទុក មានសនិទានភាព មានការសម្របសម្រួល ការពិគ្រោះយោបល់ មានតម្លាភាព និងមានការរំខានជាអប្បបរមាទៅលើប្រតិបត្តិការដែលកំពុងដំណើរការ។ មាត្រា២១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់អំពី វិស័យជាអាទិភាពសម្រាប់ការពិនិត្យមើលឡើងវិញដោយក្រសួង ស្ថាប័ន ថ្នាក់ជាតិ ដើម្បីកំណត់ថា មុខងារណាដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងមុខងារណាដែលត្រូវរក្សាទុកជាការទទួលខុសត្រូវរបស់ថ្នាក់ជាតិ។

វិស័យអាទិភាពទាំងនោះ រួមមាន៖

- កសិកម្ម
- អប់រំ
- ព្រៃឈើ ធនធានធម្មជាតិ និងបរិស្ថាន
- សុខាភិបាល អាហារូបត្ថម្ភ និងសេវាប្រជាជន រួមទាំងតម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ជនងាយរងគ្រោះ និងជនជាតិដើមភាគតិច
- ឧស្សាហកម្ម និងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច
- ការប្រើប្រាស់ដីធ្លី

[50] សៀវភៅ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ, ក្រសួងមហាផ្ទៃ ឆ្នាំ២០១៨ ទំព័រទី៤៧

- ការផលិត និងការចែកចាយអគ្គិសនី
- ការគ្រប់គ្រងទឹក
- ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយ សម្ភារៈចាំបាច់ ដើម្បីគាំទ្រ និងចាត់ចែងការទទួលខុសត្រូវទាំងនេះ
- តម្រូវការពិសេស ឬតម្រូវការដែលបានកំណត់ជាក់លាក់ សម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយគិតទាំងវិស័យទេសចរណ៍ តំបន់ប្រវត្តិសាស្ត្រ និងកេរដំណែលវប្បធម៌ផងដែរ។[51]

[51] សៀវភៅ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ, ក្រសួងមហាផ្ទៃ ឆ្នាំ២០១៨ ទំព័រទី៤៨

# ជំពូកទី៣
# ពិភាក្សា

# ជំពូកទី៣

# ពិភាក្សា

## ៣.១. ពិភាក្សាអំពីអំណាច រដ្ឋបាលថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានការរំលែកអំណាចពីរដ្ឋបាលកណ្ដាលក្នុងការអនុវត្តសិទ្ធិ ធ្វើសេចក្ដីសម្រេចផ្សេងៗ ក្នុងការបម្រើផលប្រយោជាពលរដ្ឋ នៅដែនសមត្ថកិច្ចរបស់ខ្លួន។

### ៣.១.១. ពិភាក្សាអំពីអំណាច រដ្ឋបាលរាជធានី ខេត្ត

រដ្ឋបាលរាជធានី ខេត្ត មានអំណាចជាតំណាងតំណាងរបស់រាជរដ្ឋាភិបាលក្នុងវិស័យនយោបាយ និងរដ្ឋបាលដូចជា ការចេញវិធានដែលវិធាននេះអាចអនុវត្តដោយបង្ខំបាន។ ឧទាហរណ៍ ការវាយកម្ទេចចោទនូវសំណង់អាគារដែលរំលោភនៅលើដីសាធារណៈជាសិទ្ធចេញវិធានរបស់រដ្ឋបាលនៅក្នុងមូលដ្ឋាននោះ។

អំណាចក្នុងការស្វែងរកយុត្តិធម៌ ដែលជាការសម្របសម្រួល ឬដោះស្រាយវិវាទ តាមមធ្យោបាយក្រៅប្រព័ន្ធតុលាការ។ ឧទាហរណ៍ ការអនុវត្តន៍ជាក់ស្ដែងរបស់ ឯកត្តម ម៉ៅ ធនិន ដែលជាអភិបាលខេត្តកំពត បានធ្វើការដោះស្រាយវិវាទជូនប្រជាពលរដ្ឋជាច្រើនករណី។ ជាប្រធានគណៈបញ្ជាការឯកភាពរាជធានីខេត្ត ដែលទទួលខុសត្រូវក្នុងការរក្សាសន្តិសុខ សណ្ដាប់ធ្នាប់ និងរបៀបរាបរយសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ផ្សព្វផ្សាយការអនុវត្ត តាមដាន ត្រួតពិនិត្យការអនុវត្តន៍កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ និងលិខិតបទដ្ឋាននានាជាក់ស្ដែងដូចជាការផ្សព្វផ្សាយអំពីការទប់ស្កាត់នៃការរាតត្បាលត្បាលជម្ងឺកូវីត ១៩ ទៅកាន់ប្រជាពលរដ្ឋនៅមូលដ្ឋានឱ្យបានដឹង និងចូលរួមក្នុងការទប់ស្កាត់ទាំងអស់គ្នា។ ផ្ដល់យោបល់លើការតែងតាំងប្រធានមន្ទីរ ស្ថាប័ននានាចំណុះរាជធានី ខេត្ត។ ចាត់វិធានការ ដើម្បីធានាថែរក្សាសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងភាពស្ងប់ស្ងាត់ជូនប្រជាពលរដ្ឋ។ អំណាចក្នុងការគ្រប់គ្រង និងប្រើប្រាស់ចលនទ្រព្យ និងអចលនទ្រព្យរបស់រាជធានី ខេត្ត។ អំណាចក្នុងការចេញលិខិតអនុញ្ញាត្តិឱ្យធ្វើពាណិជ្ជកម្ម សិប្បកម្ម និងអាជីវកម្មផ្សេងៗ។ សិទ្ធិតែងតាំង ផ្លាស់ប្ដូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិក្នុងនាមជាតំណាំងឱ្យរាជរដ្ឋាភិបាល។

### ៣.១.២. ពិភាក្សាអំពីអំណាច រដ្ឋបាលក្រុង ស្រុក ខណ្ឌ

រដ្ឋបាលក្រុង ស្រុក ខណ្ឌសិទ្ធិអំណាចធ្វើសេចក្ដីសម្រេចខាងបញ្ញា និងខាងប្រតិបត្តិ។ អំណាចខាងប្បញ្ញត្តិ គឺជាការធ្វើដីការ។ អំណាចប្រតិបត្តិ គឺជាការធ្វើសេចក្ដីសម្រេច ស្របតាមក្របខណ្ឌដែលកំណត់ដោយច្បាប់ និងលិខិត បទដ្ឋានគតិយុត្តនានា។ ដីកា គឺជាវិធានការខាងផ្លូវច្បាប់ដែលបានអនុម័តដោយក្រុមប្រឹក្សាហើយដែលត្រូវអនុវត្ត។ ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាអាចស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីដកហូត អភិបាល អភិបាលរងចេញពីមុខតំណែង ក្នុងករណីអភិបាល អភិបាលរងនោះមានករណីណាមួយដូច

ជាបាត់បង់លក្ខណសម្បត្តិជាអភិបាល អភិបាលរង អសមត្ថភាព បំពេញការងារ មិនបានល្អ មានបញ្ហាសុខភាព ឬ បាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមាន សមត្ថកិច្ច បោះបង់ចោលការងារ និងប្រព្រឹត្តខុស ឆ្គងពីក្រមសីលធម៌វិជ្ជាជីវៈ។ សិទ្ធអំណាច ចុះហត្ថលេខាលើលិខិតបទដ្ឋាន និងលិខិតរដ្ឋបាលនានាសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ និងការងារ ចាំបាច់ផ្សេងៗទៀត។ លើកសំណើបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាមួយចំនួនពាក់ព័ន្ធនឹងការងារគ្រប់គ្រងបុគ្គល។ អំណាចជាគណៈបញ្ជាការឯកភាពក្នុងការដឹកនាំសម្របសម្រួលមន្ទីរ ការិយាល័យពាក់ព័ន្ធនានា ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈក្នុងដែនសមត្ថកិច្ច។ អំណាចចំពោះសេវាសាធារណៈ ធ្វើសៀវភៅគ្រួសារ ធ្វើសំរង់លិខិតអត្រានុកូលដ្ឋាននិងចុះហត្ថលេខាលើលិខិតស្នាមមួយចំចំនួន ដែលឃុំ សង្កាត់បញ្ជូនមក និងជាភ្នាក់ងារបន្តទៅឱ្យសាលារាជធានី ខេត្ត ឬ មន្ទីរជុំវិញរាជធានី ខេត្ត។ សិទ្ធអំណាចនៅក្នុងការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ នៅតាមមណ្ឌលសេវាកម្មយុត្តិធម៌ដែលរាជរដ្ឋាភិបាលរៀបចំឱ្យមាននៅតាមមូលដ្ឋាន។

### ៣.១.៣. ពិភាក្សាអំពីអំណាច រដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំដោយក្រុមប្រឹក្សាឃុំ សង្កាត់។ រដ្ឋបាលឃុំ សង្កាត់មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ។

- អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ ស្តែងតាមរយៈដីកាឃុំ សង្កាត់ តាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់សម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឱ្យ។ ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តន៍តែនៅក្នុងរង្វង់ដែនដីរបស់ខ្លួនតែប៉ុណ្ណោះ។
- អំណាចប្រតិបត្តិរបស់ឃុំ សង្កាត់ មានន័យថារដ្ឋបាលឃុំ សង្កាត់មានសិទ្ធិអនុវត្តន៍សេចក្តីសម្រេចរបសខ្លួននៅក្នុងក្របខណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឱ្យ។ រដ្ឋបាលឃុំ សង្កាត់អាចធ្វើសកម្មភាពតែនៅក្នុងក្របខណ្ឌអំណាច តួនាទី និងមុខងារដែលច្បាប់បាន ប្រគល់ឱ្យតែប៉ុណ្ណោះ។ មានន័យថា រដ្ឋបាលឃុំ សង្កាត់មិនអាចធ្វើផ្ទុយពីគោលការណ៍ និងបញ្ញត្តិដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានាឡើយ។ រដ្ឋបាលឃុំ សង្កាត់ គ្មានអំណាចសម្រេចលើវិស័យៈ ព្រៃឈើ ប្រៃសណីយ៍ និងទូរគមនាគមន៍ ការពារប្រទេស សន្តិសុខជាតិ រូបិយ វត្ថុ នយោបាយក្រៅប្រទេស គោលនយោបាយសារពើពន្ធ និងវិស័យផ្សេងទៀត ដែលមានចែងនៅក្នុងច្បាប់ លិខិតបទដ្ឋានដែលពាក់ព័ន្ធ។

រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសម្រេចលើវិស័យដូចជាៈ ព្រៃឈើប្រៃសណីយ៍ និងទូរគមនាគមន៍ ការពារជាតិ សន្តិសុខជាតិ រូបិយវត្ថុ នយោបាយក្រៅប្រទេស គោលនយោបាយសារពើពន្ធ និងវិស័យផ្សេងទៀត ដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ។

## ៣.២. ចំណុចខ្លាំង ចំណុចខ្សោយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

### ៣.២.១. ចំណុចខ្លាំងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

នៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ យើងសង្កេតឃើញថាមានចំណុចខ្លាំងជាច្រើនដូចជា មានច្បាប់ស្ដីពីការគ្រប់គ្រង និងអនុវត្តក្នុងការផ្ដល់សេវាសាធារណៈ។ ការផ្ដល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិអាចជួយសម្រួលដល់ប្រជាពលរដ្ឋដែលមកទទួលសេវាមានភាពងាយស្រួល និងមានភាពឆាប់រហ័សនៅពេលដែលប្រជាពលរដ្ឋមកទទួលសេវានៅតាមមូលដ្ឋាន មួយវិញទៀតមន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិបានក៏បានជួយសម្រួលដល់ប្រជាពលរដ្ឋនៅពេលជួបប្រទះនៅបញ្ហាផ្សេងៗដូចជា សន្តិសុខសណ្ដាប់ធ្នាប់ ជួយជួសជុលផ្លូវថ្នល់នៅពេលមានបញ្ហាខូចផ្លូវ ជួយប្រជាពលរដ្ឋនៅពេលជួបគ្រោះទឹកជំនន់ និងបញ្ហាផ្សេងដែលបានកើតឡើងនៅតាមមូលដ្ឋាន។ ប្រជាពលរដ្ឋចំណាចថវិកាតិចនៅពេលមកទទួលសេវានៅការិយាល័យច្រកចេញចូលតែមួយ។

រដ្ឋបាលថ្នាក់ក្រោមជាតិកើតឡើងតាមរយៈការបោះឆ្នោតជាអសកល តាមរយៈគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលគោលនយោបាយនេះ គឺការផ្ទេរការទទួលខុសត្រូវ តួនាទី និងធនធានដល់ក្រុមប្រឹក្សាដែលជាប់ឆ្នោតនៅថ្នាក់ក្រោមជាតិ។ ចំណែកឯចំណុចខ្លាំងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនេះវិញគឺមាន៖

- រចនាសម្ព័ន្ធច្បាស់លាស់សម្រាប់ គ្រប់គ្រង និងអនុវត្តការងារ។
- កាត់បន្ថយការប្រើអំណាចជ្រុលហួសរបស់អាជ្ញាធរកណ្ដាលអាជ្ញាធរមូលដ្ឋានសម្រេចបញ្ហានៅនឹងកន្លែង ជួយសម្រួលដល់ជីវភាព និងកិច្ចការរបស់រាស្ត្រប្រជា ការងារមានភាពឆាប់រហ័ស ចំណេញពេលវេលា និងកាត់បន្ថយការចំណាយ។
- ធ្វើឱ្យមានលក្ខណៈប្រជាធិបតេយ្យដែល អនុវត្តនៅមូលដ្ឋាន គោលការណ៍ធ្វើឱ្យមានប្រជាធិបតេយ្យកាន់តែទូលំទូលាយដោយបើកឱកាសឱ្យមូលដ្ឋាន ចូលរួមដេញដោល និងបញ្ចេញទស្សនៈយោបល់។
- អនុញ្ញាតឱ្យជ្ញាធរមូលដ្ឋានអាចចេញសេចក្ដីសម្រេចផ្សេង ឬលិខិតបទដ្ឋាននានាដោយឡែកសម្រាប់គ្រប់គ្រង និងអភិវឌ្ឍមូលដ្ឋាន ដើម្បីលើកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែប្រសើរ។
- បណ្ដុះបណ្ដាលសមត្ថភាពស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យចេះទទួលខុសត្រូវ ចេះបំផុសគំនិតធ្វើផែនការអភិវឌ្ឍមូលដ្ឋានដោយគិតគូរពីប្រយោជន៍ទូទៅខ្ពស់ជាងប្រយោជន៍ផ្ទាល់ខ្លួន។
- ប្រជាពលរដ្ឋកាន់តែយល់ដឹងអំពីកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ក៏ដូចជាការអភិវឌ្ឍន៍មានការរីកចម្រើនលើគ្រប់វិស័យ និងឆ្លើយតបកាន់តែប្រសើរឡើង មានទំនុកចិត្តពីប្រជាពលរដ្ឋ ដោយមានការបិទផ្សាយជាសាធារណៈនូវតារាងតម្លៃសេវាធ្វើឱ្យមានតម្លាភាព និងទប់ស្កាត់បាននូវបញ្ហាអសកម្ម។

- ក្រុមការងារថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត និងអង្គាធរមូលដ្ឋាន បានសហការគ្នាអនុវត្តបានល្អទាំងការងាររៀបចំវេទិកា ការពន្យល់ ការបកស្រាយ បំភ្លឺ ក៏ដូចជាការប្រជុំបូកសរុប ដកពិសោធន៍ និងការប្រជុំដោះស្រាយកង្វល់ និងសំណូមពរ របស់ប្រជាពលរដ្ឋ។

### ៣.២.២. ចំណុចខ្សោយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

នៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ យើងក៏សង្កេតឃើញថាមានចំណុចខ្សោយមួយចំនួនដែរដូចជា ការផ្តល់អំណាចមកថ្នាក់មូលដ្ឋានច្រើនពេកធ្វើឱ្យអំណាចកណ្តាលបាត់បង់សមត្ថភាពក្នុងការផ្តល់សេវា និងធ្វើឱ្យអំណាចកណ្តាលមិនអាចក្តោបក្តាប់ព័ត៌មានបានទាំងស្រុងនោះទេ ដោយសារអំណាចមួយចំនួនបានផ្ទេរទៅឱ្យថ្នាក់មូលដ្ឋាន។ មួយវិញទៀត ការអនុវត្តន៍គោលការណ៍នៅទូទាំងប្រទេសមិនដូចគ្នាទេ ដោយអនុវត្តគោលការណ៍ទៅតាមតំបន់ផ្សេងៗគ្នា មានការប្រកួតប្រជែងនៅតាមតំបន់នីមួយៗ វាមានលក្ខណៈមិនដូចគ្នា នាំឱ្យប៉ះពាល់ដល់ប្រយោជន៍បុគ្គល ឬសមូហភាព និងបាត់បង់ឯកភាពជាតិដោយសារតែការអនុវត្តន៍វិធានការរដ្ឋបាលខុសពីខេត្ត ក្រុងមួយ ទៅខេត្ត ក្រុងមួយផ្សេងទៀត និងទំហំថវិការសម្រាប់គាំទ្រដល់ការអនុវត្តន៍សេវាសាធារណៈនៅមានកម្រិត។ សមត្ថភាពយល់ដឹងរបស់មន្ត្រីមូលដ្ឋាននៅមានកម្រិត ឬការខ្វះខាតធនធានមនុស្សនៅមូលដ្ឋានខ្លះ វាធ្វើឱ្យអាជ្ញាធរនៅមូលដ្ឋានរដ្ឋបាលថ្នាក់ក្រោមជាតិមិនអាចធ្វើការងារបានល្អ មិនចេះធ្វើការងារ ឬមិនចេះធ្វើផែនការការងារ ដែលនាំឱ្យលទ្ធភាពក្នុងការប្រើប្រាស់សេវារបស់ប្រជាពលរដ្ឋនៅតាមតំបន់មានភាពខុសគ្នា។ ខ្វះមធ្យោបាយ សម្រាប់ចុះបំពេញបេសកកម្ម។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

កាលណាគេនិយាយពីរដ្ឋបាលថ្នាក់ក្រោមជាតិ គឺគេសម្តៅដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ ការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាផ្នែកមួយដ៏សំខាន់ក្នុងការសម្រាលបន្ទុកការងាររបស់រដ្ឋបាលថ្នាក់ជាតិ ដោយតាមរយៈការផ្ទេរមុខងារ តួនាទីភារកិច្ច សិទ្ធអំណាច ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ អាចធ្វើការកាន់តែងាយស្រួល និងឆាប់រហ័ស។ យោងតាមច្បាប់ស្តីពី ការរៀបចំរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលថ្នាក់ក្រោមជាតិមាន ក្រុមប្រឹក្សារាជធានី ខេត្ត ដែលត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោតអសកល អភិបាលរាជធានី និងខេត្ត ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។ ចំណែកឯអភិបាលរងរាជធានី ខេត្ត អភិបាលក្រុង ស្រុកខណ្ឌ ត្រូវតែងតាំងដោយអនុក្រឹត្យ អភិបាលរងក្រុង ស្រុក ខណ្ឌ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នាយករដ្ឋបាល និងនាយករង ត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាឃុំ សង្កាត់ ជ្រើសរើសឡើងតាមការបោះឆ្នោតជាសកល ដោយប្រជា ពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ គឺមេឃុំ ចៅសង្កាត់ ដែលត្រូវធ្វើការគ្រប់គ្រង ដឹកនាំ និងបំពេញតួនាទី ភារកិច្ច នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលរាជរដ្ឋាភិបាលបានផ្ទេរមកឱ្យ។

តាមរយៈការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋបាលមូលដ្ឋានទទួលបាននូវស្វ័យភាពក្នុងការសម្រេចរដ្ឋបាល និងផ្នែកហិរញ្ញវត្ថុ តាមរយៈប្រព័ន្ធគ្រប់គ្រងរដ្ឋបាលបែបវិមជ្ឈការ និងវិសហមជ្ឈការ ដែលបម្រើដល់ការអភិវឌ្ឍន៍ និងតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។ រដ្ឋបាលមូលដ្ឋានបានធ្វើសកម្មភាពដើម្បីប្រយោជន៍ទូទៅ និងប្រជាពលរដ្ឋជាច្រើនដូចជា ផ្តល់នូវសេវាយុត្តិធម៌ ដែលជាការសម្របសម្រួល ឬដោះស្រាយវិវាទេ រក្សាសន្តិសុខ សណ្តាប់ធ្នាប់ ធ្វើការផ្សព្វផ្សាយពីច្បាប់ និងលិខិតបទដ្ឋាននានា។ ការផ្តល់សេវាសាធារណៈផ្សេងៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈសាមញ្ញ និងឆាប់រហ័ស ដែលបង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់សេវា។

ជារួមការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ ពិតជាផ្តល់នូវផលប្រយោជន៍ជាច្រើនដល់ប្រជាពលរដ្ឋ រួមទាំងរដ្ឋបាលមូលដ្ឋានផងដែរ។ រដ្ឋបាលមូលដ្ឋានទទួលបានសិទ្ធអំណាចពេញលេញ ដែលរាជរដ្ឋាភិបាលបានប្រគល់ឱ្យ ស្របទៅតាមច្បាប់បានកំណត់។ ចំពោះប្រជាពលរដ្ឋ ទទួលបាននូវសេវាសាធារណៈបានល្អប្រសើរជាងមុន តម្រូវការរបស់ប្រជាពលរដ្ឋនមូលដ្ឋាន ទទួលបាននៅការយកចិត្តទុកដាក់ និងការឆ្លើយតបមានភាពរហ័ស និងល្អប្រសើរជាងមុន ទទួលបាននូវការការពារ សុខសុវត្ថិភាព និងការអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួនបានប្រសើរ ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សាលើប្រធានបទ ការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ យើងខ្ញុំសង្កេតឃើញថារដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានសិទ្ធិអំណាចពីរដ្ឋបាលថ្នាក់ជាតិ ដើម្បីធ្វើការដឹកនាំ គ្រប់គ្រង នៅក្នុងមូលដ្ឋាន ដែលសម្រេចបាននូវសមិទ្ធផលជាជច្រើននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ប៉ុន្តែក៏នៅតែមានចំណុចខ្វះខាតមួយចំនួនដែលរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិគួរពិចារណា និងកែលម្អ មានដូចតទៅ៖

- បន្តកែសម្រួលយន្តការផ្ទេរថវិកាសម្រាប់ថ្នាក់ក្រោមជាតិដើម្បីឆ្លុះបញ្ចាំងនូវការផ្ទេរមុខងារ និងដើម្បីជំរុញការផ្តល់ថវិកាឱ្យបានកាន់តែច្រើនជាងមុនទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- ត្រូវរៀបចំ និងអនុវត្តកម្មវិធីកសាងសមត្ថភាពគ្រប់ជ្រុងជ្រោយ ដើម្បីលើកកម្ពស់សមត្ថភាពការដឹកនាំគ្រប់គ្រង និងជំនាញ
- ធ្វើការពង្រីក និងពង្រឹងការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានបច្ចុប្បន្នភាពសេវាសាធារណៈរបស់អង្គភាពទៅកាន់ប្រជាពលរដ្ឋឱ្យមានការយល់ដឹងកាន់តែច្រើន
- បង្កើនប្រសិទ្ធភាពលើការងារត្រួតពិនិត្យរដ្ឋបាលនៅក្នុងការគ្រប់គ្រងនៃដែនសមត្ថកិច្ចរបស់ខ្លួន
- បន្តធ្វើការលើកកម្ពស់ការអនុវត្តន៍នូវគោលការណ៍សំខាន់ៗនៃអភិបាលកិច្ចល្អដោយសារអភិបាលកិច្ចល្អបានរួមចំណែកយ៉ាងធំធេងក្នុងការលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។

# ឯកសារយោង

## ឯកសារយោង

- **ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**
  - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
  - ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២២ ឧសភា ២០០៨ ស្តីពីច្បាប់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង។
  - ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែឧសភា ២០០៨ ស្តីពីច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសារធារណៈ។
  - ព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី ៣១ ខែឧសភា ២០១១ ច្បប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិ។
  - អនុក្រឹត្យលេខ ៦២-អនក្រ-បក ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ។
  - សេចក្តីសម្រេចលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០១ស្តីពីច្បាប់ការគ្រប់គ្រងរដ្ឋបាលរដ្ឋបាលឃុំ សង្កាត់។
- **សៀវភៅនិងនិពន្ធ**
  - សៀវភៅ វិវាទរដ្ឋបាល បណ្ឌិត ទូ សុខុម៉ា ឆ្នាំសិក្សា ២០២២
  - សៀវភៅ នីតិរដ្ឋបាលទូទៅ បណ្ឌិត ថេង ច័ន្ទសង្វារ បោះពុម្ពឆ្នាំ ២០១០ ២០១៣
  - សៀវភៅ សេចក្តីផ្តើមរដ្ឋបាលសាធារណៈ បណ្ឌិត សឿន សោភ័ណ បោះពុម្ពឆ្នាំ ២០២១
  - សៀវភៅ នីតិរដ្ឋបាលទូទៅ សាស្ត្រាចារ្យ ហៀង សាង បោះពុម្ពឆ្នាំ ២០១៨
  - សៀវភៅ ប្រវត្តិស្ថាប័នខ្មែរ សាស្ត្រាចារ្យ ពៅ សារឿន បោះពុម្ពឆ្នាំ ២០១៥
  - សៀវភៅ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា, ក្រសួងមហាផ្ទៃ, ខែមករា ឆ្នាំ២០១៨
- **គេហទំព័រ**
  - https://doungpiseth.files.wordpress.com/2011/07/e19e94e19f92e19e9ae19e96e19f90e19e93e19f92e19e92e19e82e19f92e19e9ae19e94e19f8be19e82e19f92e19e9ae19e84e19e9ae19e8ae19f92e19e8be19e94.pdf
  - https://ncdd.gov.kh/national-program-kh/
  - https://www.khsearch.com/qna/24455
  - http://m.freshnewsasia.com/index.php/en/localnews/151347-2020-03-12-11-19-38.html

# ឧបសម្ព័ន្ធ

# ព្រះរាជក្រម

នស/រកម/០៥០៨/០១៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បាន អនុម័តកាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ នា សម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបាន ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ០៩៦/០០១/២០០៨ កបធ.ច ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៨ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១

## អំពីបទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងកំណត់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ២.-**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

**មាត្រា ៣.-**

ឃុំ សង្កាត់ត្រូវគ្រប់គ្រងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ លើកលែងតែបញ្ហាទាំងឡាយណាដែលបានចែងក្នុងច្បាប់នេះ ។

**មាត្រា ៤.-**

ភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

រាជធានីភ្នំពេញ ចែកជាខណ្ឌ ។

ខណ្ឌ ចែកជាសង្កាត់ ។

**មាត្រា ៥.-**

ខេត្ត ចែកជាក្រុង និងជាស្រុក ។

ក្រុង ចែកជាសង្កាត់ ។

ស្រុក ចែកជាឃុំ និងជាសង្កាត់ ។

**មាត្រា ៦.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការកំណត់ឈ្មោះខេត្ត ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ការកំណត់ព្រំប្រទល់រាជធានីភ្នំពេញ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការកំណត់ឈ្មោះក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៨.-**

ការបង្កើតរដ្ឋបាលឯកភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺសំដៅដល់ការពង្រឹងអង្គឯកភាពរបស់រដ្ឋ ដើម្បីសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនដីរបស់ខ្លួន ។

**មាត្រា ៩.-**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជានីតិបុគ្គលនៃនីតិសាធារណៈ ។

**មាត្រា ១០.-**

នីតិបុគ្គលនីមួយៗ ត្រូវមានក្រុមប្រឹក្សាមួយជាតំណាងដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើង ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

**មាត្រា ១១.-**

នីតិបុគ្គលនីមួយៗត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១២.-**

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរួមមាន :

-ភាពជាតំណាងសាធារណៈ

-ស្វ័យភាពរបស់មូលដ្ឋាន

-ការពិគ្រោះយោបល់ និងការចូលរួម

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL ·

-ការឆ្លើយតប និងគណនេយ្យភាព

-ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន

-ការលើកស្ទួយសមធម៌

-តម្លាភាព និងសុចរិតភាព

-វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច ។

**មាត្រា ១៣.-**

នីតិបុគ្គលទទួលសិទ្ធិអំណាចរបស់ខ្លួន ដោយរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដទៃទៀត ដែលស្របនឹងច្បាប់នេះ ។

## ជំពូកទី ២
## អំពីក្រុមប្រឹក្សា

### ផ្នែកទី ១
### ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**មាត្រា ១៤.-**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើសរើសឡើង តាមការបោះឆ្នោតអសកល ស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលហៅកាត់ថា "ក្រុមប្រឹក្សា" ។

**មាត្រា ១៥.-**

ក្រុមប្រឹក្សាមានអាណត្តិប្រាំ(០៥)ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

អាណត្តិរបស់ក្រុមប្រឹក្សា ត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

**មាត្រា ១៦.-**

ក្នុងពេលរង់ចាំក្រុមប្រឹក្សាថ្មីចូលកាន់មុខតំណែង ក្រុមប្រឹក្សាដែលចប់អាណត្តិមានសិទ្ធិអនុវត្តតែកិច្ចការរដ្ឋបាលប្រចាំថ្ងៃតែប៉ុណ្ណោះ ។

**មាត្រា ១៧.-**

ក្រុមប្រឹក្សានីមួយៗ ត្រូវមានប្រធានម្នាក់ ។

ប្រធានក្រុមប្រឹក្សា គឺជាបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេ នៅក្នុងក្រុមប្រឹក្សា ។

ក្នុងករណីដែលបញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា ត្រូវជ្រើសរើសយកបេក្ខជន ដែលមានលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានសំឡេងឆ្នោតបានការច្រើនជាងគេ ។

**មាត្រា ១៨.-**

ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រនិងកត្តាភូមិសាស្ត្រ ដូចខាងក្រោម ៖

-ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិកមិនលើសពីម្ភៃមួយ(២១)រូប

-ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពីប្រាំបួន(០៩)រូប ដល់ម្ភៃមួយ(២១)រូប

-ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំ(១៥)រូប

-ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំបួន(១៩)រូប ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងតិចមួយរយម្ភៃ (១២០)ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា ។

ក្នុងករណីគ្មានអនុក្រឹត្យ ចែងអំពីចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេនោះ ចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សា សម្រាប់ក្រុមប្រឹក្សានីមួយៗ ត្រូវយកតាមចំនួនសរុបដដែលនៃក្រុមប្រឹក្សាអាណត្តិចាស់ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL ·

**មាត្រា ១៩.-**

ក្រុមប្រឹក្សានីមួយៗត្រូវធ្វើជាតំណាង និងធ្វើសកម្មភាពក្នុងនាមប្រជាពលរដ្ឋទាំងអស់ ដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ២០.-**

ក្រុមប្រឹក្សានីមួយៗ ត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ២១.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបំពេញតាមលក្ខខណ្ឌ និងមានលក្ខណសម្បត្តិ ដូចខាងក្រោម :

-មានសញ្ជាតិខ្មែរពីកំណើត

-មានអាយុយ៉ាងតិចម្ភៃប្រាំ(២៥)ឆ្នាំ គិតមកដល់ថ្ងៃបោះឆ្នោត

-មានសិទ្ធិបោះឆ្នោត និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ តាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

**មាត្រា ២២.-**

សមាជិកក្រុមប្រឹក្សាម្នាក់ ត្រូវបាត់បង់សមាជិកភាពពីសមាជិកក្រុមប្រឹក្សាក្នុងករណីណាមួយ ដូចខាងក្រោម :

-សាមីខ្លួនបាត់បង់លក្ខណសម្បត្តិ និងលក្ខខណ្ឌ សម្រាប់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

-សាមីខ្លួនសុំលាឈប់ពីក្រុមប្រឹក្សា តាមការដាក់ពាក្យសុំលាឈប់ជាលាយលក្ខណ៍អក្សរទៅប្រធានក្រុមប្រឹក្សា

-សាមីខ្លួនទទួលមរណភាព

-សាមីខ្លួនមិនបានចូលរួមក្នុងកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាប់ៗគ្នា ចាប់ពីពីរ(០២)ដងឡើងទៅ ដោយគ្មានច្បាប់អនុញ្ញាត

-សាមីខ្លួនត្រូវបណ្តេញចេញពីសមាជិកក្រុមប្រឹក្សា អនុលោមតាមច្បាប់ នីតិវិធី ឬ បទបញ្ជាផ្ទៃក្នុង ឬ ក្រមសីលធម៌របស់ក្រុមប្រឹក្សា

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ

-សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសម្រេច និងប្រកាសពីការបាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ក្នុងករណីដូចខាងលើនេះ ។

**មាត្រា ២៣.–**

នៅពេលដែលមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវជ្រើសរើសបេក្ខជនលំដាប់លេខរៀងបន្ទាប់ ពីក្នុងបញ្ជីបេក្ខជនជាមួយមកជំនួស ក្នុងរយៈពេលយ៉ាងយូរដប់បួន(១៤)ថ្ងៃ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២៤.–**

ប្រសិនបើក្រុមប្រឹក្សាណាមួយអនុវត្តផ្ទុយពីបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់ក្រុមប្រឹក្សានោះឱ្យគោរព និងអនុវត្តបទប្បញ្ញត្តិទាំងនោះ នៅក្នុងអំឡុងពេលជាក់លាក់ និងសមហេតុផល ។

ក្នុងករណីក្រុមប្រឹក្សានោះនៅតែមិនព្រមអនុវត្តតាមការណែនាំ រាជរដ្ឋាភិបាលត្រូវរំលាយក្រុមប្រឹក្សានោះដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២៥.–**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត "គ.ជ.ប" ត្រូវរៀបចំការបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសក្រុមប្រឹក្សា ក្នុងករណីណាមួយដូចខាងក្រោម ៖

-ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបង្កើតថ្មីដូចមានចែងក្នុងមាត្រា ៦ និងមាត្រា ៧ នៃច្បាប់នេះ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរពីររយសែសិប (២៤០) ថ្ងៃ

-ក្រុមប្រឹក្សាដែលត្រូវរំលាយតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរមួយរយម្ភៃ(១២០)ថ្ងៃ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្រុមប្រឹក្សាដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះ មានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សានោះ ។

**មាត្រា ២៦.-**

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាមានរយៈពេលមិនលើសពីមួយរយប៉ែតសិប(១៨០)ថ្ងៃ ។

**មាត្រា ២៧.-**

ក្នុងករណីដែលមានក្រុមប្រឹក្សាណាមួយត្រូវរំសាយ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់វិធានការដើម្បីគ្រប់គ្រងជំនួសរហូតដល់មានក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

**មាត្រា ២៨.-**

សមាជិកក្រុមប្រឹក្សានៅក្នុងមុខតំណែង ត្រូវទទួលប្រាក់ឧបត្ថម្ភ ដែលត្រូវបើកចេញពីគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សានោះ ។

ប្រាក់ឧបត្ថម្ភខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ២
## តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

**មាត្រា ២៩.-**

ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មតាមច្បាប់នេះ ឬ ដែលស្របតាមច្បាប់នេះ ។

**មាត្រា ៣០.-**

ក្រុមប្រឹក្សា មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ ។

**មាត្រា ៣១.–**

ក្រុមប្រឹក្សា ត្រូវបំពេញមុខងារ និងភារកិច្ច ដោយធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចនោះត្រូវបានអនុវត្ត ។

**មាត្រា ៣២.–**

ក្រុមប្រឹក្សា ប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួនដោយការធ្វើដីកា ស្របទៅតាមបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី ៣ ជំពូកទី ២ នៃច្បាប់នេះ ។

**មាត្រា ៣៣.–**

ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចប្រតិបត្តិរបស់ខ្លួនដោយធ្វើសេចក្តីសម្រេច នៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា ។

**មាត្រា ៣៤.–**

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់អំពីជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្តីសម្រេច ធានាបានការអភិវឌ្ឍតាមបែបប្រជាធិប-តេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្រុមប្រឹក្សាអាចធ្វើការអង្កេតលើករណីទាំងឡាយណា ដែលខ្លួនយល់ឃើញថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង ព្រមទាំងអាចផ្សព្វផ្សាយលទ្ធផលនៃការធ្វើអង្កេតនោះ រួចហើយត្រូវផ្តល់គោលការណ៍ណែនាំអនុវត្តដល់គណៈអភិបាលនិងអភិបាល ។

**មាត្រា ៣៥.–**

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការប្រតិបត្តិតាមរដ្ឋ-ធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា ។

**មាត្រា ៣៦.–**

រៀងរាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាត្រូវធ្វើសេចក្តីសម្រេច ឬ ដីកាតាមការចាំបាច់ទាក់ទិនទៅនឹង :

-ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មី ស្របតាមច្បាប់នេះ

-មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា

-មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា

-កម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំ (៥) ឆ្នាំ រួមទាំងសមាសភាគនៃផែនការនោះ ដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សារួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា

-គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

-បញ្ហាហិរញ្ញវត្ថុផ្សេងទៀត

-ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងគណៈកម្មាធិការ អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា

-ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ

-ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋ

-កិច្ចការផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដែលបានធ្វើឡើងស្របតាមច្បាប់នេះ ។

**មាត្រា ៣៧.-**

ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍរយៈពេលប្រាំ(៥)ឆ្នាំ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ តាមការរៀបចំកម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ ។

**មាត្រា ៣៨.-**

ក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍ ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយ:

-ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ប្រភេទក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល

-អ្នកពាក់ព័ន្ធនានា ។

នីតិវិធីនៃការពិគ្រោះយោបល់នៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៣៩.–**

ក្រុមប្រឹក្សាត្រូវរៀបចំផែនការអភិវឌ្ឍ ដែលរួមមាន :

-ចក្ខុវិស័យរបស់ក្រុមប្រឹក្សា ដោយបង្ហាញពីគោលដៅ និងគោលបំណងសម្រាប់អភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

-ការប៉ាន់ប្រមាណពីកម្រិតនៃការអភិវឌ្ឍដែលមានស្រាប់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងការប៉ាន់ប្រមាណពីតម្រូវការអភិវឌ្ឍសំខាន់ៗរួមមាន :

+ តម្រូវការរបស់ក្រុមប្រឹក្សានៅក្នុងការរៀបចំទទួលយកនូវការផ្ទេរមុខងារ ភារកិច្ច និងធនធានថ្មីៗ

+ សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់នានា

+ ការកាត់បន្ថយភាពក្រីក្រ

+ តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ក្រុមជនងាយរងគ្រោះ រួមទាំងជនក្រីក្រ ជនជាតិដើមភាគតិច ។

-ក្របខ័ណ្ឌអភិវឌ្ឍដែលត្រូវចែងអំពីគោលការណ៍ណែនាំជាមូលដ្ឋានក្នុងការប្រើប្រាស់ និងគ្រប់គ្រងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិនៅតំបន់នោះ

-ផែនការគ្រប់គ្រងគ្រោះមហន្តរាយ

-ផែនការហិរញ្ញវត្ថុ ដោយត្រូវរាប់បញ្ចូលទាំងផែនការអភិវឌ្ឍមូលធន ការគ្រោងថវិកាសម្រាប់រយៈពេលដប់ពីរ (១២) ខែ ចាប់ពីពេលរៀបចំផែនការ និងសម្រាប់រយៈពេលបី (៣) ឆ្នាំចាប់ពីពេលរៀបចំផែនការ ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ

-យុទ្ធសាស្ត្រអនុវត្តផែនការអភិវឌ្ឍ ដើម្បីធានាឱ្យមានតម្លាភាពនិងគណនេយ្យភាព ចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL

-សូចនាករបំពេញការងារសំខាន់ៗ និងគោលដៅនានាទាក់ទិននឹងអាទិភាព និងទិសដៅអភិវឌ្ឍនីមួយៗដូចមានចែងក្នុងផែនការអភិវឌ្ឍ

ក្រុមប្រឹក្សាត្រូវកំណត់ឱ្យដាច់ពីគ្នានៅក្នុងផែនការអភិវឌ្ឍ និងថវិកានូវមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ។

បែបបទ នីតិវិធីជាក់ស្តែងនៃការរៀបចំ ការគ្រប់គ្រង និងការអនុវត្តផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៤០.-**

ក្រុមប្រឹក្សា ត្រូវតាមដាន និងវាយតម្លៃជាទៀងរាល់ឆ្នាំ ទៅលើការអនុវត្តផែនការអភិវឌ្ឍរបស់ខ្លួន ដោយរាប់ទាំងផ្នែកនៃផែនការអភិវឌ្ឍដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ :

-ក្រុមប្រឹក្សាប្រភេទរួមគ្នា

-ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត

-ក្រសួង ស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាល

-អ្នកពាក់ព័ន្ធនានា។

**មាត្រា ៤១.-**

ក្រុមប្រឹក្សា ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់នូវផែនការអភិវឌ្ឍបន្ទាប់ពីបានអនុម័តរួចហើយភ្លាម ។

សាធារណជន អាចពិនិត្យឯកសារផែនការនេះ នៅការិយាល័យរបស់ក្រុមប្រឹក្សាដោយឥតគិតថ្លៃ ឬ អាចស្នើសុំជាវឯកសារផែនការនេះពីក្រុមប្រឹក្សា ដោយគិតត្រឹមតម្លៃដើម ។

**មាត្រា ៤២.-**

ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុសាធារណៈ ដើម្បីជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងដែលផ្តោតទៅលើតម្រូវការអភិវឌ្ឍសំខាន់ៗបំផុតរួមមាន :

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

-តម្រូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំសម្រាប់ទទួលមុខងារ ភារកិច្ច និងធនធានថ្មីៗ

-សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់

-ការកាត់បន្ថយភាពក្រីក្រ

-តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ និងកុមារ ក្រុមជនងាយរងគ្រោះដោយរួមបញ្ចូលទាំងជនក្រីក្រ ជនជាតិដើមភាគតិច ។

**មាត្រា ៤៣.-**

ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុ ឱ្យមានតម្លាភាព និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន ។

**មាត្រា ៤៤.-**

រាជធានី ខេត្ត ក្រុង ស្រុក ត្រូវមានថវិកាផ្ទាល់របស់ខ្លួន ដែលហៅកាត់ថាថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ។

ខណ្ឌ និងសង្កាត់ចំណុះរាជធានី ត្រូវមានថវិការបស់ខ្លួននៅក្នុងថវិការបស់រាជធានី ។

សង្កាត់ចំណុះក្រុង ត្រូវមានថវិការបស់ខ្លួននៅក្នុងថវិការបស់ក្រុង ។

ក្រុមប្រឹក្សាត្រូវអនុម័តលើថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមនីតិវិធីនិងប្រតិទិននៃការកសាងថវិការដ្ឋជារៀងរាល់ឆ្នាំ ។

ក្រុមប្រឹក្សាត្រូវអនុម័តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ។

ការគ្រប់គ្រងនិងការអនុវត្តគម្រោងថវិកាប្រចាំឆ្នាំ ត្រូវផ្អែកតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

ថវិកាត្រូវរៀបចំឡើងដោយគោរពតាមគោលការណ៍សំខាន់ៗទាំងអស់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតែមានតុល្យភាពរវាងចំណូល និងចំណាយ ។

**មាត្រា ៤៥.-**

ក្នុងការគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុ ក្រុមប្រឹក្សាត្រូវធានាអនុវត្តតាមបទដ្ឋាន វិធាន ប្រព័ន្ធ និងនីតិវិធី ដែលបានកំណត់ទាក់ទិនទៅនឹង :

-ការរៀបចំ ការអនុម័ត និងការអនុវត្តថវិកា

-គណនេយ្យ និងរបាយការណ៍

-ទ្រព្យសកម្ម និងទ្រព្យអកម្ម

-តម្លាភាព និងគណនេយ្យភាព

-ការគ្រប់គ្រង :

+ ចំណូលផ្ទាល់

+ ចំណូលដែលចែករំលែក មូលនិធិផ្ទេរពីថវិកាជាតិ និងថ្លៃសេវាសម្រាប់អនុវត្តមុខងារជាភ្នាក់ងារក្នុងនាមក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល

+ ចំណូលពីប្រភពផ្សេងៗទៀត ។

-លទ្ធកម្មសាធារណៈ

-ការធ្វើសវនកម្មផ្ទៃក្នុង

-ការធ្វើសវនកម្មផ្ទៃក្រៅ

-តម្រូវការផ្នែកហិរញ្ញវត្ថុសាធារណៈផ្សេងៗទៀត ។

បទដ្ឋាន វិធាន ប្រព័ន្ធ និងនីតិវិធីសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដោយផ្អែកតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៤៦.-**

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

សម្បត្តិរដ្ឋដែលបានផ្ទេរមកឱ្យខ្លួន ឬ ដែលបានទទួលដោយមធ្យោបាយផ្ទាល់ខ្លួនផ្សេងទៀតឱ្យមានប្រសិទ្ធភាព ។

នីតិវិធីនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៤៧.-**

ក្នុងករណីដែលមានការរំលោភអំណាចកើតមានឡើង នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាត្រូវមានភារកិច្ចរាយការណ៍ជាលាយល័ក្ខណ៍អក្សរជាបន្ទាន់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៨.-**

ការរំលោភអំណាចកើតឡើងនៅពេលដែលអ្នកជាប់ឆ្នោតណាម្នាក់ ឬ អ្នកដែលបានទទួលការតែងតាំងនៅក្នុងក្រសួង ស្ថាប័ន ឬ ភ្នាក់ងាររបស់រដ្ឋ ឬ ក្នុងក្រុមប្រឹក្សាណាមួយ ឬ ជនណាម្នាក់ ដែលបានប្រព្រឹត្តអំពើដោយចេតនា ហើយដែលមិនអាចធ្វើយុត្តិកម្មបានដូចជា :

-ការប្រើប្រាស់តួនាទី ឬ អំណាចរបស់ខ្លួន ដើម្បីកេងប្រវ័ញ្ច ឬ ធ្វើទុក្ខបុកម្នេញដល់បុគ្គលណាម្នាក់ ឬ ក្រុមមនុស្ស ឬ ទ្រព្យសម្បត្តិសាធារណៈ ឬ ធនធានសាធារណៈណាមួយ

-ការមិនបានប្រើប្រាស់តួនាទី ឬ អំណាចរបស់ខ្លួន ដើម្បីទប់ស្កាត់ជនម្នាក់ទៀតដែលស្ថិតនៅក្រោមអំណាច ឬ ការត្រួតពិនិត្យរបស់ខ្លួន នៅពេលដែលខ្លួនបានដឹងអំពីកំហុសឆ្គងរបស់ជននោះ ដែលបានកេងប្រវ័ញ្ច ឬ ធ្វើទុក្ខបុកម្នេញដល់បុគ្គលណាម្នាក់ ឬ ក្រុមមនុស្ស ឬ ទ្រព្យសម្បត្តិសាធារណៈ ឬ ធនធានសាធារណៈ ។

**មាត្រា ៤៩.-**

ការរំលោភអំណាច រួមមានសកម្មភាពណាមួយ ដូចខាងក្រោម :

-ការរំលោភសិទ្ធិស្របច្បាប់ ឬ សិទ្ធិមនុស្សរបស់ជនណាម្នាក់

-ការកាន់កាប់ ឬ ការរឹបអូសទ្រព្យសម្បត្តិសាធារណៈ ឬ ទ្រព្យសម្បត្តិឯកជន និងធនធានធម្មជាតិមកធ្វើជារបស់ខ្លួនដោយខុសច្បាប់

-ការធ្វើឱ្យអន្តរាយដល់បរិស្ថាន ធនធានធម្មជាតិ

-ការដកយកថវិកា ឬ ទ្រព្យសម្បត្តិរដ្ឋដោយខុសច្បាប់ ឬ ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមិនត្រឹមត្រូវ

-ការស្នើសុំ ឬ ការទទួលប្រាក់ ឬ រង្វាន់អ្វីមួយជាថ្នូរនឹងការធ្វើ ឬ មិនធ្វើកិច្ចការណាមួយ ដែលស្ថិតនៅក្នុងវិសាលភាពនៃភារកិច្ចផ្លូវការរបស់ជននោះ ហើយដែលការចំណាយ ឬ រង្វាន់ នោះមិនបានកំណត់នៅក្នុងច្បាប់

-ភាពមិនប្រក្រតីនៅក្នុងការអនុវត្តច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬប្រកាស

-ភាពមិនប្រក្រតីនៅក្នុងការអនុវត្តដីការបស់ក្រុមប្រឹក្សា

-ការធ្វើសេចក្តីសម្រេចនៅក្នុងវិសាលភាពនៃភារកិច្ចផ្លូវការ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ផលប្រយោជន៍គ្រួសាររបស់ខ្លួន ។

**មាត្រា ៥០.-**

ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំដែលពាក់ព័ន្ធ :

-ដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញ

-សកម្មភាពនានាដែលបានអនុវត្ត

-របាយការណ៍ហិរញ្ញវត្ថុ

-ការវាយតម្លៃការបំពេញការងាររបស់គណៈអភិបាល និងបុគ្គលិកក្រុមប្រឹក្សា

-លទ្ធផលនៃការតាមដាន និងវាយតម្លៃ ដូចមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ

-វិធានការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សា

ក្រុមប្រឹក្សាត្រូវពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំខាងលើនេះ មិនឱ្យលើសពីសែសិបប្រាំ(៤៥)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំ ។

**មាត្រា ៥១.-**




ក្រុមប្រឹក្សា ត្រូវបង្កលក្ខណៈងាយស្រួលដល់សាធារណជនក្នុងការជូនព័ត៌មានជា

សាធារណៈអំពីរបាយការណ៍ របៀបវារៈប្រជុំ កំណត់ហេតុប្រជុំ ដីកា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសទាំងអស់ដែលពាក់ព័ន្ធនឹងក្រុមប្រឹក្សា និងឯកសារដទៃទៀតរបស់ក្រុមប្រឹក្សា ។

**មាត្រា ៥២.-**

ក្រុមប្រឹក្សានីមួយៗត្រូវមានក្តារព័ត៌មានជាសាធារណៈ ឬ មធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងទៀតនៅការិយាល័យកណ្តាលរបស់ខ្លួន និងនៅតាមទីកន្លែងនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់ ហើយទីកន្លែងទាំងនោះមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋទទួលបានព័ត៌មានជាសាធារណៈទាំងនោះ ។

## ផ្នែកទី ៣
## ដីការបស់ក្រុមប្រឹក្សា

**មាត្រា ៥៣.-**

ដីកា គឺជាវិធានខាងផ្លូវច្បាប់ដែលបានអនុម័តដោយក្រុមប្រឹក្សា ។

យោងតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួន តាមការធ្វើសេចក្តីសម្រេចដើម្បីដាក់ចេញនូវដីកាតាមការចាំបាច់ ។

**មាត្រា ៥៤.-**

ដីការបស់ក្រុមប្រឹក្សា មានវិសាលភាពដើម្បីកំណត់ ដើម្បីហាមឃាត់ ឬ ដើម្បីត្រួតពិនិត្យលើសកម្មភាព លើនីតិវិធី ឬ លើកិច្ចការណាមួយ ដែលស្ថិតនៅក្នុងវិសាលភាពនៃមុខងារ ភារកិច្ច និងធនធានរបស់ក្រុមប្រឹក្សារួមមាន :

-តួនាទី ភារកិច្ច សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

-មុខងារ ឬ ភារកិច្ច ដែលប្រគល់ឱ្យក្រុមប្រឹក្សា

-មុខងារ ឬ ភារកិច្ច ដែលបានធ្វើប្រតិភូកម្មទៅឱ្យក្រុមប្រឹក្សា ក្នុងករណីដែលការធ្វើប្រតិភូកម្មនោះ មិនបានដកចេញនូវសិទ្ធិអំណាចខ្លះ ឬ ទាំងអស់ដើម្បីដាក់ចេញដីកា [illegible] កិច្ចការណាមួយដែលច្បាប់នេះ ឬ ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាសផ្សេងទៀត តម្រូវឱ្យក្រុមប្រឹក្សាដាក់ចេញដីកា ។

**មាត្រា ៥៥.–**

ដីកាដែលដាក់ចេញដោយក្រុមប្រឹក្សា ត្រូវប្រតិបត្តិ និងអនុវត្តនៅក្នុងដែនសមត្ថកិច្ចទាំងមូលរបស់ខ្លួន លើកលែងតែដីកាចែងផ្សេងពីនេះ ឬ លើកលែងតែច្បាប់ណាមួយបានតម្រូវឱ្យដកចេញពីដីកានូវតំបន់ដែលបានកំណត់ព្រំប្រទល់ច្បាស់លាស់ ។

**មាត្រា ៥៦.–**

ដីកាដែលក្រុមប្រឹក្សាបានអនុម័តរួច ត្រូវចូលជាធរមាននៅថ្ងៃដែលក្រុមប្រឹក្សាប្រកាសផ្សាយដីកានោះ ។

ដីកា អាចកំណត់យកកាលបរិច្ឆេទណាមួយនាពេលអនាគត សម្រាប់ការចូលជាធរមាននូវដីកាទាំងមូល ឬ ផ្នែកខ្លះនៃដីកា ។

ដីកា មិនអាចមានប្រតិសកម្ម និងមិនអាចចូលជាធរមានមុនពេលដែលដីកាត្រូវបានអនុម័ត និងប្រកាសផ្សាយនោះឡើយ ។

**មាត្រា ៥៧.–**

ដីកា ដែលចែងផ្ទុយពីបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ដីកានោះនឹងមិនមានសុពលភាពបានឡើយ ។

**មាត្រា ៥៨.–**

ដីកាណាមួយដែលធ្វើឡើងដោយមានការរើសអើងក្នុងន័យជាអវិជ្ជមាន ឬ អនុវត្តចំពោះតែបុគ្គលណាម្នាក់ ឬ ក្រុមមនុស្សណាមួយ ដោយផ្អែកលើកត្តាជាតិសាសន៍ សាសនា ភេទ អាយុ ពណ៌សម្បុរ ជាតិ ឬ ជាតិកំណើត ឬ អសមត្ថភាពខាងស្មារតី ឬ ខាងកាយសម្បទា ដីកានោះមិនមានសុពលភាពបានឡើយ ។

**មាត្រា ៥៩.–**

ដីកាអាចបង្កើតបទប្បញ្ញត្តិសម្រាប់ការពិន័យជាប្រាក់ចំពោះការប្រព្រឹត្តល្មើស ឬ ការមិនគោរពតាមបទប្បញ្ញត្តិមួយ ឬ ច្រើននៃដីកានោះបាន ។

ប៉ុន្តែបទ នីតិវិធីនៃការរៀបចំបទប្បញ្ញត្តិ សម្រាប់ការពិន័យជាប្រាក់ដោយដីការបស់

ជាក់លាក់ណាមួយសម្រុះសម្រួលដោះស្រាយ ។

**មាត្រា ៩៥.-**

នីតិវិធីក្នុងការដោះស្រាយវិវាទនៅមូលដ្ឋាន ត្រូវផ្អែកតាមច្បាប់ ឬ អនុក្រឹត្យ ។

## ផ្នែកទី ៧
## បទប្បញ្ញត្តិពិសេសសម្រាប់ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ដែលស្ថិតក្នុងស្រុក

**មាត្រា ៩៦.-**

ក្រុមប្រឹក្សាស្រុក ត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យក្នុងស្រុករបស់ខ្លួន ។

**មាត្រា ៩៧.-**

ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិប-តេយ្យនៅក្នុងស្រុក ក្រុមប្រឹក្សាស្រុកត្រូវ :

-ជួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នីមួយៗឱ្យបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាព សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

-រួមជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីជំរុញឱ្យមានការចូលរួមពីសាធារណជន នៅក្នុងដំណើរការអភិបាលកិច្ចនៅក្នុងស្រុក និងឃុំ សង្កាត់

-ស្វែងយល់និងឆ្លើយតប ចំពោះតម្រូវការក្នុងស្រុករបស់ខ្លួន និងសំណើរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ។

**មាត្រា ៩៨.-**

ក្រុមប្រឹក្សាស្រុកត្រូវមានគណនេយ្យភាព ចំពោះក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់និងប្រជាពលរដ្ឋទាំងអស់នៅក្នុងស្រុកអំពីជម្រើស សេចក្ដីសម្រេច ការអនុវត្តរបស់ខ្លួន ព្រមទាំងផលប៉ះពាល់នៃជម្រើស សេចក្ដីសម្រេច និងការអនុវត្តទាំងនោះ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា ៩៩.-**

ក្រុមប្រឹក្សាស្រុក ត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់និងអ្នកពាក់ព័ន្ធនានា ដើម្បីវាយតម្លៃឱ្យបានទៀងទាត់អំពីសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងធ្វើការបណ្តុះបណ្តាល កសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិករបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ព្រមទាំងធ្វើការអប់រំបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់នីមួយៗឱ្យបានទៀងទាត់ ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលស្គាល់គុណភាពនៃការអប់រំបណ្តុះបណ្តាល ដែលស្របជាមួយខ្លឹមសារនៃច្បាប់នេះ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ១០០.-**

ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ដែលពាក់ព័ន្ធ ត្រូវដាក់បញ្ចូលយុទ្ធសាស្ត្រ កម្មវិធី និងសកម្មភាពដែលបានកំណត់ សម្រាប់ឆ្លើយតបទៅនឹងតម្រូវការនិងសំណើរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ទៅក្នុងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំរបស់ស្រុក និងរបស់ឃុំ សង្កាត់ព្រមទាំងគម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ស្រុក និងឃុំ សង្កាត់ ។

**មាត្រា ១០១.-**

បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ក្រុមប្រឹក្សាស្រុកត្រូវសម្របសម្រួល និងគាំទ្រដល់ការបង្កើនសមត្ថភាពផ្នែករដ្ឋបាល ឬ ធនធានផ្នែករដ្ឋបាលដែលចាំបាច់ដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ មានសមត្ថភាពផ្នែករដ្ឋបាល ឬ ធនធានផ្នែករដ្ឋបាលគ្រប់គ្រាន់ និងជាអចិន្ត្រៃយ៍ដើម្បី ៖

-ជំរុញ ឬ ធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ឬ បំពេញមុខងារ ភារកិច្ចចាំបាច់មួយ ឬ ច្រើន

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

-បំពេញសមត្ថភាពផ្នែករដ្ឋបាល និងធនធានផ្នែករដ្ឋបាល រួមទាំងបុគ្គលិក ឧបករណ៍ ទ្រព្យសម្បត្តិ និងសម្ភារៈចាំបាច់នានា ។

**មាត្រា ១០២.-**

ការរៀបចំចាត់ចែងបង្កើនសមត្ថភាពផ្នែករដ្ឋបាល ឬ ធនធានផ្នែករដ្ឋបាលនៅក្នុង ឃុំ សង្កាត់ អាចធ្វើឡើងដោយអនុញ្ញាតឱ្យក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ពីរ ឬ ច្រើន ប្រើប្រាស់រួមគ្នានូវបុគ្គលិក ឧបករណ៍ ទ្រព្យសម្បត្តិ ឬ សម្ភារៈខ្លះ ឬ ទាំងអស់តាមការ ចាំបាច់ ។

**មាត្រា ១០៣.-**

ក្នុងករណីដែលក្រុមប្រឹក្សាស្រុកបានប្រឹងប្រែងសម្របសម្រួលបង្កើនសមត្ថភាពផ្នែក រដ្ឋបាល ឬ ធនធានផ្នែករដ្ឋបាលដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់រួចហើយ ប៉ុន្តែក្រុម ប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នោះនៅតែមិនអាចបំពេញភារកិច្ចជាមូលដ្ឋាន និងចាំបាច់ របស់ខ្លួនបាន ឬ មិនអាចជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យឱ្យបានគ្រប់គ្រាន់ ក្រុមប្រឹក្សាស្រុកត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បី រាយការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

របាយការណ៍ខាងលើនេះ ត្រូវដាក់បញ្ចូលនូវអនុសាសន៍សម្រេបអំពីសំណើកែ តម្រូវកង្វះខាតទាំងនេះ ។

**មាត្រា ១០៤.-**

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឯកភាពតាមរបាយការណ៍របស់ក្រុមប្រឹក្សា ស្រុក រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាស្រុក និង ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ដើម្បីរៀបចំផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ឱ្យមានសមត្ថភាពក្នុងការជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យឱ្យមានប្រសិទ្ធភាព ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ធ្វើឱ្យ មានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១១១.-**

ក្រុមប្រឹក្សាសង្កាត់ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សាក្រុង ។

**មាត្រា ១១២.-**

ក្រុមប្រឹក្សាក្រុងត្រូវផ្ទេរប្រតិភូកម្មមុខងារ ភារកិច្ច ទៅឱ្យក្រុមប្រឹក្សាសង្កាត់ ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យ មានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១១៣.-**

តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាសង្កាត់ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៣
## អំពីគណៈកម្មាធិការក្រុមប្រឹក្សា និងគណៈអភិបាល
### ផ្នែកទី ១
### គណៈកម្មាធិការរបស់ក្រុមប្រឹក្សា

**មាត្រា ១១៤.-**

ក្រុមប្រឹក្សា មានកាតព្វកិច្ចរៀបចំឱ្យមានគណៈកម្មាធិការដូចខាងក្រោម :

-គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

-គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

-គណៈកម្មាធិការលទ្ធកម្ម ។

**មាត្រា ១១៥.-**

ក្រៅពីគណៈកម្មាធិការទាំងបីខាងលើនេះ ក្រុមប្រឹក្សាអាចបង្កើតគណៈកម្មាធិការផ្សេងទៀត ដើម្បីជួយការងាររបស់ក្រុមប្រឹក្សាតាមការចាំបាច់ ។

**មាត្រា ១៣៩.-**

គណៈអភិបាលរួមមាន ប្រធានមួយរូប ដែលហៅថា អភិបាល និងអភិបាលរងមួយចំនួន ។

**មាត្រា ១៤០.-**

គណៈអភិបាលរាជធានីភ្នំពេញមានចំនួនយ៉ាងច្រើនប្រាំពីរ(០៧)រូប ។

គណៈអភិបាលខេត្តមានចំនួនពីបី(០៣)រូប ទៅប្រាំពីរ(០៧)រូប ។

គណៈអភិបាលក្រុង ស្រុក ខណ្ឌមានចំនួនពីបី(០៣)រូប ទៅប្រាំ(០៥)រូប ។

ចំនួនជាក់ស្តែងនៃគណៈអភិបាល សម្រាប់ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤១.-**

អភិបាលរាជធានី អភិបាលខេត្ត ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤២.-**

អភិបាលរាជធានី អភិបាលខេត្ត ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម :

-មានឋានន្តរសក្តិឧត្តមមន្ត្រី

-មានអាយុចាប់ពីសាមសិបប្រាំ(៣៥)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំពីរ(០៧)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**មាត្រា ១៤៣.-**

អភិបាលរងរាជធានី អភិបាលរងខេត្ត ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃដែលមានលក្ខណសម្បត្តិ ដូចខាងក្រោម :

-មានឋានន្តរសក្តិ ចាប់ពីវរមន្ត្រីឡើងទៅ

-មានអាយុចាប់ពីសាមសិបប្រាំ(៣៥)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំ(០៥)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**មាត្រា ១៤៤.-**

អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវធ្វើការជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិ ដូចខាងក្រោម :

-មានឋានន្តរសក្តិចាប់ពីអនុមន្ត្រីឡើង

-មានអាយុ ចាប់ពីសាមសិប(៣០)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំ(០៥)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**មាត្រា ១៤៥.-**

អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌ ត្រូវធ្វើការជ្រើសរើសពីក្នុង

ចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម៖

-មានឋានន្តរសក្តិចាប់ពីនាយក្រមការឡើង

-មានអាយុចាប់ពីម្ភៃប្រាំ(២៥) ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនបី(០៣)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្ររងដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជននិងកីឡា

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**មាត្រា ១៤៦.-**

ក្នុងករណីចាំបាច់ អភិបាល អភិបាលរង អាចជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រៅពីក្របខ័ណ្ឌក្រសួងមហាផ្ទៃបាន ប៉ុន្តែមន្ត្រីនោះត្រូវមានលក្ខណសម្បត្តិ សមស្របតាមមាត្រា ១៤២ មាត្រា ១៤៣ មាត្រា ១៤៤ និងមាត្រា ១៤៥ នៃច្បាប់នេះ ។

**មាត្រា ១៤៧.-**

អភិបាល អភិបាលរង មានអាណត្តិការងារមិនលើសពីបួន(០៤)ឆ្នាំ ។

អភិបាល អភិបាលរងអាចត្រូវបានតែងតាំងបានបួន(០៤)ឆ្នាំទៀត សម្រាប់អាណត្តិទី ២ របស់ខ្លួននៅក្នុងដែនសមត្ថកិច្ចដដែល ។

**មាត្រា ១៤៨.-**

អភិបាល អភិបាលរងមិនមែនជាសមាជិកក្រុមប្រឹក្សាឡើយ ។

**មាត្រា ១៤៩.-**

អភិបាល អភិបាលរងអាចចូលរួមគ្រប់អង្គប្រជុំ និងមានសិទ្ធិបញ្ចេញមតិក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាបាន តែមិនអាចធ្វើការបោះឆ្នោតបានឡើយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

**មាត្រា ១៥០.-**

អភិបាល អភិបាលរង ត្រូវបញ្ឈប់ពីមុខតំណែងនៅមុនពេលបញ្ចប់អាណត្តិការងារ ប្រសិនបើសាមីខ្លួន :

-ដាក់ពាក្យលាលែងជាលាយលក្ខណ៍អក្សរជូនទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ

-ត្រូវបានដកហូតពីមុខតំណែង ។

**មាត្រា ១៥១.-**

អភិបាល អភិបាលរងណាមួយ ត្រូវដកហូតពីមុខតំណែងមុនពេលបញ្ចប់អាណត្តិការងារ ក្នុងករណីណាមួយដូចខាងក្រោម :

-បាត់បង់លក្ខណសម្បត្តិជាអភិបាល ឬ អភិបាលរង

-អសមត្ថភាព

-បំពេញការងារមិនបានល្អ

-មានបញ្ហាសុខភាព ឬ បាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច

-បោះបង់ចោលការងារ

-ប្រព្រឹត្តខុសឆ្គងពីក្រមសីលធម៌វិជ្ជាជីវៈ ។

**មាត្រា ១៥២.-**

ក្រុមប្រឹក្សា អាចស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីដកហូតអភិបាល អភិបាលរងចេញពីមុខដំណែង ដោយផ្អែកតាមករណីណាមួយក្នុងចំណោមករណីដូចមានចែងក្នុងមាត្រា ១៥១ នៃច្បាប់នេះ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់នូវសំណើខាងលើនេះ ដើម្បីធ្វើសេចក្តីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ពិនិត្យសម្រេចចំពោះអភិបាលរាជធានី អភិបាលខេត្ត អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង អភិបាលស្រុក អភិ-បាលខណ្ឌ ។

ចំពោះអភិបាលរងក្រុង ស្រុក ខណ្ឌ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការស៊ើបអង្កេតនិងដោះស្រាយជាបន្ទាន់ ។

មាត្រា ១៥៣.-

អភិបាល អភិបាលរង ត្រូវទទួលប្រាក់បៀវត្ស និងអាចទទួលកម្រៃផ្សេងៗទៀតដែលសមស្របនឹងមុខតំណែងនេះ ។

ប្រាក់បៀវត្ស និងកម្រៃផ្សេងៗទៀតរបស់អភិបាល អភិបាលរងត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ១៥៤.-

អភិបាល មានតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដើម្បីណែនាំ សម្របសម្រួល តម្រង់ទិសមន្ទីរ អង្គភាព ខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានា និងទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាល ដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

អភិបាល ត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការងារ សន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិមនុស្សក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល អភិបាល ត្រូវមានគណនេយ្យភាព ចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានា ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចស្នើរាជរដ្ឋាភិបាលចេញអនុក្រឹត្យដើម្បីកំណត់តួនាទី សិទ្ធិអំណាចរបស់អភិបាលក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានា តាមការចាំបាច់ ។

មាត្រា ១៥៥.-

គណៈអភិបាល ត្រូវផ្តល់យោបល់ជូនក្រុមប្រឹក្សា រាយការណ៍ជូនក្រុមប្រឹក្សា និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ។

គណៈអភិបាល ត្រូវជួយក្រុមប្រឹក្សា ដើម្បីឱ្យក្រុមប្រឹក្សាសម្រេចបាននូវការអនុវត្ត

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

មុខងារ សិទ្ធិអំណាច និងភារកិច្ចរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ១៥៦.-**

គណៈអភិបាល ត្រូវជួយក្រុមប្រឹក្សាក្នុងការពិនិត្យមើលមុខងារ ភារកិច្ច និងធនធានទាំងអស់ ដែលបានបែងចែក ឬ បានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយច្បាប់នេះ ឬ ដែលស្របតាមច្បាប់នេះ រួចហើយត្រូវផ្ដល់អនុសាសន៍ដល់ក្រុមប្រឹក្សាអំពីរបៀបបំពេញមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ ។

**មាត្រា ១៥៧.-**

ក្រុមប្រឹក្សាត្រូវត្រួតពិនិត្យសកម្មភាព និងការអនុវត្តរបស់គណៈអភិបាល និងអភិបាល ។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាអាចកោះអញ្ជើញគណៈអភិបាល ឬ អភិបាល និងបុគ្គលដែលពាក់ព័ន្ធមកសាកសួរបំភ្លឺក្នុងកិច្ចប្រជុំសាមញ្ញ ឬ វិសាមញ្ញរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៥៨.-**

គណៈអភិបាល ឬ អភិបាលដែលបានសម្រេច ឬ បានអនុវត្តកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សា ការសម្រេច ឬ សកម្មភាពនោះ ពុំមានសុពលភាពបានឡើយ ។

**មាត្រា ១៥៩.-**

គណៈអភិបាល ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាអំពីការអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា និងសកម្មភាពដែលបានអនុវត្តដោយគណៈអភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ក្នុងចន្លោះអង្គប្រជុំសាមញ្ញមួយទៅអង្គប្រជុំសាមញ្ញមួយទៀតរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៦០.-**

គណៈអភិបាលត្រូវផ្ដល់យោបល់ និងរាយការណ៍ជូនក្រុមប្រឹក្សាពីការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធានរបស់ក្រុមប្រឹក្សា ដើម្បីទទួលយក

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

មុខងារ ភារកិច្ច និងធនធាន ដែលនឹងត្រូវផ្ទេរទៅឱ្យក្រុមប្រឹក្សាដោយច្បាប់នេះ ឬដែលស្របតាមច្បាប់នេះ ។

**មាត្រា ១៦១.-**

គណៈអភិបាល ក្នុងនាមក្រុមប្រឹក្សា ត្រូវមានវិធានការដើម្បីធានាឱ្យមន្ត្រី អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សាបំពេញតួនាទី ភារកិច្ចរបស់ខ្លួន និងបំពេញការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា ព្រមទាំងអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រកបដោយប្រសិទ្ធភាព ។

**មាត្រា ១៦២.-**

គណៈអភិបាល ត្រូវផ្តល់អនុសាសន៍ និងដាក់ជូនក្រុមប្រឹក្សា ដើម្បីពិភាក្សាសម្រេចអំពី :

-ការបង្កើត ឬរំសាយអង្គភាព

-ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិក

-ការតែងតាំង ការដំឡើងឋានន្តរស័ក្តិ និងការបញ្ឈប់បុគ្គលិក ដោយផ្អែកតាមបទប្បញ្ញត្តិនៃការគ្រប់គ្រងបុគ្គលិករបស់ក្រុមប្រឹក្សា

-ការកំណត់លក្ខណសម្បត្តិនៃការជ្រើសរើស ការតែងតាំង ការកំណត់ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗទៀតនៃបុគ្គលិករបស់ក្រុមប្រឹក្សា

-ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុ សម្រាប់អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា

-ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា និងបុគ្គលិករបស់ខ្លួន ។

**មាត្រា ១៦៣.-**

គណៈអភិបាល ត្រូវរៀបចំដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និងអនុម័តនូវ :

-កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងគម្រោងថវិកាប្រចាំឆ្នាំ

-ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំនិង ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ និង

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL ·

-របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាដូចមានចែងក្នុងមាត្រា ៩០ នៃច្បាប់នេះ ដើម្បីផ្សព្វផ្សាយជូនប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

## មាត្រា ១៦៤.-

គណៈអភិបាល ត្រូវលើកសំណើទៅក្រុមប្រឹក្សា ដើម្បីកំណត់អំពីយុទ្ធសាស្ត្រ និងរបៀបនៃការពិគ្រោះយោបល់លើបញ្ហាចាំបាច់ផ្សេងៗរួមទាំងផែនការអភិវឌ្ឍជាមួយ :

-ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា

-ផ្នែកផ្សេងទៀតរបស់ក្រុមប្រឹក្សាដែលអនុវត្តមុខងារ និងភារកិច្ចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រដ្ឋាភិបាល

-ដៃគូពាក់ព័ន្ធដទៃទៀត ។

ការពិគ្រោះយោបល់លើបញ្ហាចាំបាច់ផ្សេងៗ រួមទាំងផែនការអភិវឌ្ឍដែលត្រូវធ្វើឡើងដោយក្រុមប្រឹក្សាផ្ទាល់ ឬ ដោយគណៈអភិបាលក្នុងនាមក្រុមប្រឹក្សា ។

## មាត្រា ១៦៥.-

គណៈអភិបាលត្រូវរាយការណ៍ជូនគ្រប់អង្គប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាមួយនឹងអនុសាសន៍ចាំបាច់នានា សម្រាប់លើកកម្ពស់ការអនុវត្ត :

-មុខងារជាកាតព្វកិច្ចដែលបានផ្ទេរឱ្យក្រុមប្រឹក្សា

-មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា

-កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំ (០៥) ឆ្នាំរបស់ក្រុមប្រឹក្សា រួមទាំងសមាសភាគនៃផែនការដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ :

+ ក្រុមប្រឹក្សារួមគ្នា

+ ប្រភេទក្រុមប្រឹក្សាផ្សេងៗ

+ ក្រសួង ស្ថាប័ន ឬ មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល

+ ដៃគូពាក់ព័ន្ធនានា ។

-គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-ស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-ដីការបស់ក្រុមប្រឹក្សា ។

**មាត្រា ១៦៦.-**

គណៈអភិបាល ត្រូវពិគ្រោះយោបល់ជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីធានាឱ្យផែនការសកម្មភាព និងថវិការបស់បណ្ដាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាលដែលផ្ដល់សេវា សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធ ដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា បានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ ព្រមទាំងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ១៦៧.-**

គណៈអភិបាល ត្រូវលើកទឹកចិត្ត សម្របសម្រួល និងគាំទ្រដល់សមាជិកក្រុមប្រឹក្សា បុគ្គលិករបស់ក្រុមប្រឹក្សា ដើម្បីរាយការណ៍ជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់ នៅពេលដែលបានឃើញ ឬ ដែលបានសង្ស័យដោយមានហេតុផល ឬ ដែលមានការប្ដឹងតវ៉ា ឬ ប្ដឹងបរិហារ អំពីការរំលោភអំណាចដោយបុគ្គលណាម្នាក់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៦៨.-**

គណៈអភិបាល ត្រូវផ្ដល់អនុសាសន៍ជូនក្រុមប្រឹក្សាពីការបង្កើតគណៈកម្មាធិការនានាតាមការចាំបាច់ ដើម្បីជួយដល់ក្រុមប្រឹក្សាក្នុងការអនុវត្តការងារអនុលោមតាមច្បាប់នេះ ។

**មាត្រា ១៦៩.-**

គណៈអភិបាលត្រូវធានាឱ្យមានក្ដារបិទផ្សាយព័ត៌មាន និងមធ្យោបាយផ្សព្វផ្សាយ

ព័ត៌មានផ្សេងៗទៀត តាមតម្រូវការរបស់ក្រុមប្រឹក្សារបស់ខ្លួន ។

រាល់ឯកសារទាំងអស់ដែលបានបោះពុម្ពផ្សាយស្របតាមច្បាប់នេះ ត្រូវតែបិទផ្សាយនៅលើក្ដារព័ត៌មាន ឬ ត្រូវផ្សព្វផ្សាយតាមមធ្យោបាយផ្សេងៗទៀតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៧០.-**

គណៈអភិបាល ត្រូវធានាឱ្យសាធារណជនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការពិនិត្យមើលព័ត៌មាននានានៅលើក្ដារបិទផ្សាយព័ត៌មាន ហើយត្រូវធានាថែរក្សាការពារសុវត្ថិភាពក្ដារព័ត៌មាន ដែលមានក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៧១.-**

គណៈអភិបាល ត្រូវធ្វើការបែងចែកភារកិច្ចជាលាយលក្ខណ៍អក្សរនូវកិច្ចការដែលស្ថិតនៅក្នុងសិទ្ធិអំណាចរបស់ខ្លួន ។

**មាត្រា ១៧២.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចលើកសំណើជូនរាជរដ្ឋាភិបាលដើម្បីកំណត់នូវតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយអនុក្រឹត្យ ។

## ជំពូកទី ៤
## អំពីបុគ្គលិក និងអង្គភាពរបស់ក្រុមប្រឹក្សា

### ផ្នែកទី ១
### បុគ្គលិករបស់ក្រុមប្រឹក្សា

**មាត្រា ១៧៣.-**

ក្រុមប្រឹក្សានីមួយៗ ត្រូវមានបុគ្គលិកក្រុមប្រឹក្សារបស់ខ្លួន ។

បុគ្គលិកក្រុមប្រឹក្សា គឺជាបុគ្គលិករបស់ក្រុមប្រឹក្សាដែលបានតែងតាំងដោយក្រុមប្រឹក្សា ឬ ជាបុគ្គលិកដែលបានតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា ឬ ជា

ROYAUME DU CAMBODGE MINISTRE DU PALAIS ROYAL

បុគ្គលិកដែលត្រូវបានរៀបចំឡើងវិញទៅឱ្យក្រុមប្រឹក្សាស្របទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

សមាជិកក្រុមប្រឹក្សា មិនមែនជាបុគ្គលិករបស់ក្រុមប្រឹក្សាឡើយ ។

**មាត្រា ១៧៤.-**

បុគ្គលិករបស់ក្រុមប្រឹក្សា ត្រូវស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យដោយផ្ទាល់របស់គណៈអភិបាលក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ។

**មាត្រា ១៧៥.-**

បុគ្គលិកក្រុមប្រឹក្សា មិនត្រូវរាប់បញ្ចូលនូវមន្ត្រីនៃក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល ឬ មន្ត្រីដទៃទៀតដែលអនុវត្តភារកិច្ចពាក់ព័ន្ធនឹងសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិមនុស្សក្នុងនាមរាជរដ្ឋាភិបាលឡើយ ។

**មាត្រា ១៧៦.-**

បុគ្គលិកដែលត្រូវបានជ្រើសរើស និងតែងតាំងដោយក្រុមប្រឹក្សា ត្រូវដំណើរការតាមការប្រកួតប្រជែងដែលមានតម្លាភាព ។

ក្នុងដំណើរការជ្រើសរើស និងតែងតាំងបុគ្គលិករបស់ក្រុមប្រឹក្សា ត្រូវធានាឱ្យមានចំនួនស្ត្រីសមស្របនៅមុខតំណែងប្រធាន ឬ អនុប្រធាន អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា ។

ការជ្រើសរើស និងការតែងតាំងនេះ ត្រូវធ្វើឱ្យស្របទៅតាមបទប្បញ្ញត្តិស្តីពីបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ១៧៧.-**

ក្រុមប្រឹក្សាត្រូវសម្រេចអំពីការតែងតាំង ការបណ្តេញចោល ការកម្រិតប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗទៀត សម្រាប់មុខតំណែងបុគ្គលិករបស់ខ្លួន ។

ការតែងតាំង ការបណ្តេញចោល ការកម្រិតប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗរបស់បុគ្គលិកក្រុមប្រឹក្សា ត្រូវធ្វើឡើងឱ្យស្របទៅតាមបទប្បញ្ញត្តិស្តីពីបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ១៧៨.-**

បុគ្គលិកទាំងអស់ ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពដោយផ្ទាល់ចំពោះប្រធានគ្រប់គ្រងផ្ទាល់របស់ខ្លួន និងត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពដោយប្រយោលចំពោះនាយករដ្ឋបាល អភិបាល គណៈអភិបាល និងក្រុមប្រឹក្សាតាមឋានានុក្រម ។

**មាត្រា ១៧៩.-**

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវមានប្រធានហិរញ្ញវត្ថុមួយរូប ។

ប្រធានហិរញ្ញវត្ថុនេះ ត្រូវបានតែងតាំងដោយក្រុមប្រឹក្សា ដើម្បីបំពេញភារកិច្ចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន បន្ទាប់ពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៨០.-**

ប្រធានហិរញ្ញវត្ថុត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ការងារលទ្ធកម្ម និងធានាដល់ការធ្វើសវនកម្មឱ្យបានត្រឹមត្រូវស្របតាមច្បាប់នេះ និងលិខិតបទដ្ឋាននានា ដែលធ្វើឡើងស្របតាមច្បាប់នេះ ។

**មាត្រា ១៨១.-**

ក្រុមប្រឹក្សាស្រុក ត្រូវមានអង្គភាពមួយសម្រាប់គាំទ្រឃុំ សង្កាត់ ។

អង្គភាពគាំទ្រឃុំ សង្កាត់ត្រូវមានប្រធានមួយរូប ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពគាំទ្រឃុំ សង្កាត់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៨២.-**

បុគ្គលិកក្រុមប្រឹក្សា ត្រូវបំពេញកិច្ចការប្រចាំថ្ងៃ ក្រោមការដឹកនាំរបស់ប្រធានអង្គភាពរបស់ខ្លួន ដើម្បីអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាល ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ផ្នែកទី ២

## នាយករដ្ឋបាល

**មាត្រា ១៨៣.–**

ក្រុមប្រឹក្សានីមួយៗ ត្រូវមាននាយករដ្ឋបាលមួយរូបដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៨៤.–**

នាយករដ្ឋបាល មានតួនាទីជាជំនួយការក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន ។

ក្នុងតួនាទីខាងលើនេះ នាយករដ្ឋបាលត្រូវធ្វើសេចក្តីរាយការណ៍ និងមានគណនេយ្យភាព ចំពោះក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន ។

**មាត្រា ១៨៥.–**

នាយករដ្ឋបាល មានតួនាទី ភារកិច្ចដូចខាងក្រោម :

-អនុវត្តកិច្ចការប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាល

-ធានាឱ្យអង្គភាព បុគ្គលិករបស់ក្រុមប្រឹក្សា អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន

-អនុវត្តជីការបស់ក្រុមប្រឹក្សា

-ចូលរួម និងមានយោបល់រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា និងគណៈអភិបាល ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតបានឡើយ

-ផ្តល់យោបល់ដល់ក្រុមប្រឹក្សា ដល់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ដើម្បីក្រុមប្រឹក្សាសម្រេចបាននូវគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

-ផ្តល់យោបល់ដល់គណៈអភិបាល ដើម្បីគណៈអភិបាលអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ។

**មាត្រា ១៨៦.–**

គណៈអភិបាល អាចធ្វើប្រតិភូកម្មការងារទៅឱ្យនាយករដ្ឋបាលនូវកិច្ចការណាមួយ ដែលស្ថិតក្នុងវិសាលភាពការងាររបស់គណៈអភិបាល ដើម្បីលើកយោបល់ជូនគណៈ-អភិបាលសម្រេច ។

**មាត្រា ១៨៧.–**

នាយករដ្ឋបាល ត្រូវធានាឱ្យប្រធានហិរញ្ញវត្ថុបំពេញភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវ ។

**មាត្រា ១៨៨.–**

ល័ក្ខខ័ណ្ឌនៃការតែងតាំង តួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់នាយករដ្ឋបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ផ្នែកទី ៣
## អង្គភាពរបស់ក្រុមប្រឹក្សា

**មាត្រា ១៨៩.–**

ក្រុមប្រឹក្សាត្រូវមានអង្គភាពនានារបស់ខ្លួន តាមការចាំបាច់ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវលើកសំណើដាក់ចេញអនុក្រឹត្យដើម្បីឱ្យក្រុមប្រឹក្សាកំណត់នូវការរៀបចំអង្គភាព ការកំណត់មុខងារ ភារកិច្ច និងការរៀបចំមុខតំណែងបុគ្គ-លិកក្នុងអង្គភាពនានារបស់ខ្លួនឱ្យបានសមស្រប ។

**មាត្រា ១៩០.–**

អង្គភាពរបស់ក្រុមប្រឹក្សានីមួយៗ ត្រូវស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់គណៈអភិបាលក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ។

**មាត្រា ១៩១.–**

អង្គភាពនីមួយៗ ត្រូវស្ថិតក្រោមការទទួលខុសត្រូវ ការត្រួតពិនិត្យ និងការគ្រប់គ្រងដោយផ្ទាល់របស់ប្រធានអង្គភាព ។

ប្រធានអង្គភាពនីមួយៗ ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាល ។

# ជំពូកទី ៥
# អំពីដំណើរការអនុវត្ត
## ផ្នែកទី ១
## គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ

**មាត្រា ១៩២.-**

ត្រូវបង្កើតឱ្យមានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហៅកាត់ថា "គ.ជ.អ.ប" ដែលកំណត់ដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៩៣.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ មានសមាជិកមកពីក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ។

**មាត្រា ១៩៤.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវមានអនុគណៈកម្មាធិការមុខងារ និងធនធាន អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និង ហិរញ្ញវត្ថុ និងអនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិនិងអនុគណៈកម្មាធិការផ្សេងៗទៀតជាជំនួយការ ។

តួនាទី ភារកិច្ច និងសមាសភាពនៃអនុគណៈកម្មាធិការខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

### មាត្រា ១៩៥.-

អនុគណៈកម្មាធិការ ត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល មុនពេលផ្តល់អនុសាសន៍ដល់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

### មាត្រា ១៩៦.-

អនុគណៈកម្មាធិការនីមួយៗ អាចបង្កើតក្រុមការងារមួយ ឬ ច្រើនតាមការចាំបាច់ ដើម្បីសិក្សា និងរាយការណ៍អំពីការងារដែលស្ថិតនៅក្នុងភារកិច្ច និងសិទ្ធិអំណាចរបស់អនុគណៈកម្មាធិការ ។

### មាត្រា ១៩៧.-

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវមានលេខាធិការដ្ឋានមួយជាសេនាធិការ ។

លេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិប-តេយ្យនៅថ្នាក់ក្រោមជាតិស្ថិតនៅក្នុងក្រសួងមហាផ្ទៃ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

### មាត្រា ១៩៨.-

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវប្រជុំយ៉ាងតិចពីរ(០២)ខែម្តង ។

### មាត្រា ១៩៩.-

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## មាត្រា ២០០.-

ផ្អែកតាមលក្ខខណ្ឌនានាដែលបានចែងក្នុងច្បាប់នេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវពិនិត្យមើលឡើងវិញនូវការទទួលខុសត្រូវ និងមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីកំណត់មុខងារសម្រាប់ផ្ទេរដល់ក្រុមប្រឹក្សានានានៅថ្នាក់ក្រោមជាតិ ។

ការកំណត់ និងការផ្ទេរមុខងារខាងលើនេះ ត្រូវធ្វើឡើងដោយរួមជាមួយនឹង :

-ការផ្ទេរធនធានរួមមាន ចំណូល ហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិ និងសមត្ថភាព ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារនីមួយៗ

-ការផ្តល់លទ្ធភាព និងអំណាច ដើម្បីទទួលបានធនធានចាំបាច់រួមមាន ចំណូល ហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិ និងសមត្ថភាពសម្រាប់គ្រប់គ្រង និងអនុវត្តមុខងារនីមួយៗ នោះ

-ការផ្តល់អំណាច និងភារកិច្ច ដើម្បីគ្រប់គ្រង និងអនុវត្តរាល់មុខងាររបស់ខ្លួន តាមគោលការណ៍ស្វ័យភាពមូលដ្ឋាន និងគណនេយ្យភាពនៅមូលដ្ឋានក្នុងកម្រិតជាអតិបរមា ។

## មាត្រា ២០១.-

ក្នុងពេលដែលរង់ចាំការផ្ទេរមុខងារ និងភារកិច្ចដល់ក្រុមប្រឹក្សានានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវធានាឱ្យបានថា ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលនៅថ្នាក់ជាតិបានធ្វើសមាហរណកម្មនូវផែនការអភិវឌ្ឍ និងថវិការបស់ខ្លួននៅថ្នាក់ក្រោមជាតិទៅក្នុងផែនការអភិវឌ្ឍ និង ថវិការបស់ក្រុមប្រឹក្សាតាមប្រភេទនីមួយៗ ។

## មាត្រា ២០២.-

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវធានាឱ្យច្បាប់នេះ ត្រូវបានអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធនានា នៅថ្នាក់ជាតិ មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សានានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ២០៣.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវធានាឱ្យគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីកំណែទម្រង់នានាមានសង្គតិភាពជាមួយច្បាប់នេះ ។

**មាត្រា ២០៤.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ អាចផ្តល់អនុសាសន៍ដោយផ្ទាល់ដល់រាជរដ្ឋាភិបាល ឬ ក្រសួង ស្ថាប័នណាមួយរបស់រាជរដ្ឋាភិបាលអំពីការតាក់តែង ឬ ការធ្វើវិសោធនកម្មច្បាប់ ឬ លិខិតបទដ្ឋាននានា ដើម្បីឱ្យស្របតាមច្បាប់នេះ ។

**មាត្រា ២០៥.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ អាចដោះស្រាយ ឬ លើកសំណើសុំសេចក្តីសម្រេចពីរាជរដ្ឋាភិបាលលើការមិនចុះសម្រុងគ្នា ដែលអាចកើតមានឡើងទាក់ទងនឹងការអនុវត្តច្បាប់នេះ ។

**មាត្រា ២០៦.-**

អនុគណៈកម្មាធិការនានានៃគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធ មន្ទីរ អង្គភាពនានា និងក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចអនុវត្តសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

**មាត្រា ២០៧.-**

ករណីក្រសួង ស្ថាប័នណាមួយរបស់រាជរដ្ឋាភិបាល មិនអនុវត្តតាមការសម្រេចរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ជាតិ ត្រូវរាយការណ៍ ដើម្បីសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា ២០៨.-**

ករណីក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ មិនអនុវត្តតាមការសម្រេចរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវស្នើដល់ក្រសួងមហាផ្ទៃដើម្បីអនុវត្តទៅតាមនីតិវិធីដែលបានកំណត់ក្នុងច្បាប់នេះ ។

**មាត្រា ២០៩.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវធ្វើសេចក្តីរាយការណ៍ជាលាយលក្ខណ៍អក្សរអំពីការអនុវត្តច្បាប់នេះ ជូនរាជរដ្ឋាភិបាលយ៉ាងតិចប្រាំមួយ(០៦)ខែម្តង ។

**មាត្រា ២១០.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវមានថវិការបស់ខ្លួន ។

ថវិការបស់គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិត្រូវគិតបញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ២១១.-**

ដើម្បីអនុវត្តច្បាប់នេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិប-តេយ្យ នៅថ្នាក់ក្រោមជាតិត្រូវអនុម័ត :

-កម្មវិធីជាតិពីរយៈពេលមធ្យមទៅរយៈពេលវែង សម្រាប់គាំទ្រដល់ការអនុវត្តច្បាប់នេះ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ

-ផែនការសកម្មភាព និងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដោយផ្អែកលើកម្មវិធីជាតិ

-របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តច្បាប់នេះ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

### មាត្រា ២១២.-

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមានសិទ្ធិទទួលមូលនិធិ និងការគាំទ្រពីដៃគូអភិវឌ្ឍនានា និងពីប្រភពផ្សេងៗទៀតដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ។

## ផ្នែកទី ២

## មុខងារ

### មាត្រា ២១៣.-

រាជរដ្ឋាភិបាល គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាទាំងអស់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសម្រេចឱ្យបាននូវគោលបំណងរួមក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

### មាត្រា ២១៤.-

ក្រុមប្រឹក្សាប្រភេទនីមួយៗ ត្រូវរួមចំណែកក្នុងការសម្រេចឱ្យបាននូវគោលបំណងរួមនេះ ដោយធ្វើការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានផ្ទេរឱ្យអនុលោមតាមច្បាប់នេះប្រកបដោយប្រសិទ្ធភាព ។

### មាត្រា ២១៥.-

ក្នុងការពិនិត្យមើលឡើងវិញនូវមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានានិងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិប-តេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវផ្តល់អាទិភាពដល់បញ្ហាដែលទាក់ទងនឹងផ្នែកនានាដូចខាងក្រោម :

-កសិកម្ម

-អប់រំ

-ព្រៃឈើ ធនធានធម្មជាតិ និងបរិស្ថាន

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

-សុខាភិបាល អាហារូបត្ថម្ភ និងសេវាប្រជាជន រួមទាំងតម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ជនងាយរងគ្រោះ និងជនជាតិដើមភាគតិច

-ឧស្សាហកម្ម និងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច

-ការប្រើប្រាស់ដីធ្លី

-ការផលិត និងការចែកចាយអគ្គិសនី

-ការគ្រប់គ្រងទឹក

-ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយ សម្ភារៈចាំបាច់ ដើម្បីគាំទ្រ និងចាត់ចែង ការទទួលខុសត្រូវទាំងនេះ និង

-តម្រូវការពិសេស ឬ តម្រូវការដែលបានកំណត់ជាក់លាក់ សម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយគិតទាំងវិស័យទេសចរណ៍ តំបន់ប្រវត្តិសាស្ត្រនិងកេរដំណែលវប្បធម៌ផងដែរ ។

## មាត្រា ២១៦.-

ក្នុងការត្រួតពិនិត្យមើលឡើងវិញនូវមុខងារ និងការទទួលខុសត្រូវនីមួយៗដូចមានចែងក្នុងមាត្រា ២១៥ នៃច្បាប់នេះ ត្រូវផ្តល់អាទិភាពដល់ការពិនិត្យមើលឡើងវិញនូវមុខងារជាមូលដ្ឋាន និងចាំបាច់ដែលមានផលប៉ះពាល់ផ្ទាល់ដល់ការកាត់បន្ថយភាពក្រីក្រ និងការកែលម្អគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។

## មាត្រា ២១៧.-

គោលបំណងនៃការពិនិត្យមើលឡើងវិញនូវមុខងារ និងការទទួលខុសត្រូវទាំងនេះ គឺដើម្បីកំណត់មុខងារ និងការទទួលខុសត្រូវដែលនឹងត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សាឃុំ ឱ្យក្រុមប្រឹក្សាសង្កាត់ ឱ្យក្រុមប្រឹក្សាស្រុក ឱ្យក្រុមប្រឹក្សាក្រុង ឱ្យក្រុមប្រឹក្សាខេត្ត ឱ្យក្រុមប្រឹក្សារាជធានី ឬ ត្រូវរក្សាទុកជាមុខងារ និងការទទួលខុសត្រូវរបស់ថ្នាក់ជាតិ ។

ការកំណត់ឡើងវិញនូវមុខងារ និងការទទួលខុសត្រូវខាងលើនេះ ត្រូវធានាឱ្យបានថា មុខងារ និងការទទួលខុសត្រូវដែលបានផ្ទេរ ត្រូវធ្វើឡើងជាមួយនឹងការផ្ទេរធនធានសមស្របដើម្បីគ្រប់គ្រង និងចាត់ចែងមុខងារ និងការទទួលខុសត្រូវទាំងនោះ ។

**មាត្រា ២១៨.-**

ការផ្ទេរមុខងារ និងធនធាន ត្រូវធ្វើឡើងដោយមានការគ្រោងទុក មានដំណាក់កាល មានសនិទានភាព មានការសម្របសម្រួល មានការពិគ្រោះយោបល់ មានតម្លាភាព និងមានការរំខានជាអប្បបរមាទៅលើប្រតិបត្តិការដែលកំពុងដំណើរការរបស់រាជរដ្ឋាភិបាល និងការគាំទ្រពីអ្នកពាក់ព័ន្ធនានា ។

**មាត្រា ២១៩.-**

យុទ្ធសាស្ត្រ និងកម្មវិធីជាតិ ត្រូវមានសង្គតិភាពជាមួយមុខងារ និងធនធាន ដែលត្រូវបានផ្ទេរស្របតាមច្បាប់នេះ ។

**មាត្រា ២២០.-**

ដើម្បីធ្វើការផ្ទេរមុខងារឱ្យបានសមស្របសម្រាប់ប្រភេទក្រុមប្រឹក្សានីមួយៗ ជាបឋមត្រូវធ្វើការពិនិត្យមើលមុខងារទាំងនោះ ដោយផ្អែកតាមគោលការណ៍ដូចខាងក្រោម :

- ស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ
- អាចគ្រប់គ្រង និងអនុវត្តនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ
- បម្រើ ឬ ផ្តល់ផលប្រយោជន៍ជាចម្បងដល់ប្រជាជននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ
- មានផលប៉ះពាល់ជាចម្បងនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ ។

ផ្អែកតាមគោលការណ៍ខាងលើនេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបញ្ជាក់ហេតុផលឱ្យបានច្បាស់លាស់ក្នុងការផ្ទេរមុខងារទៅឱ្យថ្នាក់រដ្ឋបាលដែលសមស្រប ដោយឈរលើគោលការណ៍មានប្រសិទ្ធភាព ។

**មាត្រា ២២១.-**

ក្នុងការផ្ទេរមុខងារដូចមានចែងក្នុងមាត្រា ២១៥ មាត្រា ២១៧ និងមាត្រា ២២០ នៃច្បាប់នេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវកំណត់មុខងារណាមួយមានលក្ខណៈជាមុខងារជាកាតព្វកិច្ច ឬ មុខងារជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ជម្រើស និងត្រូវកំណត់មុខងារណាមួយមានលក្ខណៈជាមុខងារដែលត្រូវប្រគល់ ឬ ជាមុខងារដែលត្រូវធ្វើប្រតិភូកម្ម ។

## ផ្នែកទី ៣

## មុខងារជាកាតព្វកិច្ច

### មាត្រា ២២២.-

មុខងារជាកាតព្វកិច្ច គឺជាមុខងារដែលកំណត់ដោយច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាសតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ។

ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាសខាងលើនេះ ត្រូវចែងអំពីតម្រូវការជាកាតព្វកិច្ចច្បាស់លាស់ និងជាក់លាក់សម្រាប់គ្រប់គ្រង និងអនុវត្តមុខងារដោយបញ្ជាក់ច្បាស់អំពីក្របខ័ណ្ឌពេលវេលាសម្រាប់អនុវត្តបទដ្ឋាន និងនីតិវិធី ។

### មាត្រា ២២៣.-

មុខងារជាកាតព្វកិច្ច ដែលគ្រប់គ្រង ចាត់ចែង និងអនុវត្តដោយប្រភេទក្រុមប្រឹក្សាណាមួយ ហើយមិនតម្រូវឱ្យមានការរួមចំណែកជាប្រចាំពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប៉ុន្តែក្រសួង ស្ថាប័នទាំងនោះ ត្រូវផ្ទេរធនធានដើម្បីឱ្យក្រុមប្រឹក្សាគ្រប់គ្រង ចាត់ចែង និង អនុវត្តមុខងារនោះ ។

មុខងារជាកាតព្វកិច្ចខាងលើនេះ ត្រូវប្រគល់ឱ្យប្រភេទក្រុមប្រឹក្សាដែលសមស្រប ។

### មាត្រា ២២៤.-

មុខងារជាកាតព្វកិច្ច ដែលអនុវត្តដោយប្រភេទក្រុមប្រឹក្សាសមស្របណាមួយ តម្រូវឱ្យមានការចូលរួមចំណែកជាប្រចាំពីក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ទោះបីធនធានចាំបាច់ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារនោះ បានផ្ទេរឱ្យរួចហើយក្តី ។

មុខងារជាកាតព្វកិច្ចខាងលើនេះ ត្រូវធ្វើប្រតិភូកម្មដល់ប្រភេទក្រុមប្រឹក្សា ដែលសមស្រប ។

ROYAUME du CAMBODGE · LE MINISTRE du PALAIS ROYAL

**មាត្រា ២២៥.–**

ការប្រគល់ ឬ ការធ្វើប្រតិភូកម្ម មុខងារជាកាតព្វកិច្ច ត្រូវជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិដោយ :

-ផ្តល់ទៅឱ្យក្រុមប្រឹក្សានូវអំណាចជាអតិបរមា ដើម្បីឱ្យក្រុមប្រឹក្សាធ្វើការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារទាំងនោះ

-តម្រូវឱ្យក្រុមប្រឹក្សាគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារទាំងនោះដោយមានការឆ្លើយតប និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ២២៦.–**

មុខងារជាកាតព្វកិច្ចដែលបានធ្វើប្រតិភូកម្ម ក្រុមប្រឹក្សាត្រូវមានការទទួលខុសត្រូវចំពោះក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ដោយអនុលោមទៅតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ ។

## ផ្នែកទី ៤

## មុខងារជាជម្រើស

**មាត្រា ២២៧.–**

មុខងារដែលមិនមានលក្ខណៈជាកាតព្វកិច្ច គឺជាមុខងារដែលមានលក្ខណៈជាជម្រើស ។

**មាត្រា ២២៨.–**

មុខងារដែលមានលក្ខណៈជាជម្រើស ត្រូវប្រគល់ឱ្យប្រភេទក្រុមប្រឹក្សាណាមួយដែលសមស្រប ។

**មាត្រា ២២៩.–**

ក្រុមប្រឹក្សាត្រូវបន្តគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសបន្តពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល បន្ទាប់ពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលបានផ្ទេរឱ្យក្រុមប្រឹក្សា ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ២៣០.-**

ក្រុមប្រឹក្សា ត្រូវគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសក្នុងកម្រិតអតិបរ-មានៃលទ្ធភាព និងធនធានដែលបានផ្ទេរឱ្យខ្លួន ។

ក្នុងករណីដែលមុខងារជាជម្រើស មិនក្លាយទៅជាមុខងារជាកាតព្វកិច្ច ក្រុមប្រឹក្សាអាចស្នើទៅគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីធ្វើការកែប្រែ ឬ បញ្ឈប់ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារទាំងនោះ ។

ធនធានទាំងអស់ដែលបានផ្ទេរឱ្យក្រុមប្រឹក្សាដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើស ត្រូវរក្សាទុកជាធនធានរបស់ក្រុមប្រឹក្សា ហើយក្រុមប្រឹក្សាអាចចាត់ចែងធនធានទាំងនោះ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ២៣១.-**

ក្រុមប្រឹក្សាមានសិទ្ធិក្នុងការធ្វើសេចក្ដីសម្រេចទៅលើរបៀបគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើស ដោយអនុលោមទៅតាមបទដ្ឋាន និងនីតិវិធីដែលមានចែងនៅក្នុងច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាសជាធរមាន ។

**មាត្រា ២៣២.-**

ក្នុងករណីដែលក្រុមប្រឹក្សាសម្រេចធ្វើការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសដែលមិនធ្លាប់បានគ្រប់គ្រង ចាត់ចែង និងអនុវត្តពីមុនមក ដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល បទដ្ឋាន នីតិវិធី និងធនធានសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារនោះ ត្រូវសម្រេចដោយឆន្ទានុសិទ្ធិផ្ទាល់របស់ក្រុមប្រឹក្សា ។

## ផ្នែកទី ៥
## ការប្រគល់ និងការធ្វើប្រតិភូកម្មមុខងារ

**មាត្រា ២៣៣.-**

ការផ្ទេរមុខងារឱ្យប្រភេទក្រុមប្រឹក្សាណាមួយដែលសមស្របតាមការប្រគល់ ឬ តាមការធ្វើប្រតិភូកម្មត្រូវធ្វើឡើងតាមគោលការណ៍នៃការប្រគល់ ឬ ការធ្វើប្រតិភូកម្ម

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ជាលក្ខណៈអចិន្ត្រៃយ៍ ដោយមិនត្រូវធ្វើការប្រគល់ ឬ ធ្វើប្រតិភូកម្មជាលក្ខណៈបណ្តោះអាសន្នឡើយ ។

### មាត្រា ២៣៤.-

ការផ្ទេរធនធានដែលចាំបាច់ឱ្យប្រភេទក្រុមប្រឹក្សាណាមួយដែលសមស្រប ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារណាមួយ ត្រូវធ្វើឡើងតាមគោលការណ៍ជាលក្ខណៈអចិន្ត្រៃយ៍ ដោយមិនត្រូវធ្វើការផ្ទេរជាលក្ខណៈបណ្តោះអាសន្នឡើយ ។

### មាត្រា ២៣៥.-

ក្នុងការប្រគល់ ឬ ការធ្វើប្រតិភូកម្មមុខងារជាកាតព្វកិច្ច ឬ មុខងារជាជម្រើសដែលក្រសួង ស្ថាប័នណាមួយរបស់រាជរដ្ឋាភិបាលធ្លាប់បានគ្រប់គ្រង ចាត់ចែង និងអនុវត្តពីមុនមកទៅឱ្យប្រភេទក្រុមប្រឹក្សាណាមួយដែលសមស្រប គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវកំណត់ជាមុននូវធនធាន និងការអភិវឌ្ឍសមត្ថភាព ដើម្បីក្រុមប្រឹក្សាបន្តគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារនោះ ។

### មាត្រា ២៣៦.-

ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារណាមួយឱ្យមានប្រសិទ្ធភាព និងមានចីរភាព គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឬ ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលអាចប្រគល់ ឬ ធ្វើប្រតិភូកម្មឱ្យក្រុមប្រឹក្សាពីរ ឬ ច្រើន ដោយកំណត់អំពីធនធានដែលត្រូវចែករំលែកជាមួយគ្នា និងត្រូវរួមចំណែកជាមួយគ្នា ដោយរួមទាំងបុគ្គលិកជំនាញនៅក្នុងចំណោមក្រុមប្រឹក្សាទាំងនោះផង ។

### មាត្រា ២៣៧.-

មុខងារដែលបានប្រគល់ ឬ ដែលបានធ្វើប្រតិភូកម្ម គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវពិនិត្យឡើងវិញ ដើម្បីធ្វើការកែសម្រួលមុខងារណាមួយ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន

របស់រាជរដ្ឋាភិបាល និងជាមួយក្រុមប្រឹក្សាពាក់ព័ន្ធក្នុងករណីដែល :

-មុខងារដែលបានប្រគល់ គួរត្រូវបានធ្វើប្រតិភូកម្ម

-មុខងារដែលបានធ្វើប្រតិភូកម្ម គួរត្រូវបានប្រគល់

-មុខងារជាកាតព្វកិច្ច គួរ ឬ បានក្លាយទៅជាមុខងារជាជម្រើស ឬ

-មុខងារជាជម្រើស គួរ ឬ បានក្លាយទៅជាមុខងារជាកាតព្វកិច្ច ។

**មាត្រា ២៣៨.-**

ការប្រគល់មុខងារ ឬ ការធ្វើប្រតិភូកម្មមុខងារ ត្រូវធ្វើឡើងដោយច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាស ។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវពិនិត្យមើលឡើងវិញនូវច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ដែលពាក់ព័ន្ធនឹងការប្រគល់មុខងារ ឬ ការធ្វើប្រតិភូកម្មមុខងារ ដើម្បីបំពេញបែបបទធ្វើវិសោធនកម្មឱ្យស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ២៣៩.-**

ការប្រគល់មុខងារ ឬ ការធ្វើប្រតិភូកម្មមុខងារ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដើម្បីដាក់ចេញសេចក្តីសម្រេចដែលបញ្ជាក់ :

-ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាសដែលបានធ្វើការប្រគល់ ឬ ធ្វើប្រតិភូកម្ម

-កាលបរិច្ឆេទចូលជាធរមាននូវការប្រគល់ ឬ ការធ្វើប្រតិភូកម្ម

-កំណត់បញ្ជាក់មុខងារនោះ មានលក្ខណៈជាកាតព្វកិច្ច ឬ ជាជម្រើស

-កំណត់បញ្ជាក់មុខងារនោះ ជាមុខងារត្រូវបានប្រគល់ ឬ ធ្វើប្រតិភូកម្ម ។

**មាត្រា ២៤០.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវផ្តល់ច្បាប់ចម្លងនៃច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាស និងសេចក្តី

សម្រេចរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដល់ ៖

-ក្រុមប្រឹក្សាដែលត្រូវបានប្រគល់មុខងារ ឬ ផ្ទេរប្រតិភូកម្មមុខងារ

-ក្រុមប្រឹក្សាផ្សេងៗទៀត

-ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលបានគ្រប់គ្រងលើមុខងារនោះពីមុនមក

-ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ។

## ផ្នែកទី ៦

## របបហិរញ្ញវត្ថុរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### មាត្រា ២៤១.-

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅទៅលើថវិការបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា ៤៤ នៃច្បាប់នេះ ។

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរួមចំណែកដល់ការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

### មាត្រា ២៤២.-

ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ត្រូវមានធនធានហិរញ្ញវត្ថុសមស្រប ដើម្បី ៖

-គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ចរបស់ខ្លួន

-ធ្វើការជ្រើសរើសក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសរបស់ខ្លួន

-អនុវត្តតួនាទី ភារកិច្ចតាមច្បាប់កំណត់

-ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន និង

-អនុវត្តមុខងារ ភារកិច្ច សម្រាប់ជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ២៤៣.-**

ក្រុមប្រឹក្សា ត្រូវគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាពនិង គណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន និងចំពោះរាជរដ្ឋាភិបាល ។

**មាត្រា ២៤៤.-**

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុកមានសិទ្ធិទទួល បានចំណូលពីប្រភពនៅមូលដ្ឋាន ពីប្រភពនៅថ្នាក់ជាតិ និងពីប្រភពផ្សេងៗទៀតដោយ អនុលោមទៅតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាល ថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសា-ធារណៈ ។

ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ ត្រូវមានថវិកាសម្រាប់អនុវត្តមុខងារភារ-កិច្ចរបស់ខ្លួន ដែលស្ថិតនៅក្នុងថវិការាជធានី និងថវិកាក្រុង ។

**មាត្រា ២៤៥.-**

អភិបាល គឺជាអាណាប័កក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ។

គណៈអភិបាលមានភារកិច្ចក្នុងការរៀបចំផែនការអភិវឌ្ឍកម្មវិធីវិនិយោគបី(០៣) ឆ្នាំរំកិលប្រចាំឆ្នាំ គម្រោងថវិកា និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដើម្បីដាក់ជូន ក្រុមប្រឹក្សាពិនិត្យ និងអនុម័ត ។

បែបបទ និងនីតិវិធីនៃការរៀបចំ ការអនុម័ត ការអនុវត្ត និងការទូទាត់ថវិកានៃរដ្ឋ-បាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យ សម្បត្តិនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

**មាត្រា ២៤៦.-**

ចំណូលពីប្រភពនៅមូលដ្ឋានរួមមាន :

-ពន្ធនៅមូលដ្ឋាន

-ឈ្នួល កម្រៃ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

-ចំណូលរបស់ក្រុមប្រឹក្សាស្រុក បានមកពីពន្ធ ឈ្នួល និងកម្រៃ ដែលត្រូវចែករំលែករវាងក្រុមប្រឹក្សាស្រុក ជាមួយក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក

-អំណោយស្ម័គ្រចិត្ត

-ប្រភពផ្សេងទៀតដែលកំណត់ដោយច្បាប់ ឬ អនុក្រឹត្យ ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត ។

ពន្ធ និងអាករនៅថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ក្នុងក្របខ័ណ្ឌច្បាប់ស្តីពីច្បាប់សារពើពន្ធ ។

**មាត្រា ២៤៧.-**

ចំណូលពីថ្នាក់ជាតិ រួមមាន :

-ចំណូលចែករំលែក

-មូលនិធិផ្ទេរពីថវិការដ្ឋ និង

-ថ្លៃសេវាបានមកពីមុខងារជាភ្នាក់ងារ ដែលអនុវត្តដោយក្រុមប្រឹក្សាក្នុងនាមក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ។

**មាត្រា ២៤៨.-**

ការបែងចែកចំណូលដែលបានមកពីថ្លៃចេញអាជ្ញាប័ណ្ណអាជីវកម្ម ពីកម្រៃសេវានិងពីចំណូលមិនមែនសារពើពន្ធដទៃទៀតរវាងស្រុក ឃុំ និងសង្កាត់ក្នុងស្រុក ត្រូវកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ២៤៩.-**

ក្រុមប្រឹក្សាមានសិទ្ធិទទួលពីចំណូលជាតិនូវមូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌនិងមូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ ។

ការផ្ទេរមូលនិធិពីថវិការដ្ឋ រួមមានមូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌនិងមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌពីថ្នាក់ជាតិដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងជាដំណាក់កាលៗសម្រាប់ឆ្នាំនីមួយៗ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ២៥០.-**

មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌគឺជាមូលនិធិដែលក្រុមប្រឹក្សាត្រូវប្រើប្រាស់ :

-ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ចមួយ ឬ ច្រើនដែលត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សា តាមការប្រគល់មុខងារ ឬ ការធ្វើប្រតិភូកម្មមុខងារ ឬ

-ដើម្បីបន្តគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសមួយ ឬ ច្រើនដែលក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលធ្លាប់បានអនុវត្ត ឬ

-សម្រាប់គោលបំណងជាកាតព្វកិច្ចមួយ ឬ ច្រើនដែលបានកំណត់ ។

**មាត្រា ២៥១.-**

មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌគឺជាមូលនិធិដែលក្រុមប្រឹក្សា ត្រូវប្រើប្រាស់ដើម្បី :

-បំពេញភារកិច្ចតាមផ្លូវច្បាប់

-បំពេញមុខងារ ភារកិច្ច ក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

-ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន និង

-ជ្រើសរើស គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសនានា ។

**មាត្រា ២៥២.-**

ក្រុមប្រឹក្សាគ្មានសិទ្ធិខ្ចីប្រាក់ បោះផ្សាយសញ្ញាប័ណ្ណ ឬ/និងមូលប័ត្រ ធានាគ្រប់កិច្ចសន្យា និងប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុណាមួយដែលនាំឱ្យកើតជាបំណុល ។

**មាត្រា ២៥៣.-**

ក្នុងការរៀបចំរបបហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ បែបបទ និងនីតិវិធីនៃការរៀបចំ ការអនុម័ត និងការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំប្រភពចំណូលរួមមាន ចំណូលពីថ្នាក់ជាតិ និងចំណូលនៅមូលដ្ឋាន ការផ្ទេរការឧបត្ថម្ភថវិការួមមានមូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ និងមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌពីថ្នាក់ជាតិទៅក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ការផ្ទេរទ្រព្យសម្បត្តិរដ្ឋ ការចាត់ចែង ការគ្រប់គ្រងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋដែលប្រគល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនិងទ្រព្យសម្បត្តិ

ដែលក្រុមប្រឹក្សារកបានដោយខ្លួនឯង គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវធ្វើការពិគ្រោះពិភាក្សាសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានាតាមការចាំបាច់ ដើម្បីបំពេញការងារខាងលើនេះ ដោយមានផែនការជាជំហានៗមានសនិទានភាព មានការសម្របសម្រួល មានការពិគ្រោះយោបល់ មានតម្លាភាព និងមានគណនេយ្យភាព ។

## ផ្នែកទី ៧
## ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

### មាត្រា ២៥៤.-

ដើម្បីធានាឱ្យក្រុមប្រឹក្សាមានលទ្ធភាពអនុវត្តមុខងារភារកិច្ចរបស់ខ្លួន ផ្អែកតាមច្បាប់នេះ ចាំបាច់ត្រូវផ្តល់លទ្ធភាពឱ្យក្រុមប្រឹក្សាទទួលបាននូវទ្រព្យសម្បត្តិចាំបាច់នានា ។

ទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ទ្រព្យសម្បត្តិរដ្ឋដែលបានផ្ទេរឱ្យ និងទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯង ដែលក្នុងផ្នែកនេះហៅថាទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

### មាត្រា ២៥៥.-

ទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានផ្ទេរឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រងនិងប្រើប្រាស់ និងទាញយកផលចំណូលពីទ្រព្យសម្បត្តិទាំងនោះ ។

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវថែរក្សាការពារទ្រព្យសម្បត្តិដែលរដ្ឋប្រគល់ឱ្យគ្រប់គ្រងឱ្យបានគង់វង្ស ហើយរដ្ឋបាលថ្នាក់ក្រោមជាតិគ្មានសិទ្ធិលក់ដូរ ឬ ផ្ទេរកម្មសិទ្ធិ ឬ ផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះ ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ ។

ការត្រួតពិនិត្យ ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិរកបានដោយខ្លួនឯង ត្រូវកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា ២៥៦.–**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលឱ្យមានការផ្ទេរទ្រព្យសម្បត្តិ ស្របពេលជាមួយនឹងការពិនិត្យមើលឡើងវិញនូវការទទួលខុសត្រូវតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់នេះ និងត្រូវធ្វើឡើងទៅតាមរបៀបដែលមានផែនការ មានវិចារណភាព មានការពិគ្រោះយោបល់ និងមានតម្លាភាព ។

**មាត្រា ២៥៧.–**

ក្នុងការផ្ទេរទ្រព្យសម្បត្តិ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិអាចកំណត់ឱ្យក្រុមប្រឹក្សាពីរ ឬ ច្រើនប្រើប្រាស់រួមគ្នានូវទ្រព្យសម្បត្តិណាមួយ ដើម្បីក្រុមប្រឹក្សាទាំងនោះបំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព ។

**មាត្រា ២៥៨.–**

ក្នុងករណីដែលក្រុមប្រឹក្សាបានទទួលមុខងារមួយ ឬ ច្រើន ប៉ុន្តែទ្រព្យសម្បត្តិចាំបាច់សម្រាប់ចាត់ចែងមុខងារនោះមានបរិមាណមិនគ្រប់គ្រាន់ ឬ គ្មានតែម្តង ក្រុមប្រឹក្សាត្រូវទទួលបានធនធានហិរញ្ញវត្ថុ ដើម្បីដោះស្រាយមធ្យោបាយចាំបាច់សម្រាប់បំពេញសេចក្តីត្រូវការរបស់ខ្លួន ។

**មាត្រា ២៥៩.–**

ការផ្ទេរទ្រព្យសម្បត្តិត្រូវមានឯកសារផ្លូវច្បាប់សម្រាប់ផ្ទេរសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិទៅឱ្យក្រុមប្រឹក្សា ប្រសិនបើទ្រព្យសម្បត្តិនោះមានប័ណ្ណសម្គាល់កម្មសិទ្ធិ ។

ក្នុងករណីដែលទ្រព្យសម្បត្តិណាមួយមិនមានប័ណ្ណសម្គាល់កម្មសិទ្ធិ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដែលគ្រប់គ្រងទ្រព្យសម្បត្តិនោះរួចហើយ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវដាក់ចេញសេចក្តីសម្រេចដែលកំណត់អំពី :

-ទ្រព្យសម្បត្តិដែលត្រូវផ្ទេរ

-ប្រភេទក្រុមប្រឹក្សាដែលទទួលទ្រព្យសម្បត្តិ

-ក្រុមប្រឹក្សាជាក់លាក់ដែលទទួលទ្រព្យសម្បត្តិ

-ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ឬ មន្ទីរ អង្គភាពនានាថ្នាក់ក្រោមជាតិដែលត្រូវប្រគល់ទ្រព្យសម្បត្តិដល់ក្រុមប្រឹក្សា និង

-កាលបរិច្ឆេទដែលត្រូវប្រគល់ទ្រព្យសម្បត្តិឱ្យក្រុមប្រឹក្សា ។

សេចក្តីសម្រេចខាងលើនេះ អាចផ្ទេរទ្រព្យសម្បត្តិមួយ ឬ ច្រើន ឬ អាចផ្ទេរទ្រព្យសម្បត្តិទាំងអស់ក្នុងប្រភេទណាមួយក៏បាន ។

**មាត្រា ២៦០.-**

ក្នុងករណីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ឬ មន្ទីរ អង្គភាពនានាថ្នាក់ក្រោមជាតិមិនបានប្រគល់ទ្រព្យសម្បត្តិ ស្របតាមការកំណត់ក្នុងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឬ មិនបានរៀបចំឯកសារផ្លូវច្បាប់ឱ្យបានត្រឹមត្រូវសម្រាប់ផ្ទេរកម្មសិទ្ធិ ក្រុមប្រឹក្សាត្រូវរាយការណ៍បញ្ហានេះជាបន្ទាន់ជូន គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

**មាត្រា ២៦១.-**

ក្រុមប្រឹក្សាត្រូវរៀបចំគម្រោងថែទាំទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយបញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីធានាប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះ ។

ក្រុមប្រឹក្សាត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ២៧៣.-**

បែបបទ និងនីតិវិធីនៃការពិនិត្យ និងការកែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិក ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

## ជំពូកទី ៦
## អំពីទោសប្បញ្ញត្តិ

**មាត្រា ២៧៤.-**

សមាជិកក្រុមប្រឹក្សា គណៈអភិបាល នាយករដ្ឋបាល និងបុគ្គលិករបស់ក្រុមប្រឹក្សា ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលវិន័យដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត ។

**មាត្រា ២៧៥.-**

វិន័យដែលត្រូវអនុវត្តចំពោះសមាជិកក្រុមប្រឹក្សាដែលបានប្រព្រឹត្តនូវកំហុស ត្រូវផ្អែកតាមគោលការណ៍នៃបទប្បញ្ញត្តិដូចមានចែងក្នុងចំណុចទី ៤ ចំណុចទី ៥ មាត្រា ២២ នៃច្បាប់នេះ ។

**មាត្រា ២៧៦.-**

វិន័យដែលត្រូវអនុវត្ត ចំពោះគណៈអភិបាល នាយករដ្ឋបាល បុគ្គលិកក្រុមប្រឹក្សា ត្រូវផ្អែកតាមគោលការណ៍នៃបទប្បញ្ញត្តិដូចមានចែងក្នុងចំណុចទី ៣ និងចំណុចទី ៦ មាត្រា ១៥១ នៃច្បាប់នេះ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងលក្ខន្តិកៈដោយឡែករបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ។

ROYAUME DU CAMBODGE • LE MINISTRE du PALAIS ROYAL

# ជំពូកទី ៧
# អំពីអន្តរប្បញ្ញត្តិ
## ផ្នែកទី ១
## ការផ្ទេរសិទ្ធិ និងការទទួលខុសត្រូវ

**មាត្រា ២៧៧.-**

រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌដែលត្រូវបានបង្កើតឡើងដោយច្បាប់នេះនឹងជំនួសរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ នាពេលបច្ចុប្បន្ននេះ ។

**មាត្រា ២៧៨.-**

អភិបាលរាជធានី អភិបាលខេត្ត អភិបាលក្រុង អភិបាលខណ្ឌ អភិបាលស្រុកដែលបានតែងតាំងឡើងនៅមុនពេលច្បាប់នេះចូលជាធរមាន ត្រូវបន្តស្ថិតក្នុងមុខតំណែងនិងបំពេញការងាររហូតដល់មានក្រុមប្រឹក្សា និងគណៈអភិបាលដែលបានរៀបចំឡើងស្របតាមច្បាប់នេះមកជំនួស ។

**មាត្រា ២៧៩.-**

ការតែងតាំងគណៈអភិបាលសម្រាប់ក្រុមប្រឹក្សាអាណត្តិទី ១ នេះ ត្រូវធ្វើឡើងយ៉ាងយូរដប់បួន(១៤)ថ្ងៃ បន្ទាប់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត "គ.ជ.ប." ប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានីមួយៗនោះ ។

**មាត្រា ២៨០.-**

ដីកា លិខិតបទដ្ឋាន កិច្ចសន្យា កិច្ចព្រមព្រៀង ការងារ ទ្រព្យសម្បត្តិ ចំណូល និងប្រាក់ទាំងអស់ដែលអនុវត្ត ឬ ដែលបានកាន់កាប់ដោយ ឬ ក្នុងនាមរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ នៅមុនពេលច្បាប់នេះចូលជាធរមាន ដីកា លិខិតបទដ្ឋាន កិច្ចសន្យា កិច្ចព្រមព្រៀង ការងារ ទ្រព្យសម្បត្តិ ចំណូល និងប្រាក់ទាំងអស់នោះត្រូវអនុវត្ត និងចាត់ចែងបន្តដោយរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ ។

ROYAUME du CAMBODGE • LE MINISTRE du PALAIS ROYAL
ព្រះរាជវាំង

**មាត្រា ២៨១.-**

អង្គភាព និងមន្ត្រីបុគ្គលិកដែលបំពេញការងារក្នុងអង្គភាពរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ នៅមុនពេលច្បាប់នេះចូលជាធរមាន ត្រូវបន្តជាអង្គភាព និងជាមន្ត្រីបុគ្គលិកនៃអង្គភាពទាំងនោះរបស់រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ រហូតដល់មានការរៀបចំជាថ្មី ។

**មាត្រា ២៨២.-**

ក្រសួងមហាផ្ទៃ ត្រូវធ្វើការកំណត់ និងកត់ត្រានូវការផ្ទេរ និងការទទួលយកនូវសិទ្ធិ កាតព្វកិច្ចទាំងអស់ កម្មសិទ្ធិ ទ្រព្យសម្បត្តិ ចំណូល និងប្រាក់ ព្រមទាំងអង្គភាព បុគ្គលិក ពីរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ បច្ចុប្បន្នជូនទៅរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ ឱ្យបានសមស្រប និងមានតម្លាភាព ។

## ផ្នែកទី ២
## ក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ២៨៣.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបន្តអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា លើកលែងតែគោលការណ៍ដូចមានចែងក្នុងមាត្រា ៨៨ គោលការណ៍នៃផ្នែកទី ៦ ផ្នែកទី ៧ ផ្នែកទី ៨ ផ្នែកទី ៩ នៃជំពូកទី ២ និងគោលការណ៍នៃជំពូកទី ៥ នៃច្បាប់នេះ ។

**មាត្រា ២៨៤.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវរៀបចំលិខិតបទដ្ឋានសម្រាប់គាំទ្រឃុំ សង្កាត់ ដើម្បីអនុវត្តបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៨៨ គោលការណ៍នៃផ្នែកទី ៦ ផ្នែកទី ៧ ផ្នែកទី ៨ ផ្នែកទី ៩ នៃជំពូកទី ២ និងគោលការណ៍នៃជំពូកទី ៥ នៃច្បាប់នេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវពិនិត្យឡើងវិញនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ដើម្បីស្នើធ្វើវិសោធនកម្ម ឬ ដាក់ចេញនូវលិខិតបទដ្ឋានថ្មី ឱ្យសមស្របសម្រាប់ទ្រទ្រង់ដល់គោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលចែងក្នុងច្បាប់នេះ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ២៨៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៨៦.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០៨

នស/រកម.០៥០៥.៥៩៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខ: ៥៥៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៨

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

នស / រកម / ០៣០១ / ០៥

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤នៃរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ ពីសម្តេចនាយករដ្ឋមន្ត្រី និង ពីសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី០១ខែ កុម្ភៈ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី៤ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៤១/ ០០៣ / ២០០១ កបធ.ច ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ : ៕

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងរដ្ឋបាល

# ឃុំ សង្កាត់

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាតាមនយោបាយវិមជ្ឈការ ។

**មាត្រា ២.-**

ឃុំ សង្កាត់ជានីតិបុគ្គល ។

**មាត្រា ៣.-**

ប្រព័ន្ធនៃអភិបាលកិច្ចមូលដ្ឋានត្រូវអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ។

**មាត្រា ៤.-**

អំណាចដឹកនាំនិងគ្រប់គ្រងឃុំ សង្កាត់បានមកដោយការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ក្នុងក្របខ័ណ្ឌនៃឃុំ សង្កាត់នីមួយៗ ។

**មាត្រា ៥.-**

ឃុំ សង្កាត់គ្រប់គ្រងកិច្ចការមូលដ្ឋានក្នុងដែនដីរបស់ខ្លួនដោយផ្អែកទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

អំណាចបញ្ញត្តិ អំណាចប្រតិបត្តិក្នុងការគ្រប់គ្រងមូលដ្ឋានត្រូវផ្តល់ឱ្យឃុំ សង្កាត់ ហើយអំណាចនេះត្រូវអនុវត្តស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ ។

**មាត្រា ៦.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ក្នុងករណីមិនប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ត្រូវសម្រេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងករណីដែលមានការប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ត្រូវ៤ះ.

សំរេចដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ផ្អែកលើសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧.-**

កាលបើមានផលវិបាកណាមួយកើតឡើង ក្រោយពេលដែលឃុំ សង្កាត់ ត្រូវបានបង្កើត លុបចោលឬកែសម្រួល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសដើម្បីដោះស្រាយផលវិបាកនោះស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៨.-**

ឃុំ សង្កាត់ណាដែលមិនអាចដំណើរការរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានដោយករណីប្រធានសក្តិ រាជរដ្ឋាភិបាលត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា។

បន្ទាប់ពីបានរាយការណ៍ជូនរដ្ឋសភារួចហើយ រាជរដ្ឋាភិបាលត្រូវចាត់ឱ្យក្រសួងមហាផ្ទៃរៀបចំគ្រប់គ្រងឃុំ សង្កាត់ទាំងនោះជាបណ្តោះអាសន្ន ហើយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះនឹងត្រូវដំណើរការ នៅពេលស្ថានការណ៍ឃុំ សង្កាត់ទាំងនេះមានប្រក្រតីភាពឡើងវិញ ។

## ជំពូកទី ២
## ក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ៩.-**

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយហៅថាក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបំរើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ១០.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោត ដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនស្របទៅតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ល។

**មាត្រា ១១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង ។

ក្នុងតំណាក់កាលអន្តរកាលនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ដែលផុតអាណត្តិមានភារកិច្ចសំរួលកិច្ចការប្រចាំថ្ងៃតែប៉ុណ្ណោះ ។

**មាត្រា ១២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកចំនួនពី ៥ ទៅ ១១រូប ផ្អែកតាមប្រជា-សាស្ត្រនិងភូមិសាស្ត្ររបស់ខ្លួន ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាតាមឃុំ សង្កាត់នីមួយៗត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានកំណត់រួចហើយ អាចធ្វើការផ្លាស់ប្តូរបានដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាស្រ័យដោយការផ្លាស់ប្តូរនៃប្រជាសាស្ត្រនិងភូមិសាស្ត្រ ។

សមាជិកបន្ថែមនៃក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសតាមនីតិវិធីដូចសមា-ជិកដទៃទៀតដែរ ។

**មាត្រា ១៣.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានម្នាក់ហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ច :

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ធានាឱ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ធានាឱ្យសម័យប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដំណើរការបានត្រឹមត្រូវទៅតាមវិធាននិងបទបញ្ជាដូចបានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ និងបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា២៣ នៃច្បាប់នេះ
- រក្សារបៀបរៀបរយនិងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ ។ល។

## មាត្រា ១៤.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិនិងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញល័ក្ខខ័ណ្ឌសំខាន់ៗដូចខាងក្រោម :

- មានសញ្ជាតិខ្មែរពីកំណើត
- ចេះអាននិងសរសេរអក្សរខ្មែរ
- បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមល័ក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

## មាត្រា ១៥.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ។

## មាត្រា ១៦.-

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយក្នុងចំណោមករណីដូចខាងក្រោម :

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច
- សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ
- សមាជិកត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៨៤នៃច្បាប់នេះ ៕

- ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលត្រូវរំសាយ

- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

កាលបើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយត្រូវបាត់បង់សមាជិកភាព ត្រូវជ្រើសរើសបេក្ខជនដែលមានឈ្មោះបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ ។

**មាត្រា ១៧.-**

ត្រូវរៀបចំធ្វើការបោះឆ្នោតឡើងវិញក្នុងរយៈពេល ១២០ថ្ងៃយ៉ាងយូរ ដើម្បីធ្វើការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីណាមួយដូចខាងក្រោម :

- ឃុំ សង្កាត់ដែលបង្កើតថ្មីតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរំសាយចោលតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៥៧ និងមាត្រា ៥៨ នៃច្បាប់នេះ ។

ការបោះឆ្នោតឡើងវិញដូចមានចែងខាងលើនេះត្រូវបាត់ចែងធ្វើឡើង អនុលោមទៅតាមបែបបទនិងនីតិវិធីដែលបានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះមានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានរយៈពេលមិនលើសពី ១៨០ថ្ងៃ ។

ក្នុងរយៈពេលនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវតែងតាំងសមាសភាពនិងកំណត់អំពីសមត្ថកិច្ច របៀបរបបដឹកនាំគ្រប់គ្រងឃុំ សង្កាត់នោះ រហូតដល់មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

**មាត្រា ១៨.-**

ការកែប្រែព្រំប្រទល់របស់ឃុំ សង្កាត់ណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការកែប្រែនោះ ពុំបណ្តាលឱ្យផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ។ល។

ការបង្កើតឃុំ សង្កាត់ថ្មីណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការបង្កើតនោះពុំបណ្តាលឱ្យមានផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សានៃឃុំ សង្កាត់ដែលពាក់ព័ន្ធ ។

ក្នុងករណីឃុំ សង្កាត់ដែលត្រូវបង្កើតថ្មី ដែលត្រូវលុបចោល ដែលត្រូវកែប្រែព្រំប្រទល់ ហើយបណ្តាលឱ្យមានការផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ ត្រូវចូលជាធរមានសំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិបន្ទាប់ ។

**មាត្រា ១៩.-**

ក្នុងអំឡុងពេល ១៤ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ត្រូវចាត់ឱ្យមានការប្រជុំជាលើកដំបូងនៃក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមអធិបតីភាពមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់និងប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់និងចៅសង្កាត់រង ។

**មាត្រា ២០.-**

មុនចាប់ផ្តើមការងារ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំនិងអនុម័តបទបញ្ជាផ្ទៃក្នុងដើម្បីកំណត់នូវវិធានទាំងឡាយសំរាប់អង្គប្រជុំនិងរបៀបរបបធ្វើការងាររបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីគោលការណ៍នានាសំរាប់ជាមូលដ្ឋានដល់ការរៀបចំបទបញ្ជាផ្ទៃក្នុងខាងលើនេះ ។

**មាត្រា ២១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំយ៉ាងតិចណាស់ចំនួនមួយដងក្នុងមួយខែ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំក្នុងសាលាឃុំ ឬសាលាសង្កាត់របស់ខ្លួន ឬក្នុងករណីចាំបាច់អធិបតីនៃអង្គប្រជុំអាចជ្រើសយកទីកន្លែងណាមួយក្នុងឃុំ សង្កាត់របស់ខ្លួនដើម្បីប្រជុំ ។ /.

**មាត្រា ២២.-**

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ នឹងយកជាការបាន លុះត្រាតែមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលចូលរួម ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការបោះឆ្នោតអនុម័តដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាទាំងមូល ដើម្បីសំរេចបញ្ហាណាមួយដូចខាងក្រោម :

- អនុម័តលើគំរោងផែនការអភិវឌ្ឍឃុំ សង្កាត់
- អនុម័តលើគំរោងថវិកាឃុំ សង្កាត់
- កំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាននិងកំរៃសេវាផ្សេងៗ
- អនុម័តបទបញ្ញាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងពេលអនុម័ត ប្រសិនបើមានសំឡេងឆ្នោតស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព ។

**មាត្រា ២៣.-**

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើជាសាធារណៈនិងមានលក្ខណៈប្រជាធិបតេយ្យ ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រជុំជាសម្ងាត់បាន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីរបៀបរបបប្រជុំខាងលើនេះ ។

**មាត្រា ២៤.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានសេរីភាពក្នុងការបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បានឡើយ ។៚

## ជំពូកទី ៣
## រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

**មាត្រា ២៥.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ ។

**មាត្រា ២៦.-**

មេឃុំ ចៅសង្កាត់មានអ្នកជំនួយការដូចខាងក្រោម :

ចំពោះមេឃុំ អ្នកជំនួយការមានពីររូប :

-ជំទប់ទី ១ មួយរូប

-ជំទប់ទី ២ មួយរូប ។

ចំពោះចៅសង្កាត់ អ្នកជំនួយការមានពីររូប :

-ចៅសង្កាត់រងទី ១ មួយរូប

-ចៅសង្កាត់រងទី ២ មួយរូប ។

**មាត្រា ២៧.-**

មេឃុំ ចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានាដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានាតាមការចាំបាច់ ។

គណៈកម្មាធិការខាងលើនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឱ្យធ្វើជាប្រធានក៏បាន ។

**មាត្រា ២៨.-**

ឃុំ សង្កាត់ត្រូវមានបុគ្គលិកក្របខ័ណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃមួយរូបធ្វើជាស្មៀនឃុំ សង្កាត់ ។

ស្មៀនឃុំ សង្កាត់តែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលមានភារកិច្ចជួយកិច្ចការឃុំ សង្កាត់ និងធានានិរន្តរភាពកិច្ចការរដ្ឋបាលក្នុងឃុំ សង្កាត់ ។៚

ស្មៀនឃុំ សង្កាត់ត្រូវផ្លាស់ប្តូរក្នុងករណីមានសំណើរបស់មេឃុំ ចៅសង្កាត់អនុលោមតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២៩.-**

ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋដើម្បីជួយកិច្ចការរបស់ខ្លួនតាមសេចក្តីត្រូវការនិងការចាំបាច់នៃការងារនិងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់ ។

**មាត្រា ៣០.-**

ក្នុងគោលដៅលើកកំពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់ សំរាប់ភូមិនីមួយៗ ចំណុះឃុំ សង្កាត់របស់ខ្លួន ។

មេភូមិត្រូវរៀបចំចាត់តាំងឱ្យមានអនុប្រធានមួយរូបនិងសមាជិកមួយរូបជាជំនួយការ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិនិងការតែងតាំងជំនួយការមេភូមិ ។

**មាត្រា ៣១.-**

មេភូមិមានភារកិច្ច ៖

- អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ប្រគល់ឱ្យដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិ
- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិរបស់ខ្លួន
- ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ដើម្បីចាត់ចែងនិងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំបន្ថែមអំពីរបៀបរបបធ្វើការងារនិងភារកិច្ចរបស់ភូមិឱ្យបានសមស្រប ។ល។

**មាត្រា ៣២.-**

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវជ្រើសរើសចេញពីបេក្ខជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេបង្អស់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់មានអាណត្តិស្មើនឹងអាណត្តិរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៣៣.-**

ជំទប់ទី ១ ចៅសង្កាត់រងទី ១ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ២ ។

ជំទប់ទី ២ ចៅសង្កាត់រងទី ២ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ៣ ។

**មាត្រា ៣៤.-**

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែមួយដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈទាំងអស់ក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាពីក្នុងបញ្ជីតែមួយនោះឱ្យទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។

**មាត្រា ៣៥.-**

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែពីរដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាជាបេក្ខជន ដែលមានឈ្មោះលេខរៀងបន្ទាប់ពីបេក្ខជនដែលមានឈ្មោះលេខរៀងលំដាប់លើគេបង្អស់នៃបញ្ជីដែលបានទទួលសម្លេងឆ្នោតគាំទ្រលំដាប់ទីមួយ ឱ្យទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ និងជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះលេខរៀងលើគេបង្អស់ នៃបញ្ជីដែលបានទទួលសម្លេងគាំទ្រលំដាប់ទី ២ ឱ្យទទួលតំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។ល។

**មាត្រា ៣៦.-**

តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវបាត់បង់ក្នុងករណីសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សាឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យ-ខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។

**មាត្រា ៣៧.-**

មុខតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មុខតំណែងមេឃុំ ចៅសង្កាត់និងមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ កាលបើមុខតំណែងណាមួយត្រូវបាត់បង់ មុខតំណែងទាំងអស់ខាងលើរបស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៅក្នុងបញ្ជីរួមជាមួយអតីតប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ ដែលបានបាត់បង់ពីមុខតំណែងនោះ ឱ្យទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់និងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មី ជំនួសកន្លែងដែលទំនេរតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីដែលបញ្ជីបេក្ខជនត្រូវកាន់កាប់តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់អស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចេញពីក្នុងបញ្ជីបេក្ខជនជាមួយ ផ្អែកតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យ-ខ័ណ្ឌទី ២ មាត្រា ១៦ នៃច្បាប់នេះនិងបាត់ឱ្យសមាជិកក្រុមប្រឹក្សារូបនេះទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ជំនួសប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះ ការបាត់បង់ពីមុខតំណែងនិងការទទួលតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៨.-**

តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបាត់បង់ពីមុខតំណែង ក្នុងករណីដែលសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សា ឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។ល។

ក្នុងករណីតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបានបាត់បង់ មុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៃបញ្ជីបេក្ខជនរួមជាមួយជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ឱ្យទទួលតំណែងជំនួសជំទប់ ឬចៅសង្កាត់រងដែលបានបាត់បង់ពីមុខតំណែងនិងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មីជំនួសកន្លែងដែលទំនេរ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីបញ្ជីបេក្ខជនដែលត្រូវកាន់កាប់តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ អស់សមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសបេក្ខជនពីក្នុងបញ្ជីនោះបញ្ចូលជាសមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ និងប្រគល់ឱ្យសមាជិកក្រុមប្រឹក្សារូបនោះទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ជំនួសតំណែងជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះនិងល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ការបាត់បង់មុខតំណែងនិងការទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៩.-**

មេឃុំ ចៅសង្កាត់បំពេញតួនាទីភារកិច្ចដូចខាងក្រោម :

- អនុវត្តសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អនុវត្តនូវបទប្បញ្ញត្តិនិងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពការងារជូនក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនយ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ផ្តល់យោបល់ផ្សេងៗនិងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំផែនការហិរញ្ញវត្ថុនិងក្នុងការចាត់ចែងអនុវត្តនូវតួនាទី មុខងារ សិទ្ធិអំណាចរបស់ក្រុម

ប្រឹ.

ប្រឹក្សាឃុំ សង្កាត់ ព្រមទាំងកិច្ចការផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនប្រគល់ឱ្យ ។

មាត្រា ៤០.-

ជំទប់ ឬចៅសង្កាត់រងជាជំនួយការរបស់មេឃុំ ចៅសង្កាត់ក្នុងការអនុវត្តភារកិច្ចដែលមេឃុំ ចៅសង្កាត់ប្រគល់ឱ្យនិងជំនួសមេឃុំ ចៅសង្កាត់ទៅតាមឋានានុក្រមនៃជំទប់ ចៅសង្កាត់រង នៅពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន ។

ជំទប់ ឬចៅសង្កាត់រង ត្រូវធ្វើការបែងចែកភារកិច្ចដូចខាងក្រោម :

ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈនិងសណ្ដាប់ធ្នាប់សាធារណៈ ។

មេឃុំ ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមពីលើភារកិច្ចដែលបានបែងចែកខាងលើនេះដល់ជំទប់ ឬចៅសង្កាត់រងរបស់ខ្លួន ។

## ជំពូកទី ៤
## តួនាទី មុខងារនិងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

មាត្រា ៤១.-

រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញនិងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចីរភាព សំរាប់បំពេញសេចក្ដីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនិងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ ។

មាត្រា ៤២.-

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទគឺ :

- តួនាទីបំរើកិច្ចការមូលដ្ឋានសំរាប់បំរើផលប្រយោជន៍ឃុំ សង្កាត់និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន ។
- តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។ល។

**មាត្រា ៤៣.-**

ក្នុងតួនាទីបំពេញកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ច :

- ធានាការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ
- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនិងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក
- បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។

**មាត្រា ៤៤.-**

ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាពនិងផ្តល់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកា សំរាប់អនុវត្ត ។

ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ ។

**មាត្រា ៤៥.-**

រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសំរេចលើវិស័យទាំងឡាយដូចខាងក្រោម :

- ព្រៃឈើ
- ប្រៃសណីយ៍និងទូរគមនាគមន៍
- ការពារប្រទេស ។ល។

- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- និងវិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។

**មាត្រា ៤៦.-**

តួនាទី មុខងារនិងអំណាចរបស់ឃុំ សង្កាត់ ដូចមានចែងក្នុងមាត្រា ៤២, ៤៣ និងមាត្រា ៤៤នៃច្បាប់នេះ អនុវត្តបានតែក្នុងរង្វង់ដែនដីឃុំ សង្កាត់របស់ខ្លួនតែប៉ុណ្ណោះ ។

ក្នុងករណីមានបញ្ហាកើតឡើងទាក់ទងសមត្ថកិច្ចរវាងឃុំ សង្កាត់ពីរឬច្រើន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់ការឱ្យមានការសិរុះសិរួលគ្នារវាងរដ្ឋបាលដែលពាក់ព័ន្ធទាំងនោះ ។

**មាត្រា ៤៧.-**

តួនាទី មុខងារនិងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ដូចមានចែងក្នុងមាត្រា ៤២, ៤៣, ៤៤ និងមាត្រា ៤៥នៃច្បាប់នេះ អាចកំណត់លំអិតជាក់ស្តែងបន្ថែមទៀតដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៨.-**

ឃុំ សង្កាត់មានអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ។

អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់សំរាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌ តួនាទី មុខងារនិងអំណាចរបស់ខ្លួន ។

ដីកាឃុំ សង្កាត់ត្រូវធ្វើឡើងតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ ។

រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនិងជាបន្ទាន់ក្នុងឃុំ សង្កាត់របស់ខ្លួននូវដីកាដែលបានសំរេចរួចហើយ ។ ល.ក.

**មាត្រា ៤៩.-**

ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែក្នុងរង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ ។

ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធបានឡើយ ។

ដីកាដែលដាក់ចេញដោយរដ្ឋបាលឃុំ សង្កាត់ ហើយផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធត្រូវចាត់ទុកជាមោឃៈដាច់ខាត ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវជូនដំណឹងអំពីមោឃភាពនេះជាលាយលក្ខណ៍អក្សរដល់ឃុំ សង្កាត់សាមីនិងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ៥០.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំអំពីទំរង់និងបែបបទ ដើម្បីឱ្យឃុំ សង្កាត់រៀបចំដីកាស្របទៅតាមសភាពការណ៍ក្នុងឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៥១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់តាមសេចក្ដីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែបញ្ហាទាំងឡាយដូចខាងក្រោម :

- ការអនុម័តលើគំរោងថវិកាឃុំ សង្កាត់
- ការកំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាននិងកំរៃសេវាផ្សេងៗ
- ការបោះឆ្នោតអនុម័តបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- ការអនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- បញ្ហាដទៃទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មេឃុំ ចៅសង្កាត់ដែលត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើប្រតិភូកម្មអំណាចឱ្យពុំអាចផ្ទេរអំណាចនេះបន្តទៅឱ្យបុគ្គលដទៃទៀតបានឡើយ ។ ៚

**មាត្រា ៥២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់ នៅតែទទួលខុសត្រូវលើកិច្ចការដែលបានធ្វើប្រតិភូកម្មនោះ ។

ការដកហូតនូវអំណាចដែលបានធ្វើប្រតិភូកម្ម មិនធ្វើឱ្យប៉ះពាល់ដល់សុពលភាពនៃកិច្ចការដែលបានធ្វើរួចហើយនោះឡើយ ។

## ជំពូកទី ៥
## ការតាមដាន ការត្រួតពិនិត្យនិងការធ្វើអន្តរាគមន៍

**មាត្រា ៥៣.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវកំណត់នីតិវិធីផ្សេងៗសំរាប់ធ្វើការតាមដាននិងត្រួតពិនិត្យអំពីសកម្មភាពទូទៅរបស់ឃុំ សង្កាត់ដើម្បី :

- ពិនិត្យមើលអំពីនីត្យានុកូលភាពនៃការគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទី ភារកិច្ច របស់ឃុំ សង្កាត់នីមួយៗ
- ពិនិត្យមើលការវិវត្តន៍អំពីសមត្ថភាពរបស់ឃុំ សង្កាត់នានា
- វាយតំលៃប្រមាណអំពីការធ្វើអន្តរាគមន៍និងការជួយឧបត្ថម្ភគាំទ្រចំពោះឃុំ សង្កាត់ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទីភារកិច្ច ។

ក្នុងការតាមដាន ការត្រួតពិនិត្យនិងការធ្វើការអន្តរាគមន៍ចំពោះឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចផ្ទេរអំណាចដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឱ្យជួយកិច្ចការនេះទៅតាមសំណូមពរការងារ ។

**មាត្រា ៥៤.-**

ឃុំ សង្កាត់ណាដែលមិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើអន្តរាគមន៍ដើម្បីឱ្យមានការបំពេញភារកិច្ចដែលច្បាប់បានតម្រូវនោះជាបន្ទាន់ ។ល។

ភារកិច្ចដែលច្បាប់បានតម្រូវ គឺជាភារកិច្ចមួយដែលក្រុមប្រឹក្សាឃុំ សង្កាត់ មានកាតព្វកិច្ចបំពេញតាមល័ក្ខខ័ណ្ឌទាំងឡាយនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានពាក់ព័ន្ធ ឬបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់ ។

**មាត្រា ៥៥.-**

ការតាមដាន ត្រួតពិនិត្យនិងធ្វើអន្តរាគមន៍រួមមានការងារ :

- ស៊ើបអង្កេតនិងវាយតំលៃ
- ធ្វើសេចក្តីណែនាំជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបំពេញភារកិច្ចដែលច្បាប់បានតម្រូវ
- ធ្វើជំនួសក្នុងការបន្តបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ។

**មាត្រា ៥៦.-**

ការធ្វើអន្តរាគមន៍ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៥៤ នៃច្បាប់នេះត្រូវមានលក្ខណៈសមហេតុផលនិងស្របទៅតាមទំហំនៃកិច្ចការដែលក្រុមប្រឹក្សាឃុំ សង្កាត់ មិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ដោយភ្ជាប់ជាមួយនូវការណែនាំនិងការគាំទ្រសំខាន់ចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាចបំពេញភារកិច្ចដែលច្បាប់បានតម្រូវជាធម្មតា ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានសិទ្ធិចុះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយបុគ្គល ឬអង្គការណាមួយ ឬធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌឱ្យបំពេញការងារចាំបាច់ដើម្បីធ្វើអន្តរាគមន៍ក្នុងនាមខ្លួនចំពោះកិច្ចការណាមួយ ។

**មាត្រា ៥៧.-**

កាលបើការធ្វើអន្តរាគមន៍មិនទទួលបានលទ្ធផលចំពោះភារកិច្ចដែលច្បាប់បានតម្រូវណាមួយ ឬមួយចំនួនក្នុងអំឡុងពេល ៦ខែ ហើយភារកិច្ចដែលច្បាប់បានតម្រូវជាទូទៅក្រុមប្រឹក្សាឃុំ សង្កាត់ក៏មិនអាចបំពេញបាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំលាយក្រុមប្រឹក្សាឃុំ សង្កាត់ ហើយធ្វើការបោះឆ្នោតឡើងវិញទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ល។

**មាត្រា ៥៨.-**

ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ណាធ្វើសកម្មភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ផ្ទុយនឹងនយោបាយរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ នោះជាបន្ទាន់ ហើយត្រូវធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះឡើងវិញ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះនិងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៥៩.-**

ត្រូវបង្កើតឱ្យមានអង្គភាពមួយចំណុះក្រសួងមហាផ្ទៃដើម្បីធ្វើជាសេនាធិការអំពីការងាររដ្ឋបាលមូលដ្ឋាន ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពនេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៦
## ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

**មាត្រា ៦០.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ អនុម័តនិងអនុវត្តនូវផែនការអភិវឌ្ឍន៍ឃុំសង្កាត់ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធីនិងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៦១.-**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរបស់ជាតិ ។

**មាត្រា ៦២.-**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឆ្នាំទី ១ នៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវពិនិត្យឡើងវិញដើម្បីផ្តល់ទិន្នន័យថ្មីៗជារៀងរាល់ឆ្នាំ ដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។ម.ក.

**មាត្រា ៦៣.-**

ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់វិធានការដូចតទៅ :

- វាយតំលៃអំពីកំរិតអត្ថិភាពនៃការអភិវឌ្ឍន៍និងសកម្មភាពអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់របស់ខ្លួន

- ប្រមូលផ្តុំសេចក្តីត្រូវការក្នុងឃុំ សង្កាត់និងកំណត់អាទិភាពចំពោះសេចក្តីត្រូវការទាំងនោះ ដោយផ្អែកទៅលើធនធានទាំងឡាយដែលឃុំ សង្កាត់មាននិងធនធានដែលបានទទួល

- រៀបចំកម្មវិធីដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការនានា តាមរយៈការផ្តល់សេវានិងការអភិវឌ្ឍន៍ ហើយកម្មវិធីទាំងនេះត្រូវបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់

- ផ្តល់សេវានិងការអភិវឌ្ឍន៍ អនុលោមទៅតាមថវិការបស់ខ្លួន

- ពិនិត្យ តាមដាននិងវាយតំលៃចំពោះលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍

- ប្រើប្រាស់លទ្ធផលផ្សេងៗ ដើម្បីវាយតំលៃអំពីកំរិតនៃការអភិវឌ្ឍន៍ថ្មីៗក្នុងឃុំ សង្កាត់របស់ខ្លួន

- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ជូនប្រជាពលរដ្ឋរបស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដឹកនាំការងារឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៦៤.-**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិនិងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយផង ។

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក៏ត្រូវកំណត់ផងដែរនូវវិធីសាស្ត្រនិងមធ្យោបាយនានាដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល ។ ល.ស.

មាត្រា ៦៥.-

ក្នុងករណីដែលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ណាមួយធ្វើឡើងមិនស្របតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងច្បាប់នេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់កែតំរូវផែនការរបស់ខ្លួនឱ្យបានសមស្របក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលច្បាប់ចម្លងនៃផែនការនោះ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការកែសំរួលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនឱ្យបានសមស្របតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ៦៦.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការតាមដាន ត្រួតពិនិត្យនិងវាយតំលៃរាល់ការអនុវត្តផែនការ កម្មវិធី គំរោងនិងការផ្តល់សេវានានាប្រកបដោយតម្លាភាពនិងមានការទទួលខុសត្រូវខ្ពស់ ។

មាត្រា ៦៧.-

ក្រុមប្រឹក្សាឃុំ សង្កាត់នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដាន ការត្រួតពិនិត្យនិងការវាយតំលៃចំពោះផែនការ កម្មវិធីនិងគំរោងនានា ទោះជាការងារនោះត្រូវបានអនុវត្តដោយសមាសភាពណាក៏ដោយដែលខ្លួនបានជ្រើសយក ។

មាត្រា ៦៨.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំក្រុមប្រឹក្សាឃុំ សង្កាត់អំពីវិធីផ្សេងៗក្នុងការអនុវត្តផែនការនិងក្នុងការត្រួតពិនិត្យ វាយតំលៃចំពោះការប្រើប្រាស់មូលនិធិសំរាប់ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

មាត្រា ៦៩.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ប្រចាំឆ្នាំអំពី :

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់នាឆ្នាំសារពើពន្ធកន្លងមក
- លទ្ធផលនៃការអនុវត្តចំពោះកិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍ទាំងនោះរបស់ឃុំ សង្កាត់ ./.

- វិធានការធ្វើឱ្យបានល្អប្រសើរចំពោះវិស័យនានាដែលមានការខ្វះចន្លោះក្នុងការអនុវត្តកន្លងមក

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តសេចក្តីរាយការណ៍នេះក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីបំណាច់ឆ្នាំសារពើពន្ធនីមួយៗ ។

**មាត្រា ៧០.-**

សេចក្តីរាយការណ៍ប្រចាំឆ្នាំដូចមានចែងក្នុងមាត្រា ៦៩នៃច្បាប់នេះ ក្រោយពីបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ :

- ចម្លងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តម្កល់ទុកជាសាធារណៈ
- ចម្លងចែកជូនអង្គការ សមាគមនិងសាធារណជនសំខាន់ៗដោយគិតត្រឹមថ្លៃដើម ។

**មាត្រា ៧១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិនិត្យពិចារណាទៅលើមតិយោបល់ផ្សេងៗដែលបានផ្តល់ចំពោះសេចក្តីរាយការណ៍ដូចមានចែងក្នុងមាត្រា ៦៩ និងមាត្រា ៧០នៃច្បាប់នេះ ហើយត្រូវទទួលយកនូវមតិយោបល់ល្អៗ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**មាត្រា ៧២.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវពិគ្រោះពិភាក្សាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីចេញសេចក្តីណែនាំអនុវត្តជាក់ស្តែងនូវបទប្បញ្ញត្តិនានា ដែលបានចែងក្នុងជំពូកទី ៦ នៃច្បាប់នេះ ។

## ជំពូកទី ៧
## ហិរញ្ញវត្ថុឃុំ សង្កាត់

**មាត្រា ៧៣.-**

ឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុ ថវិកានិងទ្រព្យសម្បត្តិផ្ទាល់ ។ /ន.

**មាត្រា ៧៤.-**

ឃុំ សង្កាត់មានសិទ្ធិទទួលចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ។

ពន្ធខាងលើនេះរាប់បញ្ចូលនូវពន្ធលើដីធ្លី ពន្ធលើអចលនទ្រព្យនិងពន្ធនៃការជួល ។

ក្នុងករណីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រមូលចំណូលផ្ទាល់របស់ឃុំ សង្កាត់ ការប្រមូលចំណូលនេះត្រូវធ្វើក្នុងនាមឃុំ សង្កាត់ ។

ប្រភេទ កំរិតនិងរបៀបរបបនៃការប្រមូលចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ខាងលើនេះត្រូវកំណត់ដោយច្បាប់ ។

**មាត្រា ៧៥.-**

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវធនធានវិភាជន៍ពីចំណូលរដ្ឋ សំរាប់ថវិការបស់ខ្លួន ។

ធនធានវិភាជន៍នេះរួមមានៈ

- ការផ្ទេរទាំងមូលឬមួយផ្នែកនូវប្រាក់ចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធដីជាក់លាក់របស់រដ្ឋ
- ទាយជ្ជទាននិងធនធានវិភាជន៍ ឧបត្ថម្ភធន ឬអនុប្បទានដែលបានមកពីប្រាក់ចំណូលរដ្ឋ ។

ធនធានវិភាជន៍ខាងលើនេះត្រូវផ្តល់ទៅឱ្យឃុំ សង្កាត់តាមរតនាគារខេត្ត ក្រុង ។

ការរៀបចំនិងនីតិវិធីនៃការផ្ទេរប្រាក់វិភាជន៍ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៦.-**

ឃុំ សង្កាត់នីមួយៗ មានសិទ្ធិទទួលបាននូវប្រាក់កំរៃ ចំពោះការអនុវត្តនូវតួនាទីជាភ្នាក់ងារតំណាងរដ្ឋដែលរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលបានប្រគល់ឱ្យអនុវត្ត ។

ប្រាក់កំរៃខាងលើនេះគឺជាប្រាក់បន្ថែមពីលើប្រាក់ចំណូលរបស់ឃុំ សង្កាត់ ឬប្រាក់វិភាជន៍ផ្សេងៗដែលឃុំ សង្កាត់ទទួលបានពីប្រាក់ចំណូលរដ្ឋ ។៚

រាជរដ្ឋាភិបាលឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលត្រូវផ្តល់កំរៃសមស្របដល់ឃុំ សង្កាត់ ដែលបានអនុវត្តតួនាទីជាភ្នាក់ងារតំណាងរដ្ឋដូចបានចែងខាងលើ ។

ក្នុងករណីដែលការប្រគល់អំណាច មុខងាររបស់រដ្ឋមានលក្ខណៈជាអចិន្ត្រៃយ៍ទៅឱ្យឃុំ សង្កាត់រាជរដ្ឋាភិបាលត្រូវរៀបចំឱ្យមានធនធានហិរញ្ញវត្ថុរយៈពេលយូរអង្វែងសំរាប់ផ្តល់ឱ្យឃុំ សង្កាត់ ។

ការរៀបចំប្រាក់កំរៃខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៧.-**

រដ្ឋបង្កើតឱ្យមានមូលនិធិឃុំ សង្កាត់ ។

មូលនិធិឃុំ សង្កាត់បង្កើតឡើងក្នុងគោលដៅដើម្បីធ្វើការផ្ទេរនូវប្រាក់ចំណូលពីជាតិនិងប្រាក់ចំណូលផ្សេងៗទៀតទៅឱ្យថវិកាឃុំ សង្កាត់ ។

ការផ្ទេរប្រាក់ចំណូលពីជាតិទៅមូលនិធិខាងលើនេះត្រូវធ្វើឡើងទៅតាមរូបមន្តឬតាមអត្រាជាក់លាក់មួយសំរាប់ថេរៈវេលាយ៉ាងតិច ៣ឆ្នាំ និងមិនលើសពី ៥ឆ្នាំដែលកំណត់ដោយអនុក្រឹត្យ ។

នីតិវិធីអនុវត្តជាក់ស្តែងនៃមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៨.-**

មូលនិធិឃុំ សង្កាត់បានមកពី :

- ការធ្វើវិភាជន៍នូវចំណែកដ៏ជាក់លាក់នៃប្រាក់ចំណូលរដ្ឋ ពីថវិការដ្ឋប្រចាំឆ្នាំដែលកំណត់ដោយអនុក្រឹត្យ
- អនុប្បទាននិងការខ្ចីពីប្រភពក្នុងប្រទេសនិងក្រៅប្រទេស ។

ការធ្វើវិភាជន៍នូវធនធានប្រចាំឆ្នាំទៅឱ្យឃុំ សង្កាត់តាមមូលនិធិឃុំ សង្កាត់ត្រូវធ្វើឡើងទៅតាមរូបមន្តដែលកំណត់ដោយអនុក្រឹត្យ ។

របៀបរបបចាត់ចែង វិធាននៃការប្រើប្រាស់និងនីតិវិធីនៃការបើកប្រាក់ចំណាយពីមូលនិធិឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៩.-**

ឃុំ សង្កាត់ត្រូវរៀបចំនិងអនុម័តថវិការបស់ខ្លួនជារៀងរាល់ឆ្នាំ ។ល។

ថវិកាឃុំ សង្កាត់ត្រូវរៀបចំទៅតាមទំរង់មួយនិងអនុម័តនៅក្នុងកាលបរិច្ឆេទ ឬមុនកាលបរិច្ឆេទមួយអនុលោមទៅតាមប្រពន្ធ័ថវិកាជាតិ ។

ថវិកាឃុំ សង្កាត់ត្រូវមានតុល្យភាពរវាងចំណូលសរុបនិងចំណាយសរុប ។

ឃុំ សង្កាត់អាចបង្កើនចំណាយបាន តែត្រូវឱ្យស្របទៅតាមចំណូលរបស់ខ្លួន ។

ថវិកាឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំងអំពីអាទិភាពនិងសេចក្តីត្រូវការនៃផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់ ។

នីតិវិធីនៃការរៀបចំនិងការអនុម័តថវិកាខាងលើត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨០.-**

ឃុំ សង្កាត់គ្មានសិទ្ធិខ្ចីប្រាក់បានឡើយ ។

ឃុំ សង្កាត់មិនអាចធានារ៉ាប់រងចំពោះការខ្ចី ឬកាតព្វកិច្ចហិរញ្ញវត្ថុណាមួយបានឡើយ ។

**មាត្រា ៨១.-**

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវការផ្ទេរទ្រព្យសម្បត្តិមួយផ្នែករបស់រដ្ឋមកជាទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ ។

ឃុំ សង្កាត់ត្រូវគ្រប់គ្រងឱ្យបានល្អនូវទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯងនិងទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យ ។

ឃុំ សង្កាត់អាចប្រើប្រាស់និងទាញយកផលចំណូលពីទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យខ្លួនគ្រប់គ្រង ។

ឃុំ សង្កាត់ត្រូវថែរក្សាការពារទ្រព្យសម្បត្តិដែលរដ្ឋប្រគល់ឱ្យ។បានគង់វង្សហើយទ្រព្យសម្បត្តិទាំងនោះ ឃុំ សង្កាត់គ្មានសិទ្ធិលក់ដូរឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ ។

នីតិវិធីចាត់ចែងនិងប្រើប្រាស់ទ្រព្យសម្បត្តិខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨២.-**

ឃុំ សង្កាត់ត្រូវបង្កើតឱ្យមាននូវប្រព័ន្ធគ្រប់គ្រង តាមដាននិងត្រួតពិនិត្យហិរញ្ញវត្ថុរបស់ខ្លួនដែលរួមមាន : ល.ត.

- បទដ្ឋានហិរញ្ញវត្ថុនិងការអនុវត្តជាក់ស្តែងផ្នែកគណនេយ្យ
- ការចាត់ចែង គ្រប់គ្រងទ្រព្យសម្បត្តិ
- តំរូវការផ្សេងៗ ក្នុងការធ្វើសវនកម្ម
- ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព ប្រសិទ្ធិភាពនិងការទទួលខុសត្រូវ ។

ប្រព័ន្ធនៃការគ្រប់គ្រង ការតាមដាននិងការត្រួតពិនិត្យហិរញ្ញវត្ថុឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨៣.-**

របបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានពិភាក្សាឯកភាពលើគោលការណ៍ជាមួយក្រសួងមហាផ្ទៃ ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ៨៤.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទទួលវិន័យដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

វិន័យរួមមាន :

- ស្តីបន្ទោសក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានកំណត់ហេតុច្បាស់លាស់
- ករណីនៅតែបន្តប្រព្រឹត្តកំហុស ត្រូវកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភ ។

វិន័យដែលតម្រូវឱ្យកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភដូចចែងខាងលើអាចអនុវត្តបាន លុះត្រាតែមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសេចក្តីស្នើសុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រាក់ឧបត្ថម្ភដែលកាត់នេះត្រូវបានមកជាប្រយោជន៍នៃថវិកាឃុំ សង្កាត់ ។៙ន.

ក្នុងករណីបានអនុវត្តបភាពវិន័យទាំងពីរខាងលើរួចហើយ តែសាមីខ្លួននៅតែមិនរាងចាល ក្រុមប្រឹក្សាឃុំ សង្កាត់អាចបញ្ឈប់ជននោះពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដោយការបោះឆ្នោតអនុម័តតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ហើយត្រូវធ្វើការជ្រើសរើសសមាជិកថ្មីមកជំនួសតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ទទួលវិន័យ ត្រូវជ្រើសយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឬមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីអនុវត្តបភាពវិន័យខាងលើនេះ ។

មន្ត្រីដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំខាងលើនេះពុំមានសិទ្ធិអនុម័តឡើយ ។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**មាត្រា ៨៥.-**

ដើម្បីមានមូលដ្ឋានសំរាប់រៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់និងគ្រប់គ្រងឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសអំពីចំនួន ឈ្មោះនិងព្រំប្រទល់របស់ឃុំ សង្កាត់ ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ ។

**មាត្រា ៨៦.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ១ នេះ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវរៀបចំឡើងវិញនូវមេភូមិនានាចំណុះឃុំ សង្កាត់របស់ខ្លួនទៅតាមបែបបទនីតិវិធីដូចមានចែងក្នុងមាត្រា ៣០នៃច្បាប់នេះ ។

**មាត្រា ៨៧.-**

ដើម្បីបង្កលក្ខណៈសម្បត្តិដល់ការគ្រប់គ្រងឃុំ សង្កាត់តាមប្រព័ន្ធវិមជ្ឈការត្រូវបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយឈ្មោះថា "គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់" ដែលមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន ។ល។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតបន្ទាប់ពីច្បាប់នេះបានចូលជាធរមាន ហើយត្រូវបញ្ចប់អាណត្តិរបស់ខ្លួនឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចចែកចេញជាអនុគណៈកម្មការតាមការចាំបាច់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ត្រូវយកអង្គភាពដែលបានបង្កើតឡើងស្របតាមមាត្រា ៥៩នៃច្បាប់នេះធ្វើជាលេខាធិការដ្ឋាន ។

**មាត្រា ៨៨.-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់មានសមត្ថកិច្ចធ្វើសេចក្តីស្នើយោបល់ទៅក្រសួងមហាផ្ទៃនិងរាជរដ្ឋាភិបាលអំពីបញ្ហានានាដូចខាងក្រោម :

- សិក្សាស្រាវជ្រាវកំណត់ឡើងវិញនូវព្រំប្រទល់ឃុំ សង្កាត់ទាំងអស់ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- បែងចែកមុខងារ សិទ្ធិអំណាចនិងភារកិច្ចផ្សេងៗ រវាងរាជរដ្ឋាភិបាលនិងឃុំ សង្កាត់ព្រមទាំងរៀបចំឱ្យមានកិច្ចសហការសំរបសំរួលរវាងឃុំ សង្កាត់ ពីរឬច្រើន ។
- បណ្តុះបណ្តាល បង្កើនសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់
- រៀបចំប្រាក់ចំណូលនិងសារពើពន្ធសំរាប់ឃុំ សង្កាត់
- គាំទ្រផ្នែកបច្ចេកទេសដល់ឃុំ សង្កាត់
- វិះរកមធ្យោបាយសំរាប់ផ្តល់ពត៌មាននិងគំរង់ទិសរដ្ឋបាលសាធារណៈអំពីកិច្ចដំណើរការនៃប្រព័ន្ធគ្រប់គ្រងឃុំ សង្កាត់តាមបែបប្រជាធិបតេយ្យនិងវិមជ្ឈការ
- ផ្តល់យោបល់ដល់រាជរដ្ឋាភិបាលអំពីការអនុវត្តនយោបាយវិមជ្ឈការក្រោមអំណាចនៃច្បាប់នេះនិងផ្តល់យោបល់លើការកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំព្រាងលិខិតបទដ្ឋានសំរាប់អនុវត្តច្បាប់នេះ
- រួមយោបល់ទៅលើអនុក្រឹត្យដែលមានការពាក់ព័ន្ធដល់ការងារនៅថ្នាក់ឃុំ សង្កាត់ ល.។.

- កំណត់របបគ្រប់គ្រងរដ្ឋបាលអន្តរកាលចំពោះឃុំ សង្កាត់ដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអនុវត្តនយោបាយវិមជ្ឈការ ។

**មាត្រា ៨៩.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយផ្អែកតាមសេចក្តីស្នើយោបល់របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចស្នើបង្កើតឃុំ សង្កាត់ លុបចោលឃុំ សង្កាត់ កែប្រែព្រំប្រទល់ឃុំ សង្កាត់ ផ្លាស់ប្តូរឈ្មោះឃុំ សង្កាត់ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៦ និងមាត្រា ១៧នៃច្បាប់នេះ សំរាប់ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ២ ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ៩០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១

ក្នុងព្រះបរមនាមនិងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

**ហត្ថលេខា**

**ជា ស៊ីម**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**ហត្ថលេខា**

ស ខេង    យូ ហុកគ្រី

លេខ : ៦០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ២១ ខែ ០៣ ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឆាឌី សាឌី**